# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៧ ខែសីហា លេខ ៨

ព.ស. ២៤៩៨ – គ.ស. ១៩៥៥

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — ទំព័រ

— សិប្បកថា .................... ព្រះឃោសធម្ម ម៉ឹង - សែស .. ៥៦៣

— បញ្ញាសជាតក ភាគទី ៣ (តមក) .... បណ្ឌិតមហា ឈឹម - ស៊ុម .... ៥៧៤

*ផ្នែកអក្សរសាស្ត្រ*

— ការទស្សនានិម្មាបនកម្មខ្មែរ ....... លោកញ៉ែម - ឌិម ........ ៥៨៨

— រឿងសាមកុក (តមក) .......... ឧកញ៉ា នូ - កន ......... ៦០១

— ដំណឹងតាមឲ្យល់ក្នុងកន្តារៈ (តមក) ... លោក ដេង - ជ្រឹវ ........ ៦១០

— រឿងបល្ល័ង្កទិព្យ (តមក) .......... លោក រ៉ាយ - ប៊ុក ........ ៦២០

*កំណត់នីងប្រវត្តិការណ៍*

— ប្រវត្តិវត្តបទុមវតីរាជវរារាម ......... ឃុនបណ្ណានុរ័ក្ស ប៊ូ - ប៊ូ .... ៦២៩

— ពិធីបុណ្យវិសាខបូជា នៅក្រុងភ្នំសឹងតោន. លេខាធិការ ញ៉ែម - ឌិម .... ៦៣៧

មួយឆ្នាំមាន ២១ សៀវភៅ — ដំឡៃជាវ ២១០រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES

PARTIE RELIGIEUSE: *Page*

— Sippakatha . . . . . . . . . *Vên. MENG-SES*. . . . . . 563

— Pannasajataka-vol. 3 (suite) . *M. CHHIM-SOUM* . . . . 574

PARTIE LITTERAIRE:

— Regard sur l'Architecture-khmêre . . . . . . . . . . *M. NHEM-KHEM* . . . 588

— Histoire de SAMKOK (suite). . *Okhna NOU-KAN* . . . . . 601

— Le souffle du désert (suite) . *M. PHENG-CHRIV* . . . 610

— Les trente deux récits du TRONE (suite) . . . . . . *M. RAY-BUC* . . . . . . 620

NOTES ET CHRONIQUES:

— Historique de Vat Botum Vaddey Reachavararam . . . . . . . *M. BOU-PO*. . . . . . . . 629

— Visakh bochéa à Washington . *M. NHEM-KHEM* . . . 637

Prix d'abonnement annuel (comprenant 12 numéros) 210$00

ផ្នែកសាសនា

## សិប្បកថា

ព្រះឃោសធម្ម ម៉ុង-សែស វត្តមហាមន្ត្រី

រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (៣ដង)

សូមនមស្ការចំពោះព្រះភគវន្តមុនី ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ ដោយសេចក្ដីគោរព) ។

ឱកាសនេះ អាត្មាភាពសូមសំដែងអំពីសិប្បកថា តាមទំនងដែលមានមកក្នុងមង្គលសូត្រព្រមទាំងអដ្ឋកថា ល្មមជាផ្លូវប្រតិបត្តិនៃពុទ្ធបរិស័ទទាំងឡាយ ។

ហត្ថកោសល្ល សេចក្ដីឈ្លៀវឆ្លាសប៉ិនប្រសប់ខាងការងារដោយដៃ គឺបេះធ្វើការកើតបានល្អត្រឹមត្រូវល្មមគេប្រើប្រាស់បាន ហៅ សិប្បៈឬសិល្បៈ ។ សិប្បៈនេះ បើសំរេចហើយជាការគាប់ប្រសើរក្នុងលោក ជាហេតុឲ្យបានទ្រព្យសម្បត្តិសក្ដិយសខ្ពង់ខ្ពស់ និងមានកិត្តិស័ព្ទល្អផ្សាយទៅសព្វទិស ។

ឯសិប្បៈនោះមាន ២ ប្រការ គឺៈ អនាគារិយសិប្បៈ= សេចក្ដីឈ្លៀវឆ្លាសប៉ិនប្រសប់ដោយដៃរបស់អ្នកបួស ១, អាគារិយសិប្បៈ= សេចក្ដីឈ្លៀវឆ្លាសប៉ិនប្រសប់ដោយដៃរបស់គ្រហស្ថ ។

អនាគារិយសិប្បៈ នោះ មានសេចក្ដីថា កិច្ចក្នុងសាសនានេះ មានប្រាជ្ញាឈ្លាសវៃចេះធ្វើការងារធំដុំ និងការងារបន្ទាប់បន្សំ ដល់ពួកសព្រហ្មចារីបាន ។ ចេះវៃលកកាត់ដេរជ្រលក់ត្រៃចីវរ ធ្វើសមណបរិក្ខារឯទៀត ៗ មានសំពត់និសីទនៈ សំពត់ជូតទឹកភ្លៀងនឹងត្រៃគាំងជាដើម ត្រឹមត្រូវតាមបញ្ញត្តិ ចេះបូកបាយអលាបទឹកកំបោរចេតិយ ចេះធ្វើខឿនចេតិយ ខឿនព្រះពោធិព្រឹក្សធ្វើកេនុបោសថជាដើម ហៅថាការងារធំដុំ; កិច្ចចេះធ្វើកន្ទុងសម្រាប់លាងជើង វត្ថុសម្រាប់ជូតជើងជាដើម ហៅថា ចេះធ្វើការងារបន្ទាប់បន្សំ ។ ការចេះដឹងបែបនេះ ហៅថា នាថករណធម៌ គឺធម៌ធ្វើនូវទីពឹងដល់ខ្លួន គឺបានសេចក្ដីរាប់អានអំពីសំណាក់ឧបជ្ឈាយ៍អាចារ្យនឹងព្រះថេរៈធំ ៗ ឯទៀត, ទាំងឧបាសកឧបាសិកា ក៏ច្រើនស្រឡាញ់រាប់អានកិច្ចបែបនេះ តែងទំនុកបំរុងបូជាដោយបច្ច័យទាំង ៤, ព្រោះហេតុនោះ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា សិប្បៈបែបនេះជាមង្គលដ៏ឧត្ដម ។

ឯ អាគារិយសិប្បៈ សេចក្ដីធៀបផ្ទាសប៉ុនប្រសប់ខាងការងារដោយដៃរបស់គ្រហស្ថនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងថា ជាមង្គលដ៏ឧត្ដម ចំពោះការងារណា ដែលផុតអំពីការបៀតបៀនសត្វដទៃ ឃ្លាងអំពីផ្លូវអកុសលទាំងពួង គឺការងាររបស់ជាងកែវ ជាងមាស ជាងប្រាក់ ជាងស្មិត ជាងឥដ្ឋ–កំបោរ ជាងឈើ ជាដើម ។ សិប្បៈនេះបានជាព្រះអង្គទ្រង់សំដែងថាជាមង្គល ព្រោះជាហេតុឲ្យបានផលប្រយោជន៍ក្នុងលោកនេះ ដូចមានរឿងរ៉ាវតទៅនេះ៖

ពោធិរាជកុមារ ជាព្រះរាជបុត្រព្រះបាទពិម្ពិសារ បានជួលជាងឈើម្នាក់ ឲ្យសាងប្រាសាទ ១ ខ្នង ឈ្មោះ កោកនទប្រាសាទ ប្រែថា "ប្រាសាទឈូកក្រហម" ។ ប្រាសាទនោះល្អក្រៃលែងជាងប្រាសាទឯទៀតៗ ជាប្រាសាទឆ្នើមក្នុងព្រះនគរ ។ វេលាសាងជិតហើយស្រេច ពោធិរាជកុមារមានព្រះបន្ទូលសួរជាងឈើថា ជាងឯងធ្លាប់ធ្វើប្រាសាទបែបនេះ ច្រើនដងច្រើនគ្រាណាស់មកហើយ ឬក៏ទើបទឹងធ្វើតែម្តងនេះទេ? . . .

ជាងឈើក្រាបទូលថា ទើបទឹងធ្វើតែម្តងនេះទេ ។ ពោធិរាជកុមារទ្រង់ព្រះដំរិះថា "ជាងនេះទើបតែទឹងធ្វើប្រាសាទ ១ នេះ ល្អម្ល៉េះទៅហើយ តទៅមុខទៀតជាងនេះមុខតែធ្វើប្រាសាទឲ្យគេឯទៀតៗល្អជាងប្រាសាទអញមិនខាន បើដូច្នោះគួរអញសំឡាប់ជាងនេះចោលចេញ ឬក៏កាត់ដៃចោល ឬឆ្កៀលភ្នែកវាចេញ ទើបបាន" ។ លុះគិតហើយក៏មានព្រះបន្ទូលប្រាប់រឿងនោះដល់មាណពម្នាក់ឈ្មោះសញ្ជិកាបុត្រ ជាមិត្រសំឡាញ់របស់ខ្លួន ។ សញ្ជិកាបុត្រមានសេចក្តីអាណិតអាសូរដល់ជាងឈើ ក៏និយាយប្រាប់ដំណើរនោះសព្វគ្រប់ដល់ជាងឈើ ដោយស្ងាត់កំបាំង ។

ជាងឈើក៏រកឧបាយនឹងដោះខ្លួនឲ្យរួចអំពីសេចក្តីវិនាស ។ លុះដល់ពេលតពីនោះមក ពោធិរាជកុមារមានព្រះបន្ទូលសួរថា ប្រាសាទស្រេចហើយឬនៅ? ។ ជាងឈើក្រាបទូលថា "មិនទាន់ស្រេចទេ នៅច្រើនណាស់" ហើយក្រាបទូលឲ្យរកឈើស្រាយ ៗ ស្ងួត ៗ ជាច្រើនមកឲ្យ

ហាមឃាត់ថា កុំឲ្យមនុស្សណាមួយចូលទៅក្នុងប្រាសាទនោះឲ្យសោះឡើយលែងតែភរិយាខ្លួនមួយដែលនាំយកអាហារទៅឲ្យ ។

ជាងឈើក៏ធ្វើសកុណយន្ត គឺយន្តហោះមានសណ្ឋានដូចសត្វបក្សីដោយឈើស្រាយតាំងនោះ នៅខាងក្នុងប្រាសាទ ។ ឯយន្តហោះរបស់ជាងឈើនោះ មានរូបភាពដូចសត្វបក្សីគ្រុឌ ។ ជាងឈើបង្គាប់ភរិយាឲ្យលក់ដូរទ្រព្យសម្បត្តិទាំងអស់យកសុទ្ធតែមាសនិងប្រាក់រៀបចំដំណើរទុកជាស្រេច លុះសំរេចសកុណយន្តហើយ ក៏នាំភរិយានិងកូនឡើងជិះសកុណយន្តយកមាសប្រាក់និងទ្រព្យឯទៀតដែលស្រាលៗ ជារបស់ផងខ្លួនដាក់ក្នុងសកុណយន្តបើកសកុណយន្ត ហោះចេញតាមបង្អួចប្រាសាទទៅកាន់ប្រទេសព្រៃហិមពាន្ត ទៅចុះត្រង់ទីកន្លែង ១ ដ៏សមគួរ បានសាងទីក្រុង ១ ត្រង់កន្លែងនោះ ។ លុះនៅក្នុងទីក្រុងនោះយូរៗ ទៅ ជាងឈើបានសោយរាជ្យជាស្ដេចក្នុងនគរនោះ ព្រះនាមថា កដ្ឋវាហនរាជ បានចំរើនរុងរឿងដរាបដល់អស់ព្រះជន្ម ។

សំដែងរឿងនេះដើម្បីញុំាងសាធុជនឲ្យជ្រាប អំពីកម្លាំងហេតុកោសល្យ សេចក្ដីឈ្លៀវឆ្លាសប៉ិនប្រសប់ដោយដៃដែលហៅថាសិប្បៈនោះអាចឲ្យប្រយោជន៍គឺសេចក្ដីសុខចំរើនសក្ដិយសទ្រព្យសម្បត្តិ ក្នុងលោកនេះពិតប្រាកដ ។

ន័យមួយទៀត ក្នុងកម្ពុជរដ្ឋយើងនេះអ្នកកាន់ព្រះពុទ្ធសាសនាមានចំនួនច្រើន អ្នកខ្លះមានសេចក្ដីសង្ស័យដដែកគ្នាថា ខ្ញុំយើងធ្វើបុណ្យធ្វើទានច្រើនជាងគេ ហេតុអ្វីក៏ក្រខ្សត់ទ្រព្យសម្បត្តិជាងគេ? ជាតិដទៃ

គេមិនសូវធ្វើបុណ្យធ្វើទានទេ ខ្វះគ្មានធ្វើសោះ ហេតុអ្វីក៏គេច្រើនមានទ្រព្យសម្បត្តិផងយើង?

សូមឆ្លើយតបប្រស្នានេះ ឲ្យឃើញថាបុណ្យភ័ព្វព្រេងសំណាងនឹងសិប្បៈមានលក្ខណការណ៍ផ្សេងគ្នានេះ ដូចមានសេចក្តីតទៅនេះ:

ព្រះសព្វញ្ញុពុទ្ធ ទ្រង់ប្រាប់ហេតុផលសព្វគ្រប់ ទ្រង់សំដែងមង្គលសូត្រត្រង់គាថាទី ២ ត្រង់មង្គលទី ៥ ថា បុព្វេ ច កតបុញ្ញតា ការកសាងបុណ្យកុសលអំពីជាតិមុនៗមក ក៏បានជាមង្គលក្នុងបច្ចុប្បន្ននេះ គឺបរិបូណ៌ដោយទ្រព្យសម្បត្តិស័ក្តិយសដ៏ខ្ពង់ខ្ពស់ក្នុងលោកនេះ ៗ ព្រះអដ្ឋកថាចារ្យលោកទាញរឿងរ៉ាវមកអាង ដូចមានតទៅនេះ ព្រះបាទកាកវណ្ណតិស្សមហារាជ បានសោយរាជ្យ ក្នុងពេហណជនបទ ទីក្រុងឈ្មោះមហាគ្រាម, លុះទ្រង់សោយព្រះទីវង្គតទៅ មានព្រះរាជបុត្រ ១ ព្រះអង្គព្រះនាម ទុដ្ឋគាមណីអភ័យ សោយរាជ្យស្នងព្រះបិតាឡើង ៗ សម័យជាខាងក្រោយ ព្រះបាទទុដ្ឋគាមណីអភ័យ ទ្រង់ស្តេចយាងចេញអំពីពេហណជនបទ ទ្រង់ធ្វើគតស្តេចទមិឡ ១ ព្រះអង្គ ព្រះនាមឯឡារៈ ហើយទ្រង់បានឡើងជាឯករាជ្យ ទ្រង់គង់នៅក្នុងក្រុងអនុរាធបុរីក្នុងលង្កាទ្វីប ៗ ក្នុងគ្រាកាលដែលព្រះសម្ពុទ្ធបរិនិព្វានហើយកន្លងទៅបាន ៣៧២ ឆ្នាំ ព្រះបាទទុដ្ឋគាមណីអភ័យមានបុណ្យអស្ចារ្យមានកំណប់ទ្រព្យជាច្រើនផុសឡើងសំរាប់ព្រះអង្គ ក្នុងទីជុំវិញនៃក្រុងអនុរាធបុរី ព្រោះបានកសាងបុណ្យកុសលទុកមកអំពីជាតិមុន ៗ

១– ខាងភាគទិសឦសានប្រមាណ ៣ យោជន៍អំពីក្រុងអនុរាធបុរី

ក្នុងស្រុកមួយឈ្មោះអាវរ៉ាវដិគ្រាម មានដុំមាសជាច្រើនប្រវែង ១ ចំអាមក៏មាន ១ អង្គុលីក៏មាន ផុសឡើងលើផ្ទៃផែនដីប្រមាណ ១៦ ករីស ។

២. ខាងភាគទិសឯកើតប្រមាណ ៧ យោជន៍ ក្នុងជនបទ ១ ឈ្មោះតម្ពបិដ្ឋិ ត្រើយខាងនាយនៃស្ទឹងគង្គា មានទង់ដែងជាច្រើនផុសឡើងលើផ្ទៃផែនដី ។

៣– ខាងភាគទិសអាគ្នេយ៍ ប្រមាណ ៤ យោជន៍ ក្នុងស្រុក ១ ឈ្មោះព៉បីគ្រាម មានកែវមណីជាច្រើនផុសឡើងលើផ្ទៃផែនដី ។

៤– ខាងភាគទិសឯត្បូងប្រមាណ ៨ យោជន៍ ក្នុងអម្ពដ្ឋកោលជនបទ មានប្រាក់ផុសឡើងក្នុងគុហា ១ ។

៥– ខាងភាគទិសឯលិច ប្រមាណ ៥ យោជន៍ ក្នុងកំពង់ ១ ឈ្មោះឧរុវេល: មានកែវមុក្តាជាច្រើន ទំហំប៉ុនផ្លែកន្ទួតព្រៃខ្នាតធំ មានទ្រង់ទ្រាយដូចផ្លែកន្ទួតព្រៃចំនួន ៦០ រទេះធំ ព្រមទាំងកែវប្រពាឡផង ផុសឡើងនៅលើគោក ។

៦– ខាងភាគទិសឯជើង ប្រមាណ ៧ យោជន៍ អំពីអនុរាធបុរី មានកែវមណី ៤ ដុំ មានសម្បុរដូចផ្កាត្រកៀត ប្រវែង ១ ចំអាម ៤ ធ្នាប់ ទំហំប៉ុនចង្សំពប់គិនយ៉ាងតូច ផុសឡើងនៅលើផ្កខ្យាប់ ក្នុងស្ទឹងតូច ១ ដែលហូរកាត់ស្រុក ១ ឈ្មោះបេឡុវាបិកគ្រាម ចុះទៅក្នុងបឹង ១ ។

មនុស្សទាំងឡាយដែលបានឃើញមាសជាដើមផុសឡើងដូច្នោះក៏នាំគ្នាមកក្រាបបង្គំទូលព្រះបាទទុដ្ឋគាមណីអភ័យ ។ ក៏មានព្រះរាជឧង្ការត្រាស់បង្គាប់ឲ្យជីកនាំជញ្ជូនមកដាក់ជាព្រះរាជទ្រព្យក្នុងព្រះឃ្លាំងរបស់

ព្រះអង្គ ។ នេះជាផលរបស់បុណ្យ ក័ត្តព្រេងសំណាងព្រះមហាក្សត្រអង្គនេះ ទ្រង់បានកសាងទុកមកអំពីជាតិមុន មិនមែនកើតដោយកំឡាំងព្យាយាមឬវិជ្ជាសិល្បសាស្ត្រ ក្នុងបច្ចុប្បន្ននេះទេ ។

ឯសិប្បៈ មង្គលទី ៨ គាថាទី ៣ ក្នុងមង្គលសូត្រនេះ ដូចបានសំដែងមកហើយខាងដើមនោះ និយាយចំពោះតែអំពីវិជ្ជាសិល្បសាស្ត្រដែលសំរេចហើយក្នុងបច្ចុប្បន្ននេះ អាចឲ្យផលប្រយោជន៍ក្នុងបច្ចុប្បន្ននេះ ដូចជាព្រះបាទកដ្ឋហារកជនោះឯង ។

មនុស្សក្នុងលោកនេះ ទោះជាតិណាក៏ដោយ ប្រទេសណាក៏ដោយ ដែលមានទ្រព្យសម្បត្តិថ្កុំថ្កើងរុងរឿង មិនមែនសុទ្ធតែសំរេចមកអំពីការកសាងបុណ្យកុសលអំពីជាតិមុនទាំងអស់ទេ សំរេចមកអំពីវិជ្ជាសិល្ប-សាស្ត្រក្នុងបច្ចុប្បន្ននេះក៏មានដោយច្រើន; ព្រោះហេតុនោះហើយបានជាប្រទេសធំៗឯទៀត គេចំប្រឹងប្រែងរៀនវិជ្ជាគ្រប់មុខបានចេះដឹងច្រើន បានទៅជាអ្នកមានទ្រព្យសម្បត្តិច្រើនថ្កុំថ្កើងរុងរឿងជាងប្រទេសដែលល្ងង់ទៅៗ មួយយ៉ាងទៀតមានសំដែងក្នុងគម្ពីរព្រះពុទ្ធសាសនាក្នុងទីឯទៀតថា បុគ្គលអ្នកមានបុណ្យក័ត្តច្រើន តែងអន្ទោលចាប់កំណើតកើតក្នុងត្រកូលសុក្កសុមក្នុងប្រទេសធំៗ សមទឹងបុណ្យដែលខ្លួនបានកសាងទុកមក ។ បើមកកើតក្នុងត្រកូលខ្សត់ខ្សោយក្នុងប្រទេសតូចៗ ដែលក្រីក្រទ្រព្យធន ធ្វើម្តេចនឹងសមតាមទំនងបុណ្យក័ត្តនោះ ។

មយ៉ាងទៀត អ្នកដែលប្រកបដោយវិជ្ជាសិល្បសាស្ត្រ មិនត្រឹមតែបានផលប្រយោជន៍ក្នុងបច្ចុប្បន្ននេះប៉ុណ្ណោះទេ, បើបានជួបប្រទះនឹងស្រែ

បុណ្យល្អ បានបណ្តុះពូជបុណ្យទៅក្នុងស្រែបុណ្យនោះ នឹងបានផលប្រយោជន៍ច្រើនក្នុងបរលោកទៀតផង បានសំរេចប្រយោជន៍ដ៏ឧត្តមគឺមគ្គផលនិព្វានផងទៀត ដូចមានរឿងរ៉ាវតទៅនេះ ។

ក្នុងកាលកន្លងទៅហើយ ឯកោ នឡកាកេ មានជាងត្បាញកន្ទេលបបុសម្នាក់នៅក្នុងនគរពារាណសី; ថ្ងៃ ១ ជាងនោះដើរទៅកាន់ស្រែបានជួបនឹងព្រះបច្ចេកពុទ្ធ ១ ព្រះអង្គ ក៏បង្គាប់ទាសកម្មករឲ្យទៅធ្វើការងារក្នុងស្រែ, ឯអាត្មាឯងត្រឡប់មកផ្ទះវិញនិមន្តព្រះបច្ចេកពុទ្ធឲ្យឆាន់ក្នុងផ្ទះ ហើយក៏និមន្តទៅកាន់ឆ្នេរទន្លេគង្គា ទៅជាមួយនឹងកូនប្រុសម្នាក់ផង, បានសង់បណ្ណសាលា គឺសាលាប្រក់ស្លឹក ១ ខ្នង យកឈើឧទុម្ពរធ្វើជាជើងជញ្ជាំង យកកន្ទេលបបុសធ្វើជាជញ្ជាំង ធ្វើទីចង្ក្រមន៍ ១ ផង, និមន្តព្រះបច្ចេកពុទ្ធឲ្យគង់នៅក្នុងបណ្ណសាលានោះអស់ ៣ ខែ ។ ជនទាំង ២ នាក់ គឺបិតានឹងបុត្រប្រុសបានប្រគេនត្រៃចីវរដល់ព្រះបច្ចេកពុទ្ធ ដែលគង់ចាំវស្សារួចហើយ បានគោរពរាប់អានទំនុកបំរុងបូជាព្រះបច្ចេកពុទ្ធ ៧ ព្រះអង្គដទៃទៀត ដូចព្រះបច្ចេកពុទ្ធ ១ អង្គមុននោះដែរ ។ ជនទាំង ២ នាក់ គឺបិតានឹងបុត្រប្រុសលុះធ្វើមរណកាលទៅក៏បានទៅកើតក្នុងពិភពតាវត្តិង្ស សោយទិព្វសម្បត្តិក្នុងឋានតាវត្តិង្ស ជាអនុលោមនឹងបដិលោម ។

ចំណែកទេវបុត្រជាបិតាស្ថិតនៅក្នុងទេវលោកដដែល ឯទេវបុត្រជាបុត្រប្រុស ក៏ច្យុតចុះមកចាប់កំណើតក្នុងផ្ទៃនាងសុមេធាទេវី ជាមហេសីនៃព្រះបាទសុរុចិរាជក្នុងមិថិលា ដែននិទេហៈគ្រប់កំណត់ ១០ ខែ

ក៏ប្រសូតមក គេថ្វាយព្រះនាមថា មហាបនាទកុមារ, លុះមានព្រះជន្មាយុ ១៦ ឆ្នាំ ក៏បានសំរេចវិជ្ជាសិល្បសាស្ត្រគ្រប់ប្រការ ។ ព្រះរាជបិតាទ្រង់ត្រាស់បង្គាប់ពួកវត្ថុវិជ្ជាចារ្យ គឺអាចារ្យដែលចេះមើលទីដីសង់ផ្ទះថា អ្នកកាល់គ្នាចូរនាំយកជាងមកសាងប្រាសាទឲ្យកូនរបស់អញ អញនឹងអភិសេកកូនអញឲ្យសោយរាជ្យ ។ ពួកវត្ថុវិជ្ជាចារ្យក៏ទទួលព្រះរាជឱង្ការ ហើយពិចារណាមើលប្រទេសផែនដីដោយសព្វគ្រប់ ក៏កើតក្តៅរំជួលដល់អាស្នព្រះឥន្ទ្រាធិរាជ ១ រំពេច ដោយអានុភាពបុណ្យរបស់មហាបនាទកុមារនោះ ។ ព្រះឥន្ទ្រាធិរាជទ្រង់ជ្រាបការណ៍នោះសព្វគ្រប់ ទ្រង់ប្រើព្រះវិស្សកម្មទេវបុត្រឲ្យចុះមកសាងប្រាសាទថ្វាយមហាបនាទកុមារ ។

ព្រះវិស្សកម្មទេវបុត្រក៏កៀសខ្លួនជាមេជាង មកកាន់សំណាក់ពួកជាងបញ្ជូនពួកជាងឲ្យត្រឡប់ទៅកាន់ស្ថានលំនៅរៀងខ្លួន ហើយយកដំបង់វាយផែនដី ក៏ស្រាប់តែមានប្រាសាទកែវ ៧ ប្រការ មានសណ្ឋាន ៤ ជ្រុងស្មើគ្នា គឺទទឹងកន្លះយោជន៍ បណ្តោយកន្លះយោជន៍ កំពស់ ២៥ យោជន៍ មានជាន់ ៧ ផុសឡើងមួយរំពេច ។ មហាបនាទស្តេចគង់នៅជាសុខសម្រាន្តក្នុងប្រាសាទកែវជាអស្ចារ្យនោះ បានធ្វើបុណ្យមានទានជាដើម ។ លុះទ្រង់សោយព្រះទិវង្គតទៅក៏បានទៅកាន់ស្ថានសួគ៌ទេវលោកវិញ ។ ប្រាសាទនោះក៏ស្រុតលិចចុះទៅក្នុងទន្លេគង្គា ។ គេបានសាងទីក្រុងមួយ ឈ្មោះបយាគប្បតិដ្ឋាន ចំត្រង់ជណ្តើរប្រាសាទនោះ មានស្រុកមួយឈ្មោះកោដិគ្រាម នៅចំត្រង់កំពូលប្រាសាទ

នោះ ។ លុះដល់មកក្នុងពុទ្ធុប្បាទយើងនេះ នទ្យការទេវបុត្រជាកូននោះ ក៏ច្យុតអំពីទេវលោក មកកើតជាកូននៃកុដុម្ពិយសេដ្ឋី ក្នុងទីក្រុងកុដុម្ពិយៈ គេឲ្យឈ្មោះថា កុដុម្ពិកុមារ ។ គ្រានោះព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តជាតិយាវ័ន អាស្រ័យនៅទីក្រុងកុដុម្ពិយៈ ។ ពួកជនដែលនៅក្នុងទីក្រុង បាននាំគ្នាសាងមណ្ឌបសម្រាប់ធ្វើទាន ត្រង់កណ្ដាលទីក្រុង ហើយថ្វាយទានដ៏ច្រើន ។ ព្រះសាស្ដាទ្រង់ធ្វើភត្តកិច្ចរួចហើយទ្រង់ធ្វើអនុមោទនាក្នុងមណ្ឌបនោះ ។ កុដុម្ពិកុមារក៏ចូលទៅគាល់ព្រះសាស្ដា បានស្ដាប់ធម៌ក៏បានសម្រេចអរហត្តផល ហើយទៅកាន់វត្តជាមួយនឹងព្រះសាស្ដា ចូលបួសបានឧបសម្បទាជាភិក្ខុ ។ ព្រះសាស្ដាទ្រង់គង់ក្នុងវត្តជាតិយាវ័ននោះបាន ៧ ថ្ងៃ ទ្រង់ស្ដេចទៅកាន់ចារិកបានស្ដេចទៅដល់គោដិគ្រាម លុះធ្វើភត្តកិច្ចរួចហើយ ក៏ធ្វើអនុមោទនា ។ កុដុម្ពិត្ថេរ កាលដែលកំពុងធ្វើអនុមោទនា ក៏ចេញទៅខាងក្រៅស្រុក អង្គុយចូលឈានក្រោមម្លប់ឈើជិតកំពង់ទន្លេគង្គា ដោយគិតថា "នឹងក្រោកឡើងក្នុងពេលដែលព្រះសាស្ដាស្ដេចយាងមក" ។ កាលដែលមានព្រះថេរៈចាស់ៗនិមន្តមក មិនបានក្រោកឡើង លុះដល់ពេលដែលព្រះសាស្ដាស្ដេចយាងមកដល់ទើបក្រោកឡើងតែម្ដង ។ ពួកភិក្ខុជាបុថុជ្ជននាំគ្នាពោលទោសកុដុម្ពិត្ថេរ ថាមិនគោរពព្រះថេរៈចាស់ៗ ។ ព្រះសាស្ដាទ្រង់ស្ដេចទៅគង់លើទូកឃ្លាបមានព្រះបន្ទូលហៅកុដុម្ពិត្ថេរឲ្យឡើងជិះទូកជាមួយនឹងព្រះអង្គ កុដុម្ពិត្ថេរក៏ហោះឡើង ហើយចុះគង់លើទូក ១ ។ ព្រះសាស្ដាមានព្រះបន្ទូលសួរក្នុងពេលដែលទូកទៅដល់ពាក់កណ្ដាល

ចន្ទគន្ធ ថា នែខុជ្ជ ប្រាសាទដែលលោកធ្លាប់អាស្រ័យនៅ ក្នុងកាលដែលលោកសោយរាជ្យជាស្តេចឈ្មោះមហាបនាទនោះ តើនៅត្រង់កន្លែងណា ? ខុជ្ជិតេ្ថរក្រាបបង្គំទូលថា ប្រាសាទនោះលិចចុះទៅនៅត្រង់កន្លែងនេះ ។ លុះក្រាបបង្គំទូលហើយថ្វាយបង្គំព្រះសាស្តា រួចចុះទៅដោយកំឡាំងឫទ្ធិយកម្រាមដៃចុងកំពូលប្រាសាទហោះទៅឰដ៏អាកាសបង្ហាញឲ្យឃើញកល់គ្នាហើយលែងទៅវិញ ដើម្បីកាត់នូវសេចក្តីសង្ស័យរបស់បុថុជ្ជន ។ ប្រាសាទនោះក៏ធ្លាក់ទៅនៅត្រង់កន្លែងដដែលវិញ គ្មានអន្តរាយខូចខាតហូតដល់មកសព្វថ្ងៃនេះ ។ សួរថា ប្រាសាទនោះហេតុអ្វីបានជាមិនទាន់អន្តរាយ ? ឆ្លើយថា ដោយអានុភាពនៃនឡការទេវបុត្រជាបិតាពីដើម ។ ព្រោះថានឡការទេវបុត្រនោះនឹងបានជាព្រះរាជាចក្រពត្តិព្រះនាមសង្ខៈក្នុងអនាគត ប្រាសាទនោះនឹងផុសឡើងសំរាប់ព្រះរាជានោះ ; ដោយហេតុនេះ បានជាមិនទាន់អន្តរាយ ។

សំដែងរឿងនេះដើម្បីបញ្ជាក់អំពីកម្លាំងវិជ្ជាសិល្បសាស្ត្រដែលប្រកបដោយធម៌ បើបង្អោនទៅរកបុណ្យកុសលនឹងមានផលប្រយោជន៍ទៅក្នុងអនាគត នឹងចំរើនរុងរឿងក្នុងមនុស្សលោកនិងទេវលោក បានសំរេចព្រះនិព្វានក្នុងជាតិជាទីបំផុត ។

អាត្មាភាពសំដែងធម៌មកនេះ ក៏សូមបញ្ចប់ត្រឹមតែប៉ុណ្ណេះ ឯវំ ។

# បញ្ញាសជាតក

## ភាគទី ៣

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ
នៅសាលាបាលីជាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង
កាលដែលនៅជាភេទបព្វជិតពី ព.ស. ២៤៨៦, គ.ស. ១៩៤៣

(តមក)

---

## សុវណ្ណកុមារជាតក ទី ១៩

លោកអាចារ្យ ងី-សមិទ្ធ ក្រុមជំនុំព្រះត្រៃបិដក
ប្រែពីបាលី

(តចប់)

---

ព្រះសុវណ្ណកុមារពោធិសត្វ ត្រាស់សរសើរកល្យាណមិត្តដូច្នេះ, ហើយ កាលទ្រង់ទឹងតិះដៀលនូវបាបមិត្រ ទ្រង់ត្រាស់ថា បពិត្រព្រះរាជា, បុគ្គលពួកមួយ ពោលពាក្យសំដីល្អជា ពីរោះពិសា តែថាក្នុងដួងចិត្តមានគំនិតផ្សេង; កាលបើជនដទៃមានសេចក្ដីទុក្ខ, បុគ្គលនោះក៏ធ្វើអាការៈហាក់ដូចជាទឹងលះបង់ជីវិតខ្លួន, ប៉ុន្តែដល់សំឡឹងរកប្រយោជន៍ផ្ទាល់ខ្លួនមិនឃើញក៏ប្រែប្រួលជាធ្វើអាការៈផ្សេង លែងស្គាល់គ្នាឯងសោះ; បុគ្គលនោះ ឈ្មោះថាមនុស្សបាបក្រៃលែងជាងបុគ្គលបាបទាំងពួង; ក្នុងបច្ចុប្បន្នជាតិនេះ បុគ្គលនោះឥតមានសេចក្ដីចំរើនទេ, អ្នកប្រាជ្ញចាត់ជាមនុស្សកំសត់ក្រៃលែង, ដល់បរលោកនាយរមែងទៅរងទុក្ខធំ ក្នុងអវិចីឬលោហកុម្ភនរក អស់កាលជាអង្វែង ៗ ព្រោះហេតុនោះ បានជាអ្នកប្រាជ្ញសំដែងថា

យោ ធីរោ វិបនំ ករោ    ហទយេ បន អញ្ញថា
អញ្ញោ ទុក្ខសមុប្បន្នេ    បត្តោ កម្មេសុ កណ្ឋិតោ
សឆត្ថេ នេវ ជានាតិ    តស្ស ទោសំ កបិយតេ
សោ ប បាបតរោ បដ្ឋា    លោហកុម្ភឹ បតិយតេ ។

បុគ្គលខ្លះជាអ្នកមានប្រាជ្ញា ពោលវាចាផ្អែមត្រជាក់ហាក់ដូចជាមានសេចក្ដីមេត្រី, ប៉ុន្តែក្នុងដួងហឫទ័យមានគំនិតផ្សេង, បុគ្គលនោះឯង កាលជនដទៃបានសេចក្ដីទុក្ខធុរៈ ក៏សំដែងអាការៈហាក់ដូចជាមានសេចក្ដីខ្នះខ្នែង ជួយប្រឹងប្រែងក្នុងកិច្ចការធុរៈនោះ, លុះបុគ្គលនោះសំឡឹងឃើញថាមិនជាប្រយោជន៍ ក៏ប្រែបែរជាមិនស្គាល់គ្នាទៅវិញក៏មាន បែរជាពោលថ្កោលទោសជនអ្នកមានទុក្ខធុរៈនោះវិញក៏មាន, បុគ្គលនោះ ឈ្មោះថាមនុស្សបាបអាក្រក់ក្រៃលែង រមែងធ្លាក់ទៅក្នុងនរកលោហកុម្ភី ក្នុងកាលជាខាងក្រោយពុំខាន, បពិត្រមហារាជ, ព្រោះហេតុនោះ សូមព្រះអង្គពិចារណាមើលនូវជនទាំងពីរពួកនោះ ហើយសូមប្រាប់ខ្ញុំតាមសេចក្ដីពិតរបស់ខ្លួន, កុំប្រាប់តាមហេតុដែលប្រកបដោយមានះ នឹងហេតុដែលប្រកបដោយភ័យឡើយ ។

ព្រះបាទកេដេសុរាជ ជាម្ចាស់ដែនសីហឡៈ ទ្រង់រីករាយសប្បាយក្នុងព្រះរាជហឫទ័យ ទូលតបសេចក្ដីថា សាធុសាធុ-

មហារាជ បពិត្រមហារាជ, ពិរោះណាស់! ល្អណាស់! ព្រះរាជឱង្ការរបស់ព្រះអង្គទាំងអស់នេះ សុទ្ធតែជាសុភាសិត, ធម៌ដ៏ខ្ពង់ខ្ពស់យ៉ាងនេះ ឥតមាននរណាដែលឮ ដែលបេះទៀយ; ខ្ញុំសូមថ្វាយជីវិត ដួងហឫទ័យ ទាំងសេចក្ដីស្រឡាញ់ ព្រមទាំងរាជសម្បត្តិទាំងអស់ចំពោះព្រះអង្គ; បពិត្រព្រះអង្គជាអរិមទ្ទនរាជ, សូមព្រះអង្គទ្រង់ទទួលយកតាមសព្វព្រះរាជហឫទ័យចុះ ។

ព្រះបរមពោធិសត្វ ទ្រង់ត្រាស់ថា បើពិតជាដូច្នោះមែន, សូមព្រះអង្គទៅថ្វាយបង្គំព្រះរាជមាតាបិតារបស់ខ្ញុំ ជាមួយនឹងខ្ញុំចុះ ។ ព្រះបាទកដេស្សុរះទទួលព្រមថា បពិត្រមហារាជ, ល្អហើយ ស្រួលហើយ, ប៉ុន្តែ សូមព្រះអង្គរង់ចាំ ទំរាំខ្ញុំចាត់ចែងដំណើររួចស្រេចសិន ។ ព្រះពោធិសត្វត្រាស់ថា អញ្ជើញទ្រង់ចាត់ចែងចុះ មហារាជ ។

លំដាប់នោះ ព្រះបាទកដេស្សុររាជ ព្រះចៅដែនសីហឡៈ កាលបើបានព្រះរាជានុញ្ញាតដូច្នោះហើយ ក៏ថ្វាយបង្គំលាព្រះពោធិសត្វ មកកាន់ព្រះរាជនិវេសនដ្ឋាន ទ្រង់ចាត់ចែង ជ្រើសរើសរកយករាជនារីស្រីក្រមុំព្រហ្មចារី បានចំនួន ១ ហ្មឺនប្រាំបីពាន់ មានសុដន់ក្បំក្រពុំដូចផ្កាបទុមរ័ត្តសុវណ្ណ មានវង់ភក្ត្រផូរផង់ដូចអង្គព្រះចន្ទ្រ ក្នុងថ្ងៃបណ្ណរសី មានសិរីដូចស្រីទេពអប្សរ មានបាទដៃបាទជើងសម្បុរល្បឿងស្រស់ល្អដូចជ្រលក់ទឹកល័ក្ត មានទ្រគាកសាយត្រសុំសំណុំខ្លួនស្មើនល្អដូចរូបចម្លាក់ ដែលគេឆ្លាក់ដោយជំបារមាស មានសរីរប្រាសចាកទោស ៦

ប្រការ គឺមិនឆាត់ពេក មិនស្គមពេក មិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនសពេក ជាទីគួរត្រេកឡេកគយគន់នៃជននានា មានសំដីពីរោះពិសាផ្អែមល្ហែមត្រជាក់ មានអាការៈហាក់ដូចញញឹមស្រស់ប្រិមជានិច្ច; កដកញ្ញាទីមួយៗនោះ មានរាសីស្រីបំរើ, មានរូបល្អស្រស់ប្រសើរ ១០ នាក់ៗប្រដាប់ដោយគ្រឿងអាភរណៈ ល្អស្រស់គ្រប់ប្រការ; ស្តេចបញ្ជូនឲ្យទៅបំរើព្រះបាទសុវណ្ណកុមារ នៅគ្រប់ត្រាតាំងយប់តាំងថ្ងៃ ។ តមកព្រះបាទកដេសុរ ទ្រង់ត្រាស់បង្គាប់ សេនាគុត្តអាមាត្យជាមហាអាមាត្យ អ្នកគ្រប់គ្រងចតុរង្គសេនា, ឲ្យអ្នករៀបពលសកលយោធាទាំង ៤ ពួកឲ្យគ្រប់គ្រាន់ ត្រូវឲ្យពួកយោធាទាំងនោះតែងកាយតាមថ្នាក់តាមជាន់ផ្សេងៗពីគ្នា ពួកមួយឲ្យតែងកាយពណ៌ក្រហមមានមុខខៀវ, ពួកមួយឲ្យតែងកាយពណ៌ខ្មៅមានមុខស, ពួកមួយឲ្យតែងកាយបែបជានាគ, ពួកមួយឲ្យតែងកាយបែបជាគ្រុឌ ពួកមួយឲ្យតែងកាយបែបជាខ្លា, ជាគោឧសភ ជាដំរី ជាសេះ ជារាជសីហ៍ ជាក្របី ទីងជាសត្វដទៃៗឲ្យមានគ្រប់ប្រការ ដែលកាន់គ្រឿងសស្ត្រាគ្រប់គ្នាទាំងអស់, ឲ្យពាក់គ្រឿងក្រោះប្រដាប់ដោយអាវុធគ្រឿងយុទ្ធាការ; ពួកសេនាបតីទាំងឡាយ ត្រូវប្រដាប់កាយគ្រឿងអម្ពរតសុវណ្ណ ដែលកាន់កូនសរបំពុះទ្រូងទឹងកាំភ្លើងខ្សឹងជិះដំរី; ពួកសេនាហត្ថី ត្រូវឲ្យមានគ្រឿងសំលៀកបំពាក់ថ្មីៗរៀងទាមលើដំរីរាជកុញ្ជរ; ពួកសេនាអស្សតរ ត្រូវឲ្យតែងកាយយ៉ាងល្អៗ រៀងជិះលើខ្នងពាជី; ពួកសេនារថ ត្រូវឲ្យមានគ្រឿងសម្រាំងយ៉ាងថ្មីៗសសុទ្ធ; ពួករាជបុត្រ ក៏ត្រូវឲ្យពាក់

តែងកាយដោយសំពត់នឹងគ្រឿងអម្ពររ័ត្នសុវណ្ណ ដៃកាន់អាវុធផ្សេងៗ ទីទៃៗ ឡើងជិះលើដំរីរាជគជសារ, ពួកអ្នកភ្លេងត្រូវឲ្យលេងតាមបែបតាមបទ កុំឲ្យភ្លាត់ចង្វាក់. ក្លងយ៉ៃក្លូដផ្ទាក ត្រូវឲ្យគោះឲ្យឮទូងកំទរឲ្យខ្ទរខ្ទា. ចូរអ្នកឯងមុំម្នា រៀបទ័ពដំរីឲ្យបាន ១ ម៉ឺន, ទ័ពសេះ ១ ម៉ឺន, ទ័ពរថ ១ ម៉ឺន, ហើយអ្នកទាំងអស់គ្នានោះ ចូលទៅហែហមព្រះសុវណ្ណ-កុមារជាមួយនឹងខ្ញុំ ដើម្បីទៅថ្វាយបង្គំព្រះបរមរាជា ។

ព្រះបាទកជេសុរៈ ទ្រង់ចាត់ឲ្យរៀបដំណើរ អស់វេលា ១ ខែ, កាលបើទ្រង់ពិនិត្យ ឃើញថាការងារទាំងអស់ មានរបៀបរៀបរយស្រួលហើយ ទើបទ្រង់ទៅក្រាបបង្គំទូលព្រះពោធិសត្វ ។

គ្រានោះព្រះពោធិសត្វ ទ្រង់មានរាជកញ្ញា ១ ម៉ឺនប្រាំបីពាន់ ប្រ-ដាប់គ្រប់គ្រាន់ដោយគ្រឿងអម្ពរកស្ត្រា ល្អដូចស្រីទេពកញ្ញា មូលមកក្រៀបក្រា ហែហមព្រះអង្គ, ទ្រង់ស្ដេចទៅកណ្ដាលពួករាជកញ្ញា ល្អដូចអង្គសម្ដេចព្រះអម្រិន្ទ្រា គ្រាដែលស្ដេចទៅក្នុងកណ្ដាលពួកទេពអប្សររាជកញ្ញាពួកខ្លះកាន់ចាមរ ពួកខ្លះកាន់វាលវិជនី ពួកខ្លះអញ្ជើញព្រះសុវណ្ណភាជនៈ ពានព្រះស្រី ថូងព្រះឧស្ឍ ជាពួកៗ; បន្ទាប់ពីរាជ-កញ្ញានោះមក មានពួកសេនាកំឡោះជំទង់ ទទ្រង់គ្រឿងសំពត់អលង្ការរចនាដោយមាស មានដាវមាស ព្រះខ័នមាស គ្រឿងសស្ត្រាមាស ខែលមាស តម្រៀបគ្នាពេញពាស ហែហមព្រះអង្គ ។ បន្ទាប់ពីពួកសេនាកំឡោះនោះមក មានពួកពលយោធា ជាមនុស្សកណ្ដាលក្នុងមជ្ឈិមវ័យ មានរូបធំសម្បើមល្អប្រពៃ ដៃកាន់លំពែងមាស ព្រះខ័នមាស

ខ្ទះគាន់ដាវប្រាក់ លំពែងប្រាក់ ព្រះច័ន្ទប្រាក់ ។ តពីនោះមក មានពួកសេនាដំរី, តពីសេនាដំរីមក មានពួកសេនាសេះ, តពីសេនាសេះមក មានពួកសេនារថ, តពីសេនារថមក មានពួកសេនាថើរជើង, តពីសេនាថើរជើងមក មានពួកអ្នកខ្វាំង១ក្រៀវក្លា ហត្ថាគាន់ធ្នូ ដើរតម្រៀបជាគូ១ កម្រាស់ ៣ យោជន៍ពីខាងក្រោយ ៣ យោជន៍ពីខាងឆ្វេង ៣ យោជន៍ពីខាងស្ដាំ ។ ព្រះបរមពោធិសត្វ ទ្រង់មានសេនាហែមកែមជាបរិវារ ៣ យោជន៍ជុំវិញដូច្នេះហើយ • ទ្រង់ឡើងគង់លើខ្នងដំរីរាជគជេន្ទ្រ ប្រកបដោយលក្ខណ: ល្អបាក់ដូចជារូបគំនូរ ទ្រង់ចេញទៅកងពេលមាននក្ខត្តឫក្សល្អ ។ ចំណែកខាងព្រះបាទកដេសុរាជ ក៏មានបរិវារហែហម ចេញទៅជាលំដាប់ខាងក្រោយបំផុត ។ ព្រះបរមពោធិសត្វមានពួកសេនាដំក្រៀវក្លា ហែមកែមជាបរិវារ ទ្រង់ស្ដេចទៅក្នុងកណ្ដាលពួកសេនាល្អល្អះថ្លៃថ្លាដូចជាសក្កទេវរាជ ដែលគង់លើដំរីឯរាវណ្ណ មានពួកទេវតាទាំងពាន់ហែមកែមជាបរិវារ, ពុំនោះសោតទេ ដូចជាគំមេរុរាជ ដែលល្អចំពោងចំពោចទៅក្នុងកណ្ដាលកំសត្តបរិភណ្ឌ ទីងសមុទ្រសីទន្តរ។ សូរសំពួដំរី សូរសំពួសេះ សូរសំពួរថ សូរសំពួពល សូរសំពួតូរ្យតន្ត្រី ព្លួខ្ទរ បាក់ដូចជាសន្ទឹកខ្យល់ពែងក្ដី ឬសន្ទឹកក្រោមទ្រទ្រសែតដែនដីវ ឬសន្ទឹករទ្ទះអសទីដែលកំរើកពីថ្ងៃចក្រពាឡ ដាលលាន់ពួរខ្ទួរទៅលើមេឃ បាក់ដូចជាទឹងដំបែកកំបក្រពាឡ, ឯបុទ្ធិអំណាចពលសេនាទាំងនោះ ក៏ខ្វាំងចំឡែកប្លែកត្រិកាល ហាក់ដូចជាទឹងកំទេចផែនប្រឹថពីទាំងមូល ដូច្នេះឯង ។ ព្រះពោធិសត្វទ្រង់គង់លើខ្នងដំរីសេតមង្គល ទ្រង់ព្រះរាជដំណើរ

ទៅដល់មហាសមុទ្រ ដោយសេចក្ដីរីករាយសប្បាយព្រះរាជហឫទ័យជាទីបំផុត ទើបព្រះបរមម្ពុជឲ្យបោះកងទ័ពសំចតនៅក្នុងទីនោះអស់វេលាប្រាំពីរថ្ងៃ ដើម្បីឲ្យពួកពលសកលយោធាលេងល្បែងផ្សេងៗ តាមប្រាថ្នា ។

សីហឡរាជា រីឯព្រះបាទកលេសុរាជ ព្រះចៅដែនសីហឡៈ ក៏ចូលទៅក្រាបបង្គំគាល់ ក្នុងទីចំពោះព្រះភក្ត្រ ហើយក្រាបបង្គំទូលតឿនថា បពិត្រព្រះរាជសម្ភារ, ស្អែកនេះជាវេលាមាននក្ខត្តឫក្សល្អ គួរព្រះអង្គនាំពួកពលនិករ ចុះឆ្លងមហាសមុទ្រសាគរទៅបានដោយស្រួល ។ ព្រះពោធិសត្វក៏ទ្រង់ទទួលថា សាធុមហារាជល្អមែនហើយមហារាជ, ទើបទ្រង់ប្រាប់ដល់មេក្រុមពួកសេនា ។ គ្រានោះសមុទ្ទទេវតាទាំងស្ដេចនាគទាំងឡាយក៏និម្មិតប្រាសាទរត្នសម្រាប់ថ្វាយព្រះមហាសត្វនៅលើសុវណ្ណ-នាវ; ព្រះរាជាក៏ទ្រង់ឡើងគង់លើប្រាសាទនោះ ជាមួយនឹងស្រីស្នំក្រមការ ។ ព្រះបាទសីហឡរាជ នឹងពួកពលសកលយោធា ក៏ស្រែកថ្វាយជ័យ ៣ ដង ហើយក៏ចុះត្រសងឆ្លងទៅកាន់នាវ របស់ខ្លួនគ្រប់ៗគ្នា ។ ពួកសមុទ្ទទេវតា ក៏បាត់ការថែទាំរក្សាមហានាវទាំងអស់ ពុំឲ្យមានទាស់ មានសេចក្ដីអន្តរាយឡើយ; មារុតទេវតាទាំងឡាយ ក៏បញ្ចេញព្រះពាយ ផ្សាយមករំភើយៗ ហើយសព្វកាយា នាំអស់សំពៅកេត្រាឲ្យលឿនដឿយ ឥតឲ្យយឺងយ៉ាងឡើយ ។ សមុទ្ទទេវតា តែងនាំភោជនាហារ មានទិព្វរសឧត្ដមថ្លៃថ្លា មកថ្វាយព្រះរាជា លៀងអស់ពួកពលសកលយោធា រាល់ទិវារាត្រី ។ ពួកនាងសមុទ្ទកញ្ញាក៏តែងកាយាស្រស់ថ្លាប្រពៃ ដៃកាន់ទិព្វមាលា ផ្សាយក្លិនសុគន្ធា មក

ថ្វាយព្រះរាជា ទឹងចែកជូនអស់ពួកពល ។ ពួកសេនាទាំងអស់ក៏ឥត រវល់ បានបរិភោគស្កប់ស្កល់សុទ្ធតែភោជនដ៏ថ្លៃថ្លា អ្នកណាចូលចិត្តស្រា ក៏ក្រេបផឹកតាមប្រាថ្នា ឥតមានខ្វះខាត, ជនទាំងអស់សុទ្ធតែតែងខ្លួន យ៉ាងស្អាត ស្អិតស្អាងដោយគ្រឿងគន្ធជាតិសៀតក្លួងមាលា ខ្លះរាំ ខ្លះ ច្រៀង ខ្លះសើច ខ្លះទះហត្ថា លេងកំសាន្តទៀវទារ លើសំពៅកេត្រា ឥតមានក្តឹក ៗ

ចំណែកខាងព្រះមហាសត្វ ទ្រង់សោយទិព្វសម្បត្តិក្នុងមហាសមុទ្រ មានសុទ្ធតែរាជទេពី ជាស្រីមានរូបសាំ ល្អទុកាស មានយានយាស គួរជាទីអភិរម្យ ទ្រង់មានលំនាំហាក់ដូចជាដួងព្រះចន្ទ មានពន្លឺភ្លឺត្រចះ ឋិតនៅក្នុងទីស្ថានស្រឡះ នាកណ្តាលហ្វូងតារា ឬថាដូចជាសុវណ្ណ-ហង្ស នៅត្រង់កណ្តាលហ្វូងហង្សជាបរិវារ, ក្សត្រាទ្រង់ឆ្លងសមុទ្រផុត ប្រាំពីរថ្ងៃទើបដល់ត្រើយនាយ ហើយទ្រង់បញ្ជូនរាជទូត ឲ្យទៅក្រាប បង្គំទូលព្រះវររាជមាតាបិតា ។ គ្រានោះសម្តេចព្រះបរមរាជា ជាព្រះ វររាជបិតា ទ្រង់ចាត់ការឲ្យតែងព្រះនគរបវររាជដ្ឋាន មានទំហំ ១២ យោជន៍ រួចឲ្យតែងរាជមគ្គាផ្លូវថ្នល់ដែលចុះទៅមាត់សមុទ្រ ហើយទើប ព្រះបរមនុជ ព្រមទាំងព្រះអគ្គជាយាមានពួករាជបរិស័ទ្យហោមរោមជាយស-បរិវារ ទ្រង់ស្តេចយាត្រាដោយព្រះរាជដំណើរប្រកបដោយមហិស្សរិយ-យស ទ្រង់ចុះទៅទទួលព្រះពោធិសត្វ ជាព្រះរាជបុត្របម្បួន ហែ ត្រសងចូលមកកាន់ព្រះរាជធានី ។ ព្រះពោធិសត្វ ទ្រង់ក្រាបបង្គំថ្វាយ ស្តេចនេះដេសុវរាជទឹងពួកពល ព្រមទាំងមាសប្រាក់ គ្រឿងរតនៈសព្វ

គ្រប់ប្រការ ចំពោះព្រះវររាជមាតាបិតាដោយសេចក្ដីគោរព ។ ព្រះវររាជមាតាបិតា ទ្រង់ទទួលដោយសេចក្ដីជ្រះថ្លា ហើយទ្រង់ព្រះរាជ-ទានពរសព្ទសាធុការ ចំពោះព្រះពោធិសត្វថា

ចិរំ ជីវំ តុវំ បុត្ត មា វិយោគោ បិយេហិ ច
ឱប្បុតុ តំ សង្កប្បោ បត្តោ ចន្ទុស្សោ យថា ។

ហៃបុត្រសម្លាញ់ ជាទីពេញចិត្តមាតាបិតា, សូមអ្នកមានជន្មាយុយឺនយូរ អស់កាលជាអង្វែងវែងឆ្ងាយ, សូមកុំឲ្យរបស់ទាំងឡាយដែលជាទីស្រឡាញ់ពេញចិត្ត ព្រាត់ខ្ចាត់ទៅឡើយ, តម្រិះគំនិតដែលអ្នករិះគិតឡើងហើយ សូមឲ្យបានសម្រេចយ៉ាងឆាប់, សូមឲ្យអ្នកបានសេចក្ដីចំរុងរុងរឿងដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត ។

ព្រះវររាជមាតាបិតា ទ្រង់ប្រទានពរសព្ទសាធុការយ៉ាងនេះហើយ ទើបទ្រង់ព្រះរាជទានរាជសម្បត្តិ ឲ្យព្រះបរមពោធិសត្វគ្រប់គ្រងព្រះរាជវង្សរៀងទៅ ។

គ្រានោះស្ដេចទាំងអស់ក្នុងសកលជម្ពូទ្វីប បានជ្រាបរាជានុភាពរបស់ព្រះមហាសត្វ ក៏មានសេចក្ដីខ្លាចស្ញប់ស្ញែងកោតក្រែងគ្រប់ៗព្រះអង្គ ទ្រង់ផ្ចិតផ្ចង់ជ្រើសរើសរកគ្រឿងបណ្ណាការ ដ៏ឧត្តមថ្លៃថ្លាទាំងរយទាំងពាន់ នាំមកស្រុកចូលថ្វាយបង្គំព្រះមហាសត្វ ហើយថ្វាយគ្រឿងបណ្ណាការទាំងអស់នោះចំពោះព្រះអង្គ ។ ថ្ងៃមួយ ព្រះរាជាទាំងអស់ នាំគ្នាចូលទៅបង្គំគាល់ ប្រជុំសម្រេចការតាំងព្រះពោធិសត្វជាអគ្គឯករាជ ប្រគល់

អំណាចឲ្យជាឥស្សរក្នុងសកលជម្ពូទ្វីប ហើយថ្វាយទាំងដែនអាណាខេត្ត របស់ខ្លួនព្រមទាំងខ្លួនចំពោះព្រះពោធិសត្វ បុះយ៉មតាំងខ្លួនជាអ្នកប្រតិបត្តិ ដោយសេចក្ដីគោរព ។ ព្រះពោធិសត្វក៏ទ្រង់ព្រះរាជទានគ្រឿងជប់លៀងមានបណ្ណាការជាដើមផង គ្រឿងអម្ពរក្រាលល្អផ្ទុកៗជាអនេកប្រការផង ចំពោះពួកព្រះរាជានឹងពួកពលយោធាទាំងអស់ តាមសមគួរដល់ឋានៈនៃអ្នកដែលត្រូវទទួល, ដោយហោចទៅសូម្បីតែអ្នកឃ្វាលដំរីក៏ព្រះបក្រីទ្រង់ព្រះរាជទានប្រាក់មាសជាច្រើនគ្រប់ៗគ្នាដែរ ។ ក្នុងទីក្រុងពារាណសីទាំងមូល ដែលមានទំហំ ១២ យោជន៍ ឮតែសូរស័ព្ទរងំដែលគេប្រគំដោយភ្លេងតូរ្យតន្ត្រី នឹងសូរសំឡេងមនុស្សប្រុសស្រីច្រៀងរាំឆ្លើយឆ្លងគ្នា, អស់ទាំងល្បែងកីឡាគ្រប់ប្រការ ក៏មានឥតសល់ចន្លោះ, មហាជនក្នុងដែនទាំងអស់ ក៏មានសេចក្ដីសុខក្សេមក្សាន្ត ឥតមានអាពាធឥតមានហេតុមិនជាទីពេញចិត្តបន្តិចបន្តួចសោះ ដោយអំណាចរាជតេជៈព្រះមហាបុរស ដែលផ្សាយទៅប្រកបដោយធម៌ ។

ថ្ងៃមួយ ពួកព្រះរាជាទាំងអស់ ចូលទៅទូនព្រះសិរីគំនាប់ ផ្គង់អញ្ជលីថ្វាយបង្គំ ចំពោះព្រះបរមពោធិសត្វ ដែលទ្រង់គង់លើរតនបល្ល័ង្ក ហើយថ្លែងសេចក្ដីសរសើរព្រះពោធិសត្វថា

យើងខ្ញុំព្រះអង្គទាំងអស់គ្នា បានឃើញបុញ្ញសិរី ដែល
ផ្សាយទៅសព្វផ្ទៃផែនដី ក៏សំគាល់ព្រះអង្គថាជាទេវរាជ ជា
ស្ដេចទេវតាមានអំណាច នៅក្នុងឋានត្រៃត្រិង្ស ដែលពេញ
ដោយទេវសិរីដ៏ជាទិព្វ, បុគ្គលដែលមានជ័យជំនះឈ្នះគេ

ទាំងពាន់ប្រទេស មានតេជះដ៏វិសេស ផ្សាយទៅសព្វផ្ទៃប្រថពី ដូចសម្តេចព្រះភូមិជាម្ចាស់ជីវិតអង្គនេះ ឥតមាននរណាដែលឃើញដែលឮទេ តាំងពីមុនៗរៀងមក ។

ព្រះពោធិសត្វ ទ្រង់ឃាត់ស្តេចទាំងនោះថា

ខ្ញុំជាស្តេចធម្មតា មិនមែនជាព្រះឥន្ទ្រទេ ខ្ញុំមិនមែនជាទេវតា ដែលមានឫទ្ធិច្រើនទេ, អានុភាពធំ និងសេចក្តីសុខយ៉ាងនេះ ប្រព្រឹត្តទៅបានដោយកម្លាំងធម៌ទេតើ ។

ទើបស្តេចទាំងនោះក្រាបបង្គំទូលសួរ, ព្រះពោធិសត្វថា ព្រះអង្គទ្រង់មានសេចក្តីរុងរឿង ដូចជាព្រះអាទិត្យដែលកំចាត់ងងឹតឲ្យសាបសូន្យទៅដោយរស្មីតែដោយបានបំពេញបុញ្ញកម្មដូចម្តេច? ។

ព្រះពោធិសត្វទ្រង់មានជាតិស្សរញ្ញាណ ទ្រង់ប្រកាសបុញ្ញកម្មដែលព្រះអង្គបានធ្វើហើយថា

សូមព្រះអង្គទាំងឡាយចាំស្តាប់ពាក្យខ្ញុំ, ខ្ញុំបាននូវសិរីសម្បត្តិប្រាកដដូច្នេះ ដោយបានធ្វើនូវបុញ្ញកម្មឯណា, បុញ្ញកម្មនោះគឺពីដើម ខ្ញុំជាអ្នកពោលនូវពាក្យគោរព, លះបង់នូវវេរទាំងប្រាំប្រការ, ឥតមានចិត្តជាប់ចំពាក់ដោយសេចក្តីប្រស្រាច្រណែនទិន្នាដល់នរណាៗ ឡើយ, មិនមានសេចក្តីក្រោធ មិនខ្វល់ខ្វាយក្នុងការឥតប្រយោជន៍, ខ្ញុំដល់នូវសេចក្តីសុខប្រាកដដូច្នេះ ដោយបានធ្វើអំពើល្អដូច្នោះឯង ។

ព្រះបរមពោធិសត្វ ទ្រង់ប្រកាសបុព្វចរិតរបស់ព្រះអង្គដូច្នេះហើយ ទើបទ្រង់ប្រទានឱវាទតទៅទៀតថា

សប្បុរសទាំងឡាយអ្នកប្រាថ្នានូវសួស្តីនិងជ័យជំនះក្នុងលោកនេះនិងក្នុងលោកខាងនាយ ស៊ូតែលះបង់ជីវិត មិនត្រូវលះបង់ការល្អឡើយ, មិនត្រូវសម្លាប់សត្វ, មិនត្រូវលួចលាក់ឆបំបាត់ទ្រព្យអ្នកដទៃ, មិនត្រូវប្រព្រឹត្តមោះពុំគាប់នឹងបុរសស្ត្រីដែលមិនមែនជាស្វាមីភរិយារបស់ខ្លួន, មិនត្រូវនិយាយកុហក, ត្រូវវៀរបង់ចាកការបរិភោគគ្រឿងស្រវឹង, ជនណាអាចធ្វើយ៉ាងនេះបាន, ជននោះរមែងបាននូវសួស្តី និងជ័យជំនះដូចសេចក្តីប្រាថ្នា បពិត្រក្សត្រទាំងឡាយបុគ្គលត្រូវតែពិចារណាឲ្យស្រេច សឹមធ្វើ, មិនត្រូវធ្វើដោយឥតពិចារណាឡើយ, យសនិងកិត្តិស័ព្ទល្អ រមែងមានកុះករល្បីខ្ចាយខ្ចរបំពោះព្រះរាជា ដោយសារតែមានសេចក្តីពិចារណា, សូមព្រះអង្គទាំងឡាយរក្សាអាណាប្រជាជន ឲ្យត្រឹមត្រូវតាមរាជធម៌, សូមព្រះអង្គទាំងឡាយព្រះរាជទានព្រះរាជទ្រព្យឲ្យទៅជាទានរាល់ៗថ្ងៃ, សន្សំសេចក្តីល្អឲ្យរឿយៗ, កុំលុះអំណាចសេចក្តីកំណាញ់ឡើយ ។

ព្រះរាជាគ្រប់ព្រះអង្គ ទ្រង់ព្រះសវនាការ ស្តាប់ធម៌ទេសនាព្រះពោធិសត្វហើយ ទ្រង់មានព្រះរាជហឫទ័យរីករាយ ទើបក្រាបបង្គំទូលព្រះរាជឱង្ការថា

បពិត្រព្រះរាជសម្ភារ, យើងខ្ញុំព្រះអង្គទាំងអស់គ្នា សូមធ្វើតាមព្រះរាជឱង្ការ ដែលព្រះករុណាទ្រង់ត្រាស់រំលឹកទាំងប៉ុន្មាននោះ ពុំហ៊ានប្រព្រឹត្តកន្លង, ព្រះអង្គជាសាស្តា ជាគ្រូអាចារ្យរបស់យើងខ្ញុំព្រះអង្គទាំងឡាយ ញុំាងយើងខ្ញុំព្រះអង្គទាំងឡាយ ឲ្យដល់នូវសុគតិភព ។

ព្រះបរមពោធិសត្វ ទ្រង់ព្រះរាជទានឱវាទយ៉ាងនេះហើយ ទើបទ្រង់បញ្ជូនព្រះបាទកេជសុរារាជ និងព្រះរាជាទាំងនោះ ឲ្យត្រឡប់ទៅកាន់នគររបស់ខ្លួន ជាមួយនឹងពួកពលរបស់ខ្លួនគ្រប់ចំនួនទាំងអស់ ។ ព្រះរាជាទាំងឡាយនោះមានព្រះរាជហឫទ័យត្រេកអរជាសោមនស្ស ទើបថ្លែងសេចក្តីសរសើរព្រះមហាបុរសថា

ដំណើរដែលយើងទាំងឡាយបានមកកើតជាមនុស្សក្នុងជាតិនេះប្រកបដោយផលល្អណាស់, ទាំងជីវិតរបស់យើងក៏ជាជីវិតប្រកបដោយផលល្អដែរ ដោយហេតុតែបានកើតនៅក្នុងអំណាចនៃព្រះរាជាដែលប្រកបដោយធម្មតេជះ ។

ព្រះរាជាទាំងនោះសរសើរដូច្នោះហើយ ក៏នាំពួកសេនាត្រឡប់ទៅកាន់នគររបស់អាត្មាទីទៃៗរៀងខ្លួន ។ ចំណែកខាងព្រះបរមពោធិសត្វ ទ្រង់គ្រប់គ្រងអាណាប្រជារាស្ត្រក្នុងជម្ពូទ្វីបទាំងមូលដោយមិនប្រើអាជ្ញា មិនប្រើគ្រឿងសស្ត្រា ។ ទ្រង់ចាត់ឲ្យសាងសាលាទាន៦ខ្នង គឺនៅទៀបទ្វារនគរទាំងបួន ៤ ខ្នង ត្រង់ពាក់កណ្តាលនគរ ១ ខ្នង ទៀបទ្វារព្រះរាជនិវេសន៍ ១ ខ្នង, ទ្រង់ចំណាយព្រះរាជទ្រព្យ ១ សែនកហាបណៈ

ឲ្យទានដល់ស្មូមយាចកអ្នកកំសត់ទុគ៌តរាល់ ៗ ថ្ងៃដរាបដល់អស់ព្រះជន្មាយុ ទ្រង់សោយព្រះទិវង្គតរលត់ព្រះជន្មទៅ ទ្រង់បានទៅកើតក្នុងឋានទេវលោក ជាមួយនឹងបរិវារទាំងឡាយ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ប្រទានឱវាទដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ជនណាមួយ ពោះបីភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី បើចង់បានជោគជ័យ សេចក្តីសម្រេច សេចក្តីសុខ គ្រប់ទីជម្បូនទាំងអស់, ជននោះត្រូវបូជាគ្រូអាចារ្យមាតាបិតា ដោយវត្ថុដ៏ប្រសើរ ហើយបំរើដរាបដល់អស់ជីវិត, មិនត្រូវប្រព្រឹត្តកន្លងសាសនា, មិនត្រូវធ្វើបញ្ចវេរ ទើបបាននូវជោគជ័យ សេចក្តីសម្រេច សេចក្តីសុខសមគួរដល់សេចក្តីប្រាថ្នា ដូចជាព្រះសុវណ្ណកុមារនេះឯង ។

សត្ថា រីអង្គសម្តេចព្រះបរមសព្វជ្ញសាស្តាចារ្យ ទ្រង់នាំព្រះធម្មទេសនានេះមកសំដែងសព្វគ្រប់ហើយ ទ្រង់ប្រកាសនូវអរិយសច្ចទាំង ៤ ប្រការ ចប់ស្រេចហើយ ភិក្ខុទាំងអស់ក៏បានសម្រេចមគ្គផលទីទៃ ៗ មានសោតាបត្តិផលជាដើម; ទើបទ្រង់ប្រជុំជាតកថា ព្រះបាទកដេសុរាជក្នុងកាលនោះ លុះបរលោកមក បានជាសារីបុត្ត, ព្រះវររាជមាតានៃព្រះសុវណ្ណកុមារ បានជាព្រះនាងមហាមាយាទេវី, ព្រះវររាជបិតាបានជាព្រះបាទសុទ្ធោទន, ព្រះឥន្ទ្រ បានជាអនុរុទ្ធ, ព្រះសុវណ្ណកុមារ គឺជាតួអង្គព្រះតថាគតជាសាស្តាចារ្យនេះឯង ដែលទ្រង់សំដែងធម្មប្រកៀបគល់ពោធិព្រឹក្ស; អ្នកទាំងឡាយចូរចាំទុកនូវជាតកយ៉ាងនេះចុះ ។

ចប់ សុវណ្ណកុមារជាតក ទី ១៥ តែប៉ុណ្ណេះ ។

## ផ្នែកអក្សរសាស្ត្រ

# ការទស្សនានិម្មាបនកម្មខ្មែរ

(Regard sur l'Architecture Khmère)

និពន្ធដោយលោក ហង់រី - ម៉ាក្សាល់, នាយកិត្តិយសធ្វើការនៅផ្នែក
ស្រាវជ្រាវបុរាណវត្ថុនៃសាលាបារាំងសែសខាងបូព៌ាប្រទេស
អ្នកប្រែប្រៀង : ញ៉ែម - ទិម
លេខាធិការនៅពុទ្ធសាសនបណ្ឌិត្យ

ខ្ញុំមានសេចក្តីពេញចិត្ត នឹងពោលលាតបង្ហាញនូវទស្សនាការមួយយ៉ាងសង្ខេបអំពីនិម្មាបនកម្មខ្មែរទូទៅ ។ ពាក្យប៉ុន្មានម៉ាត់នេះ មានធ្វើឲ្យពួកបស្ចិមទិសភ្ញាក់ផ្អើលជាក្រៃលែង ។

ប្រាសាទខ្មែរទាំងឡាយ បើគេក្រឡេកមើលមួយភ្លែត, គេស្មានហាក់ដូចជាគំនរថ្មស្រុតបាក់បែក, តាស់តែត្រង់ជុំសិលាទាំងនោះ សុទ្ធតែមានរូបភាពផ្សេង ៗ គ្នាទាំងអស់ដូចជាថែវ (galerie), . ពេងទេព្តា (archipelle de cloître), កំពូលប្រាសាទជាច្រើនដែលកន្លែងខ្លះមានបរិវេណតូចល្មម ។ ដូច្នេះ ពួកអ្នកទៅមើលប្រាសាទអង្គរ, បើតាមពៀរ - ឡូទី ដំណាល, ត្រូវដើរយ៉ាងរួសរាន់តាមអ្នកមគ្គុទ្ទេសក៍ ដើម្បីមើលឲ្យបានសព្វគ្រប់កុំឲ្យយប់ទាន់, ស្ពីថែវមួយទៅថែវមួយ, ឆ្លងកាត់ព្រះលានជាច្រើន, ហើយត្រូវឡើងយ៉ាងទំទោះលើខឿនខ្ពស់ ៗ លើដំបូលតាមជណ្តើរ ៗ ចោត ៗ ហើយបាក់បែកខ្លះផង ជាហេតុឲ្យមានការលំ-

បាកជាច្រើនដល់ពេលចុះមកវិញ  ចំពោះជនណាដែលមានកើតវិលមុខប្រចាំនៅនឹងប្រាណ ។

កាលដែលខ្ញុំពោលដូច្នេះ មានជនខ្លះឆ្ងល់សួរខ្ញុំថា ចុះបើមានការលំបាកដូច្នេះ តើមហាក្សត្រិយ៍នឹងបរិវារព្រះអង្គធ្វើដូចម្តេច ដើម្បីយាងចុះតាមជណ្តើរនោះបាន? ការឆ្លើយងាយសោះ ស្តេចនឹងបរិវារព្រះអង្គឥតយាងចុះតាមជណ្តើរនេះទេ ព្រោះជណ្តើរនេះជាជណ្តើរឡើងពីទីអាសនៈព្រះ ជនណាក៏ដោយមិនអាចចុះតាមផ្លូវនេះបានឡើយ ។ មានតែព្រះសង្ឃនឹងអ្នករក្សាព្រះពុទ្ធអង្គប៉ុណ្ណោះទេ ដែលមានអំណាចចុះឡើងតាមនោះបាន ។ សាសនាហិណ្ឌូគឺយ៉ាងដូច្នេះឯង ។

ប្រាសាទខ្មែរទាំងនោះបង្ហាញឲ្យឃើញនូវអតីតកាលដ៏រុងរឿង, នៅជំនាន់ដែលប្រទេសកម្ពុជាសម្បូរណ៍ទៅដោយផលានុផល, កិត្តិយសនឹងកិត្តិគុណយ៉ាងល្បីល្បាញ ។ គឺជាជំនាន់ដែលក្សត្រខ្មែរជាមេចម្បាំងមួយយ៉ាងឯកនឹងជាមេបញ្ជាការយ៉ាងឈ្លាសវៃ សោយរាជ្យនៅលើអាណាចក្រដ៏ធំទូលាយ ។

ក្សត្រទាំងនោះសុទ្ធតែបានសង់ប្រាសាទពាសពេញ ព្រោះមានព្រះរាជធានីខ្លះមានឈ្មោះថាអង្គរ ឋិតនៅខាងជើងបឹងទន្លេសាប ។

រាជធានីមួយៗមានស្នាមភ្លោះ, មានស្រះជីក, មានកំពែងព័ទ្ធជុំវិញ ។ នៅកណ្តាលវត្តទាំងនោះហើយដែលគេឃើញប្រាសាទជាច្រើនសាងថ្វាយព្រះឥសូរ, ព្រះវិស្ណុឬព្រះមហាសាវកនៃព្រះពុទ្ធ (Grand sage du Bouddha) ។

ក្សត្រមួយអង្គៗតែងបង់បានប្រាសាទមួយៗ ដើម្បីឧទ្ទិសចំពោះព្រះអាទិទេពដែលក្សត្រអង្គនោះឯងធ្វើជាតំណាងព្រះអាទិទេព នៅលើលោកយើងនេះ ហើយសំខាន់បំផុតគឺទុកចារិកព្រះនាមព្រះអង្គនៅក្នុងប្រាសាទនោះ ក្រោយពេលដែលព្រះអង្គទ្រង់ចូលព្រះសុវណ្ណកោដ្ឋទៅ ៗ ត្រង់នេះពន្យល់ឲ្យឃើញថាបើគេចូលទៅក្នុងផ្ទៃប្រទេសកម្ពុជា, គេនឹងឃើញប្រាសាទជាច្រើនដែលគេស្មានប្រមាណជិតមួយពាន់ប្រាសាទ ៗ ពីដើមនៅក្នុងសតវត្សរ៍ទី ១២ ទី ១៣ និងទី ១៤ ប្រទេសខ្មែរជាអាណាចក្រមួយមានឈ្មោះលាន់ឮរន្ទឺសុះសាយ, ជានគរឯករាជ្យមានផ្ទៃដីធំទូលាយក្រៃលែងគឺប្រទេសឥណ្ឌូចិនទាំងមូលរួមជាមួយនឹងប្រទេសសៀមប្រទេសលាវមួយផ្នែកៗទៀត ៗ

បណ្ដាអ្នកប្រាជ្ញទាំងឡាយ ដែលសរសេរអត្ថបទពីនិម្មាបនកម្មខ្មែរ, តាមការយល់របស់ខ្ញុំ មានតែអ្នកប្រាជ្ញម្នាក់ទេគឺលោក ហង់រី-មូហូ ដែលបាននិពន្ធរឿងនេះក្បោះក្បាយជាងគេ ៗ លោក ហង់រី-មូហូ ជាអ្នកប្រាជ្ញខាងធម្មជាតិបានធ្វើដំណើរពាសពេញក្នុងប្រទេសកម្ពុជា ៗ ជាលើកដំបូងបង្អស់គឺនៅឆ្នាំ ១៨៥៩ លោកបានអញ្ជើញទៅដល់អង្គរវត្ត រួចតមកលោកក៏យករឿងនោះមកដំណាលប្រាប់ប្រជាជន ឲ្យបានស្គាល់អង្គរវត្តគ្រប់ៗគ្នា ៗ ប៉ុន្តែខ្ញុំសូមដកឃ្លាបន្ថែមថា នៅលើទំព័រអត្ថបទទាំងនោះអ្នកនិពន្ធពុំបានពោលឲ្យហ្មត់ចត់អំពីឫសគល់នៃនិម្មាបនកម្មខ្មែរនោះប៉ុន្មានទេ អ្នកនិពន្ធគ្រាន់តែបញ្ចេញទឹកចិត្តពោលស្ញើចសរសើរ ទូវការចាប់អារម្មណ៍ចំពោះនិម្មាបនកម្មប៉ុណ្ណោះ ៗ ដូច្នេះ អត្ថបទដែលពោលអំពី

និម្មាបនកម្មខ្មែរ មានខ្វះសេចក្ដីជាច្រើនមិនគ្រប់គ្រាន់ ដូចអត្ថបទដែលដំណាលពីប្រាសាទអង្គរឡើយ ។

កាលនៅសតវត្សរ៍ទី ១៣, មានចិនម្នាក់ឈ្មោះ ជាវ-តា-ក្វាន់ បានមកមើលអង្គរ, ធ្វើដំណើរពាសពេញក្នុងប្រទេសខ្មែរ រួចបានសរសេររឿងនោះយ៉ាងសព្វគ្រប់ ។ អត្ថបទរបស់ ជាវតាក្វាន់ នេះ គេប្រមូលទុកជាឯកសារមួយយ៉ាងឯកពោលអំពីជីវភាពប្រជាជនខ្មែរនៅពេលនោះ និងអំពីពិធីផ្សេងៗដែលគេនិយមធ្វើនៅក្នុងលានព្រះរាជវាំង ។ មានចិនបួនខ្មែរជាច្រើនក៏បាននិយាយប្រាប់ខ្ញុំសព្វគ្រប់អំពីរបរអាជីវកម្ម និងអំពីកាយ-វិការខ្មែរនៅសម័យនោះ ដោយចង្អុលបង្ហាញលើសិលាចារិកៗ ទាំងនោះមិនប្លែកគ្នាពីរូបគំនូរ ដែលគេឆ្លាក់នៅលើផ្នូរខ្មោច ជាតិអេហ្ស៊ីបឡើយ ។

សាវតារក្នុងប្រទេសនឹងរឿងរ៉ាវក្នុងរជ្ជកាលស្ដេចនីមួយ ដែលកើតមានឡើងជាលំដាប់លំដោយតាំងពីសតវត្សរ៍ទី ៧ រហូតមកទល់សតវត្សរ៍ទីជំនាន់ដែលអាណាចក្រខ្មែរធ្លាក់ចុះអាប់អោនបន្តិចម្ដងៗ ធ្វើឲ្យយើងស្គាល់បាន ដោយសារមានចារិកនៅលើជញ្ជាំងប្រាសាទឬនៅលើគោលថ្មផ្សេងៗ ។ អក្សរចារិកទាំងនោះជាសំស្ក្រឹតឬជាអក្សរខ្មែរបុរាណ ។

មានអ្នកប្រាជ្ញខ្វះដូចជាលោកហ្វីលីព-ស្ទៀន និងអ្នកស្រី កូរ៉ល-ដឺរ៉េមុយសាត់ ទើបអាចពោលរកញែកសព្វគ្រប់អំពីការវិវត្តន៍នៃសិល្បខ្មែរដោយមានលក្ខណៈច្បាស់លាស់នៅគ្រប់រជ្ជកាលក្សត្រនីមួយៗ ។ ដូច្នេះយើងក៏បានដឹងរឿងនោះយ៉ាងជាក់ច្បាស់ នៅគ្រប់ប្រាសាទទាំងឡាយក្នុងកម្ពុជរដ្ឋ ។

ដោយសារការស្វែងរកទាំងអម្បាលម៉ាននេះ, គេសង្កេតឃើញបែបនិម្មាបនកម្មនៅសតវត្សរ៍ទី ៩ ជាឧទាហរណ៍ខុសគ្នាស្រឡះពីនិម្មាបនកម្មនៅសតវត្សរ៍ទី ១១ ឬ ទី ១២ ដូចគ្នានឹងនៅប្រទេសបារាំងបែបនិម្មាបនកម្មម្យ៉ាងខុសគ្នាអំពីនិម្មាបនកម្មនៅជំនាន់ព្រះបាទល្វៃទី ១៤ ឬ ល្វៃទី ១៥ ។ តាមរឿងហេតុទាំងនេះ ឃើញថាប្រទេសកម្ពុជា ជាប្រទេសមានឥទ្ធិពលជាងប្រទេសឥណ្ឌាឬជ្វា ព្រោះនៅលើប្រាសាទផ្សេងៗនៃប្រទេសឥណ្ឌា គេឃើញរូបចម្លាក់តិចណាស់មិនដូចជានៅលើប្រាសាទខ្មែរទេ ។ អស់ពេលជាយូរមកហើយ គេតែងពោលថាសិល្បខ្មែរកើតមានតាំងពីអតីតកាលដ៏អង្វែងមកម្ល៉េះ តែគេចាំសាវតារពុំច្បាស់ ។

បំណែកខ្ញុំៗ បានជួបទេសចរជាច្រើនដែលខ្ញុំបាននិយាយប្រាប់អំពីកាលបរិច្ឆេទយ៉ាងត្រឹមត្រូវនៃប្រាសាទអង្គរវត្ត ។ ខ្ញុំបានជំរាបប្រាប់គេថាប្រាសាទអង្គរកើតឡើងជំណាលគ្នានឹងជំនាន់ប្រទេសបារាំង កើតមានព្រះវិហារនានាសាសនា ។ ការដែលខ្ញុំនិយាយប្រាប់គេនោះត្រូវណាស់ បើប្រសិនជានៅពេលដែលខ្ញុំកំពុងថ្លែងរៀបរាប់នោះ, ទេសចរអ្នកស្តាប់កំពុងតែចោលអារម្មណ៍ទៅលើប្រាសាទខ្មែរ ។

ព្រះវិហារទាំងឡាយក្នុងប្រទេសកម្ពុជា ដែលគេសាងឧទ្ទិសចំពោះព្រះឥសូរ, ព្រះព្រហ្ម, ព្រះវិស្ណុ សុទ្ធតែមានកត់ចារិកជាសំស្ក្រឹតដែលជាបុរាណភាសានៃប្រទេសឥណ្ឌា ។ សំអាងទៅលើរូបចម្លាក់ទាំងនេះគេអាចពោលបានថា និម្មាបនកម្មខ្មែរទាំងឡាយសុទ្ធតែចម្លងឬយកគំរូតាមសិល្បៈឥណ្ឌា ។ មានអ្នកខ្លះហ៊ានទាំងពោលថា ជាងដែលសាងប្រា-

សាទអង្គរសុទ្ធតែពួកនិម្មាបនិក (Architectes) មកពីប្រទេសឥណ្ឌា ៗ ប្រជាជនភាគច្រើនក៏ព្រមជឿតាម ថែមទាំងបានផ្សាយឬសរសេរថា និម្មាបនកម្មខ្មែរដែលមានកំណើតកើតចេញពីនិម្មាបនកម្មហិណ្ឌូនោះ គ្រាន់តែជានិម្មាបនកម្មរបស់ឥណ្ឌានៅតាមអាណាខេត្តគេផង ៗ

ដែលពោលដូច្នោះមិនពិតសោះ ព្រោះខ្ញុំបានទាំងធ្វើដំណើរកាត់ប្រទេសឥណ្ឌា ចាប់តាំងពីខាងជើងរហូតទៅខាងត្បូងប្រទេស ដើម្បីមើលប្រាសាទក្នុងនគរនោះ រួចខ្ញុំបានពិនិត្យយ៉ាងហ្មត់ចត់ទៅឃើញមានប្រាសាទខ្លះល្អពិតមែន, ប៉ុន្តែដល់សង្កេតមែនទែនទៅឃើញក្បួនទឹងសណ្ឋានសិល្បខុសគ្នាស្រឡះពីសិល្បនៅប្រទេសខ្មែរ ៗ

ឧបមាដូចជានៅលើផ្ទៃប្រទេសឥណ្ឌា តើគេឃើញមានវិថីប្រាសាទយ៉ាងល្អវិចិត្រចូលទៅកាន់កន្លែងអាសនៈព្រះកាត់ស្នាមកោះ, កាត់ស្រះជីកមានបង្កាន់ដៃអមសងខាងធ្លាក់ជារូបយក្សទេវរូបនាគពជទេ ?

រូបភាពយ៉ាងសម្បើមនៃសិល្បខ្មែរនេះ បើប្រសិនជាគេសាងឡើងដើម្បីរំលឹកដល់វត្ថុអ្វីមួយនោះ, គេអាចប្រៀបទៅនឹងវិថីហៅដម៉ូសចូលទៅក្នុងប្រាសាទអេហ៊ីបបាន ៗ

បណ្ដាប្រាសាទខ្មែរមួយណាដូចមួយណា, ពួកទេសចរត្រូវប្រឹងដោយពេញកំឡាំងដើម្បីឡើងតាមជណ្ដើរធំៗ ទៅលើខឿនជាច្រើនជាន់ច្រើនថ្នាក់មានរាងដូចស្តូបពិសដ្ឋមួយ ៗ គឺនៅលើកំពូលស្តូបនោះហើយដែលគេសង់ទីអាសនៈជាន់ខ្ពស់ (Sanctuaire centrale) ៗ របៀបសិល្បខាងលើនេះគេពុំដែលឃើញទេនៅប្រទេសឥណ្ឌា តែចំពោះជនណា

ដែលបានទៅមើលប្រាសាទម៉ាយ៉ាសនៅប្រទេសអាមេរិកកណ្ដាលនោះៗ ពុំអាចទប់ចិត្តមិនប្រដូចប្រាសាទខ្មែរយើង ទៅនឹងប្រាសាទគេអូកាល្ងី នៅមុខក្រិកបានឡើយ ។

មិនតែប៉ុណ្ណោះនៅមានការរចនាពយរន៍ខ្លះទៀតបញ្ជាក់ឲ្យឃើញនូវការល្អឆើតឆាយនៃសិល្បខ្មែរប្រៀបទៅនឹងសិល្បឥណ្ឌា ។ ដូច្នេះគេនៅប្រទេសឥណ្ឌា គេអាចឃើញមានរូបចម្លាក់ក្បាច់ក្បូរមានបន្ទាត់ខ្វាត់ខ្វែងប្រទាក់រយេនិររយោនដូចជាប្រាសាទអង្គរវត្តទេ? ដោយសារនៅបន្ទោះខ្លះ នៃប្រាសាទដែលប្រកបដោយការរចនាយ៉ាងប្រិតប្រៀបបំផុតនោះ ដើម្បីធ្វើឲ្យលេចពីចម្ងាយនៃតួអាសនៈជាន់ខ្ពស់, ដោយសារវាលស្មៅពងធំធេង, ដោយសារថ្មកទឹក, ស្រះជីក ប្រាសាទនោះធ្វើឲ្យវិញ្ញាណអ្នកមើលចាប់ចិត្តនឹកដល់វិមានទេវសែជាពន់ពេក ។

ឯផែនការសង់ប្រាសាទទៀត ក៏មានរបៀបរៀបរយសមរម្យល្អណាស់ប្រដូចទៅនឹងផែនការដែលគេរៀបតាំងអច្ឆរិយវត្ថុ នៅសាលាវិចិត្រសិល្បៈនៃប្រទេសរ៉ូម នៅឆ្នាំ ១៨៩០ ។

ពោលដោយខ្លីទៅ, នៅកន្លងនិម្មាបនកម្មខ្មែរនេះ• គេសង្កេតឃើញគំនិតរបៀបចិត្តផ្ទុំផ្ទួននៃសិល្បករខុសប្លែកពីប្រាសាទឥណ្ឌា ដែលមានរូបចម្លាក់ស្ទើរតែពុំស្គាល់ជាអ្វី ។ គំនិតខេមរៈសិល្បករយើងនេះប្រហែលគ្មាននឹងគំនិតពួកអ្នកប្រាជ្ញធំៗ នៅអឺរ៉ុប ។ ដោយសារអង្គរវត្តជាស្នាដៃឯកនៃសិល្បខ្មែរ, គេអាចដឹងច្បាស់ថាអាណាចក្រខ្មែរពីដើមជាអាណាចក្រមានសារការយ៉ាងខ្ពង់ខ្ពស់ខាងសិល្ប ។ និម្មាបនកម្មខ្មែរ បើយើងពិនិត្យ

ឲ្យហាត់បត់តាំងពីក្បាច់ល្អិតល្អោចបន្តិចបន្តួច រហូតដល់ក្បាច់ចម្លាក់ធំៗ ឃើញប្លែកគ្នាទាំងអស់ ។ មានប្រាសាទពីរទៀត គឺប្រាសាទព្រះខ័ន នឹងប្រាសាទតាព្រហ្មឋិតនៅជិតប្រាសាទតាកែវ មានកពងដូចស្តូបមួយ ។ ស្តូបនេះខុសពីប្រាសាទដទៃទាំងអស់ ព្រោះគ្មានរូបចម្លាក់អ្វីសោះនៅលើផ្ទាំងក្រៅ ។ នៅលើតួប្រាសាទទាំងពីរ មានដើមឈើដុះត្របជិតពីលើ មើលទៅហាក់ដូចជាប្រាសាទនោះ លេងល្បែងបំពួននៅកណ្តាលព្រៃព្រឹក្សា ។

នៅឯប្រាសាទបក្សីចាំក្រុងវិញ មានព្រះវិហារតូចមួយសង់ជាប់នឹងទ្វារចូលក្រុងខាងត្បូងអង្គរធំ បញ្ចេញទង់ទោយយ៉ាងប្រណីត ប្រកបដោយទៀនដម្កល់យ៉ាងខ្ពស់ហើយនឹងពណ៌ក្រហមឆ្អៅ នៅពេលដែលព្រះអាទិត្យបញ្ចាំងរស្មីមកលើ ។

មានប្រាសាទមួយទៀតឈ្មោះបន្ទាយស្រី ដែលមានរូបចម្លាក់ល្អចំឡែកគួរឲ្យគយគន់ណាស់, ជាប្រាសាទមួយដែលមានក្បាច់របនាល្អត្រកាលវិស័យដូចក្បាច់ដែលគេធ្វើនៅលើមាស ។

បន្ទាប់ពីនេះទៅ ខ្ញុំសូមជូនយោបល់ប្រៀបធៀបសិល្បខ្មែរ ទៅនឹងប្រាសាទដទៃទៀត ដែលខ្ញុំស្គាល់ក្នុងពិភពលោក ។

ស្តូបនៅប្រទេសអេហ្ស៊ីប ជាការកសាងមួយយ៉ាងលំបាកក្រៃលែង ដោយមានមនុស្សធ្វើការជាច្រើននាក់ រហូតទាល់តែបានហើយជាតួពងមួយយ៉ាងសម្បើមសង្កេតមើលតាមជំនៃសិល្ប ។ ប៉ុន្តែស្នាមបន្ទាត់

ចម្លាក់ទីងកង៍ក្បាច់ឃើញថានៅខ្ចីណាស់ គ្មានកន្លែងត្រង់ណាមួយដែលបង្ហាញឲ្យឃើញនូវចំណេះវិជ្ជាដ៏ខ្ពង់ខ្ពស់សោះ ។

ការរចនាដែលមានសណ្ឋានជាជ្រុងៗ (art gothigue) លេចលយយ៉ាងខ្ពស់ត្រដែតទៅលើអាកាសនកាល័យ, មានកំពូលស្រួចតូចៗ អមជុំវិញ គួរឲ្យល្អមើលមែន ប៉ុន្តែបើសង្កេតមើលបន្ទាត់ទទឹងបន្ទាត់ផ្ដេកឃើញថាគ្គងច្រើនណាស់ ។ ផ្ទុយទៅវិញ ប្រាសាទក្រិកទាញចិត្តទេសចរឲ្យចង់តែទស្សនាដោយសារតែប្រាសាទនោះមានបន្ទាត់ ចម្លាក់សមល្មមហើយត្រង់ៗ មានសមាមាត្រជាមាត្រដ្ឋានមនុស្សលោកផ្ទើ, ប៉ុន្តែបើនរណាពោលថាជាស្នាដៃទេវតានោះគឺយល់ខុសស្រឡះទេ ។

ចំណែកទិម្ពាបនកម្មបាក់ងនៅសតវត្សរ៍ទី ១ ទីងទី ១៨ វិញ ដែលមាននៅទីងវិហារខ្លះ បង្ហាញឲ្យឃើញថាមានដម្លៃថ្លៃថ្នូរមានខ្លឹមសារត្រាន់បើដែរ ប៉ុន្តែពុំសូវសម្បើម, ពុំសូវទាញអារម្មណ៍ អ្នកផងឲ្យចង់ទស្សនាប៉ុន្មានទេ ។

ដូច្នេះបង្អួលឲ្យឃើញថា មួយចំណែកនៃទិម្ពាបនកម្មខ្មែរកើតគំនិតចេញមកអំពីប្រាសាទទាំងឡាយដែលខ្ញុំបានរាប់រៀបមកខាងលើនេះ ។ ប្រាសាទមានរាងដូចស្តូប ដែលមានការរចនាឆាយល្មមមិនពិបាកពេកមិនស្រណុកពេកបិតនៅឯបាតនងទីងកោះកែ ។

ក្បាច់រចនាដែលមានសណ្ឋានជ្រុង ៗមូលៗបន្តិចមានធ្លាក់នៅជុំវិញបរិវេណកំពូលប្រាសាទដែលលយក្ដាប់ទៅនឹងហោជៀង ពាក់ព័ន្ធជា

ច្រើនត្រូវ ថែមទាំងបន្ទុបថ្មជាច្រើនពីលើដើម្បីបំពេញជ្រុងចម្ងាក់ នៅក្បាលសសរជាប់នឹងដំបូល ។

ជាលើកដំបូងគេឃើញសិល្បក្រិក នៅនឹងអង្គរត្រង់ក្បាលសសរទីពីរ ជាប់នឹងក្បាលសសរទ្រដំបូលនៃប្រាសាទអង្គរវត្ត ដែលយើងស្គាល់ជាក់ជាងគេ ។ ត្រង់នេះ ខ្ញុំមានបញ្ហាមួយចោទឡើងថា: ចុះហេតុដូចម្តេចបានជាសិល្បក្រិកព្រួសាយមកដល់តាមឆ្នេរទន្លេមេគង្គ? ។ មុននឹងឆ្លើយសំនួរនេះ យើងត្រូវដឹងថាលោកអាឡិចសង់-ឡឺ-ក្រង់ ជាស្តេចប្រទេសម៉េដ្វាននៅខាងជើងប្រទេសក្រិកបាននាំយកទម្រង់សិល្បខ្លះមកពីប្រទេសឥណ្ឌាខាងជើងដូចជាព្រះពុទ្ធរូបជាដើមដែលគេនាំយកទៅស្រុកគេនោះសុទ្ធតែធ្លាក់ព្រះភក្ត្រទាំងអស់ បើមិនពួកក្រិកធ្លាក់ក៏ពួកកូនសិស្សជាងដែលរៀននៅសាលាក្រិកធ្លាក់ដែរ ។ ហេតុដូច្នេះហើយបានជាព្រះពុទ្ធរូបនៅប្រទេសក្រិកជាន់ដើម មានទ្រង់ទ្រាយប្រហែលគ្នានឹងរូបព្រះរបស់គេឈ្មោះអាប៉ូឡុង ។ រួចចាប់ពីប្រទេសឥណ្ឌាមកតាមប្រទេសអាស៊ីកណ្តាល គេឃើញមានបុរាណវត្ថុជាច្រើនដែលជាប់ទាក់ទងនឹងសិល្បក្រិក, អ៊ីរ៉ង់, ពៀរ៍សង់ ហើយវត្ថុទាំងនោះមានសាយចូលទៅដល់ប្រទេសចិននឹងប្រទេសជប៉ុន, រួចត្រឡប់ចេញពីប្រទេសទាំងនេះចូលមកប្រទេសឥណ្ឌូចិន ។

ក្រៅពីនោះមានក្បាច់ក្បូរខ្លះទៀតដែលនៅនឹងធ្នឹមទ្វារ ឬនៅលើសិលាចារិកនៃសិល្បខ្មែរជំនាន់សតវត្សទី ៩ នឹងទី ១០ នោះមិនមែនឥត

ខ្លឹមសារទេ  គឺពិតជាមានខ្លឹមសារហើយថែមទាំងល្បីល្បាញលាន់ឮរន្ទឺ ប្រហែលគ្នានឹងវិហារបារាំងជំនាន់សតវត្សរ៍ទី ១៧ នឹងទី ១៨ ដែរ ។

ខ្ញុំសូមបញ្ជាក់ថាដែលខ្ញុំពោលនេះ គឺខ្ញុំពោលពីសិល្បៈខ្មែរនៅសតវត្សរ៍ទី ៩ នឹងទី ១០, ពីព្រោះនៅក្នុងសិល្បៈថៃនឹងសិល្បៈខ្មែរបច្ចុប្បន្ននេះមានក្បាច់ក្បូរកង្កាក់ដែលកើតឡើងនៅជំនាន់ល្វិទី ១៥ នឹងល្វិទី ១៦ លាយឡំគ្នាច្រើនណាស់ ។ ការនេះបញ្ជាក់ឲ្យឃើញថា កាលប្រទេសសៀមបញ្ជូនឯកអគ្គរាជទូតទៅកាន់ប្រទេសនោះក្នុងជំនាន់នេះ ។ លុះឯកអគ្គរាជ-ទូតនោះត្រឡប់មកវិញក៏បាននាំយកក្បាច់ក្បូរខ្លះមកបំភ្លឺប្រជាជនគេផង ។

ខ្ញុំសូមស្ទះរឿងសិល្បៈតែប៉ុណ្ណេះ ។ បន្ទាប់ពីនេះខ្ញុំនឹងដំណាលពីប្រាសាទសិលាខ្មែរនៅអតីតកាល ដែលសព្វថ្ងៃមានសុទ្ធតែស្មៅដុះរុំព័ទ្ធពាសពេញ ។

កាលជំនាន់ដើមប្រទេសខ្មែរជាប្រទេសថ្កុំថ្កើងរុងរឿងណាស់ មានក្សត្រប្រកបដោយទសពិធរាជធម៌សោយរាជ្យលើអាណាចក្រនេះ ដែលខ្ញុំនឹងអធិប្បាយដោយអន្លើ ៗ ជូនជាសណ្ដាប់ ។ នៅថ្ងៃធ្វើបុណ្យខាងសាសនាឬបុណ្យផ្សេង ៗ ទៀត, ព្រះភិក្ខុសង្ឃជាច្រើនបានដង្ហែព្រះពុទ្ធ-រូបកណ្ដាលចំណោមប្រជាជននៅលើវិថីធំៗ ទាំងឡាយដែលសព្វថ្ងៃស្ងាត់សូន្យឈឹង ។ នៅពេលនោះគេសង្កេតឃើញព្រះមហាក្សត្រទ្រង់ប្រ-ដាប់ដោយសំលៀកបំពាក់មានរលោយាលរលេចយ៉ាងចែតឆាយ គង់នៅកណ្ដាលអស់អ្នកអស់នាងនឹងនាហ្មឺនសព្វមុខមន្ត្រី ។ ខាងមុខ មានពួកទាហានរក្សាព្រះអង្គ ស្លៀកពាក់សំលៀកបំពាក់យ៉ាងចែតឆាយកាន់ទង់-

ជ័យជាតិ ។ ខាងក្រោយ មានពួកស្រីបរិវារមើរដើរជាសដើរតាមក្បួន ។ សំឡេងតូរ្យតន្ត្រីលាន់ឮខ្ទរពាសពេញលាយឡំនឹងសូរស័ព្ទអំណរនៃប្រជាជន ។ រីឯប្រាសាទទាំងឡាយក្តីចាំងត្រចះត្រចែងក្រោមរស្មីព្រះអាទិត្យ ។ រឿងទាំងនេះ ខ្ញុំបានដឹងពីអ្នកដំណើរចិនម្នាក់ ដែលខ្ញុំបានជំរាបពីមុននេះ ព្រោះគាត់បានទៅមើលពិធីនឹងក្បួនដង្ហែនោះផ្ទាល់នឹងភ្នែកគាត់ ។

គាត់បានដំណាលបន្ថែមទៀតថា កំពូលប្រាសាទទាំងនោះសុទ្ធតែធ្វើអំពីមាសប្រាក់ទឹងស្ពាន់ សូម្បីតែបរិវេណកំពូលក្រោមៗ ក៏ស្រោបសន្ទឹកមាសឬប្រាក់ដែរ ។ តែសព្វថ្ងៃនេះនៅសល់តែស្នាមខ្មៅៗ ទេជាប់នៅនឹងថ្ម ។ អំណាចក្សត្រខ្មែរពីដើមបានធ្វើឲ្យអ្នកផងកោតស្ញប់ស្ញែងចាំពុំភ្លេចសោះឡើយ ។ ស្ទើរគ្រប់គ្នាឆ្ងល់ថាចុះហេតុអ្វី បានជាជំនាន់ដែលប្រកបទៅដោយកិត្តិគុណ, ដោយរិទ្ធិអំណាច, សេចក្តីសុខសេចក្តីចំរើន, សម្បូរធនធានហូរហៀរនោះក៏ធ្លាប់វិនាសម៉្លេះ? ខ្ញុំសូមជំរាបថា ដោយហេតុនៅពេលដែលស្រុកកើតចម្បាំងរាំងជល់នឹងសៀម ទ័ពសៀមក៏ចូលមកលុកលុយប្រទេសកម្ពុជា នៅសតវត្សរ៍ទី ១៤ នៅពេលនោះស្រុកខ្មែរទៅជាអត់ឃ្លានកំរើងហួតហែងទឹកអស់ ។ ស្ទឹងបឹងបួរទាំងប៉ុន្មានគោកក្រញង់គ្មានសល់ ជាហេតុបណ្តាលឲ្យផលដំណាំដាំដុះផ្សេងៗ វិនាសហិនហោចអស់ ។ ពេលនោះទ័ពសៀមក៏ពុំបានតាំងទីលំនៅៗ អង្គរដែរ ពិតមែនតែស្តេចខ្មែរបានរត់គេចចេញហើយក៏ដោយ ។

ការខ្វះទឹកប្រើប្រាស់នេះបង្ខំឲ្យប្រជាជនរត់ចោលទីលំនៅអស់ ជាឱកាសបើកដៃឲ្យរុក្ខជាតិលតាវល្លិដុះគ្របសង្កត់លើប្រាសាទបុរាណៗ ទាំងនោះ, ចាក់ឫសពាសពេញចូលទៅក្នុងប្រាសាទបណ្ដាលឲ្យជញ្ជាំងនិងពិតានស្រុតបាក់បែកខ្ទេចខ្ទី ៗ ព្រៃឈើមួយដុះយ៉ាងធំក្រាស់ជំនួសកន្លែងដែលមនុស្សធ្លាប់លេងអ៊ូអរពីមុន ។

លុះមកដល់ឆ្នាំ ១៩០៨, ពេលដែលសៀមប្រគល់ខេត្តបាត់ដំបងនិងសៀមរាបមកខ្មែរវិញ រាជការបារាំងសែសបានចូលមកដល់អង្គរវត្តរួចក៏បានកាប់ឆ្ការព្រៃផ្សៃ ដែលដុះចាក់ឫសរួតរឹតប្រាសាទទាំងនោះអស់, ធ្វើឲ្យលេចឃើញតួប្រាសាទយ៉ាងល្អត្រចះ ៗ ស្នាដៃសាលាបារាំងសែសខាងបូព៌ាប្រទេស បានបន្តការនេះតាំងពីពេលនោះរហូតមកទល់សព្វថ្ងៃ ហើយគេអាចសង្ឃឹមច្បាស់ថា កេរ្តិ៍ដំណែលយ៉ាងឧត្តុង្គឧត្តម គឺប្រាសាទបុរាណទាំងប៉ុន្មាននេះមុខជាជៀសរួចពីសេចក្ដីអន្តរាយ និងសេចក្ដីធ្វេសប្រហែសនៃប្រជាជនខ្មែរក្នុងការថែទាំអច្ឆរិយវត្ថុនេះទៅអនាគតពុំខាន ។

ប្រែចេញពីសារពត៌មាន « កាមបូជ៍ » ចេញពីថ្ងៃ ១៩-៥-៥៥
លេខ ២៨៨៤ និងថ្ងៃ ២០-៥-៥៥ លេខ ២៨៨៥ ឆ្នាំទី ១២ ។

# រឿងសាមកុក

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាជការផ្លាស់បើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

### កណ្ឌទី ២២

តាំងពីប៊ូធូពិគ្រោះគ្នានឹងគុយកែទីប្រឹក្សា គិតលើកទ័ពទៅវាយឡៀពីចៅហ្វាយស្រុកឈីជីវ រហូតដល់ប៊ូធូឲ្យសេះសិកថាវទៅគួនអ៊ូជាជំនិះ, សេះនេះដើរផ្លូវ ១ ថ្ងៃ ១ ម៉ឺនសិ៍ (គឺ ២០១ គ.ស.) ។

---

ខណៈនោះ ទទួលគុយកែចូលមក ៗ ប៊ូធូក៏ពិគ្រោះសួរថា យើងនឹងលើកកងទ័ពទៅច្បាំងនឹងឡៀពីនៅស្រុកឈីជីវខាងទិសឯកើត តែបារម្ភក្រែងខាងទិសឯជើងខ្លាចអ៊ួនសៀវដឹង នឹងលើកទ័ពមកសន្ទប់វាយយកក្រុងហ៊ូតោ តើអ្នកនឹងយល់ឃើញដូចម្តេច? ៗ គុយកែះឆ្លើយថា ឯជំរេះប្រាជ្ញានឹងគំនិតអ៊ួនសៀវនោះ បើនឹងធ្វើការអ្វីក៏ស្លូវពន់ណាស់ បើនឹងប្រើនរណាអ៊ួនសៀវក៏រមែងសង្ស័យមិនចុះចិត្តជឿអ្នកនោះ ប្រការ ១

ទៀតសេនាទាហានអ៊ួនសៀវក៏បែកខ្វែកចិត្តគំនិតពីគ្នា បើប្រសិនណានឹង
លើកទ័ពមកវាយក្រុងហ៊ូតោមែន គំគង់មិនសម្រេចតាមគំនិត ឯឡៅពី
សោតក៏ទើបតែត្រឡប់ទៅនៅស្រុកឈីជីវ ហើយទាហានដែលជាប់តាម
ទៅក៏សុទ្ធតែទាហានរបស់យើង ដែលនឹងគិតការធ្វើសឹកសង្គ្រាមនោះ
មុខជាទាហានទាំងពួងមិនស្រុះចិត្តជាមួយគ្នាទេ បើយើងរង់បង្អង់ទុកឲ្យ
យូរទៅទៀត ឃើញថាទាហានទាំងនោះនឹងរួមគំនិតចូលគ្នា ហេតុនេះ
សុំឲ្យលោកបង្ហិលើកកងទ័ពទៅវាយស្រុកឈីជីវជាប្រញាប់ ៗ ចូចូបាន
ស្តាប់ក៏ត្រេកអរណាស់ ឆ្លើយតទៅគុយកែវិញថា "ដែលយើងសួរនេះ
គឺក្នុងសួរចង់ដឹងជម្រះប្រាជ្ញានឹងគំនិតរបស់អ្នកទេ ឥឡូវនេះ អ្នកឆ្លើយ
មកក៏ដូចគំនិតយើងដែលគិតទុកដែរ" ហើយចូចូក៏ផ្ដុំពលយោធាបាន
ប្រមាណ ២០ ម៉ឺនលើកចេញពាក្រុងហ៊ូតោ ៗ

ពេលនោះ មានបំរើសេះស៊ើបការណ៍ដឹងថាចូចូលើកទ័ពមក ក៏
ស្រូតរូតចូលទៅជំរាបស៊ុនខៀនក្នុងស្រុកឈីជីវថា ឥឡូវចូចូលើកទ័ពមក
ហើយ ៗ ស៊ុនខៀនដឹងដូច្នោះ ក៏ទៅប្រាប់គួនអ៊ូនៅស្រុកហៃហ៊ីតាម
ដំណឹងនេះ ហើយឲ្យរៀបចំត្រៀមសេនាទាហានទុកឲ្យព្រម រួចស៊ុន
ខៀនក៏ហួសទៅស្រុកសៀវផាយទៀត ដើម្បីនឹងឲ្យដំណឹងឡៅពី ៗ ដឹង
ដូច្នោះក៏និយាយថា "យើងនឹងឲ្យមានសំបុត្រទៅដល់អ៊ួនសៀវទៀត ឲ្យ
លើកកងទ័ពមកជួយទើបនឹងទប់ទល់គនឹងចូចូបាន" គិតហើយក៏សរសេរ
សំបុត្រពាក់ស៊ុនខៀនឲ្យនាំយកទៅឲ្យអ៊ួនសៀវ ៗ ស៊ុនខៀនក៏ទទួល
នាំសំបុត្រទៅដល់ស្រុកគីជីវ ក៏ចូលទៅរកខៀនហាង អធិប្បាយរ៉ាយ

ឡើងឲ្យខ្មៀនហង់ស្តាប់គ្រប់ប្រការ ហើយថាចូរអ្នកជួយនាំខ្ញុំទៅជួបនឹងអ៊ួនសៀវ ។ ខ្មៀនហង់បានស្តាប់ដូច្នោះ គឺនាំស៊ុនខៀនចូលទៅដល់អ៊ួនសៀវ ស៊ុនខៀនគំនាប់ហើយ ក៏ជូនសំបុត្រទៅឲ្យអ៊ួនសៀវៗមើលដឹងសេចក្តីហើយ ក៏មិនមានថាអ្វីសោះ ក្លែងធ្វើជាទុក្ខសញ្ជប់សញ្ជឹង ។ ខ្មៀនហង់ឃើញមុខអ៊ួនសៀវសៅហ្មងក៏សួរថា ថ្ងៃនេះខ្ញុំឃើញមុខលោកមិនសប្បាយ តើលោកវិតក្កពីអ្វី? ។ អ៊ួនសៀវឆ្លើយថា យើងជិតនឹងស្លាប់ទៅហើយ ទើបមិនមានសេចក្តីសប្បាយសោះ ។ ខ្មៀនហង់ថា ហេតុម្តេចលោកចរចាជាពាក្យអពមង្គល? អ៊ួនសៀវថា ជីវិតយើងនឹងដល់នូវសេចក្តីស្លាប់ក្នុងថ្ងៃនេះ ឬថ្ងៃស្អែកក៏មិនដឹងឡើយ យើងវិតក្កនឹងបុត្រទាំង ៤ នាក់ ឃើញថាបុត្រពៅបង្អស់នោះ មានជម្រេះប្រាជ្ញាគ្រាន់បើ តែអាយុនៅក្មេងណាស់ ឥឡូវក៏មានជម្ងឺឈឺផងហេតុនេះ ទើបយើងមិនមានសេចក្តីសប្បាយនឹងគិតការអ្វីក៏មិនបាន ។ ខ្មៀនហង់តបថា មនុស្សទាំងអស់ក៏បានដឹងព្រមគ្រប់គ្នាថា លោកជាធំបំផុតក្នុងអាណាខែត្រខិសខុត្តរ ហេតុម្តេចលោកមកគិតរញ៉េរញ៉ៃ ហើយភ័យខ្លួនឯងឲ្យស្លាប់មុនឈឺដូច្នោះមិនគួរសោះ ឥឡូវចូចូលើកទ័ពមកវាយស្រុកឈើជីវហើយ ឯស្រុកហ៊ូគោនោះមិនមាននរណានៅត្រួតត្រាក្សាជាមាំមួន ទៀតពីក៏មានសំបុត្រមកសុំកងទ័ពលោកលើកទៅជួយ បើលោកលើកកងទ័ពទៅវាយស្រុកហ៊ូគោ គ្រានេះមុខជានឹងបានងាយណាស់ ។ អ៊ួនសៀវតបថា "យើងក៏ដឹងអស់ហើយថាគ្រានេះនឹងបានចំណាប់ធ្វើការសឹក តែចិត្តរបស់យើងផ្ចុះនឹងបុត្រ បើ

បុត្រយើងមានសេចក្ដីអន្តរាយជាខាងក្រោយហើយ ជីវិតយើងក៏នឹងស្លាប់ជាមួយ ប្រការ ១ ទៀតប្រសិនបើលើកទ័ពទៅគង់មិនមានជ័យជំនះព្រោះហេតុមិនសប្បាយនោះឯង" រូបអ៊ួនសៀវក៏បង្គាប់ស៊ុនខៀនថា គ្រានេះយើងមិនលើកទ័ពទៅទេ ឲ្យទៅប្រាប់ឡៅពីចុះ បើឡៅពីអាប់ចុនវេលាណា ក៏រត់មករកយើង ៗ នឹងជួយទំនុកបំរុងមិនឲ្យព្រួយលំបាកឡើយ ។

ខៀនហងបានឮអ៊ួនសៀវនិយាយដូច្នោះក៏ខឹងណាស់ ទើបថា "ស្ដាយ គ្រានេះបានចំណាប់ល្អហើយ គួរឬមកគិតជាធុរៈរវល់នឹងកូនតូចតាចដូច្នេះមិនគួរសោះ" ខៀនហងក៏ដកដង្ហើមធំហើយដើរចេញទៅ ។ ស៊ុនៈខៀនក៏លាអ៊ួនសៀវត្រឡប់ទៅស្រុកសៀវផាយវិញ ហើយអធិប្បាយពាក្យរឿងឲ្យឡៅពីស្ដាប់គ្រប់ប្រការ ។ ឡៅពីបានស្ដាប់ក៏ទឹកតូចចិត្តរិតតែព្រួយបារម្ភខ្លាំងណាស់ ប្រឹក្សានឹងស៊ុនខៀនថា ចូចូលើកកងទ័ពមកគ្រានេះ យើងរិះគិតចេញច្បាំងយ៉ាងម្ដេចឲ្យបាន ។

គៀវហ៊ុយឆ្លើយដំណបឡៅពីថា ទ័ពចូចូលើកមកគ្រានេះបើយើងនឹងបង្អង់ទុកឲ្យយូរ ចូចូនឹងតាំងជាមាំមួនបានរិតតែមានកំឡាំងធ្វើការសឹកយើងក៏លំបាក ព្រោះវេលានេះចូចូលើកចូលមកជិតស្រុកយើងហើយ ពេលយប់នេះ ខ្ញុំបាទសុំយកអាសាលើកពាហានចេញទៅព័ទ្ធវាយកងទ័ពចូចូ កុំឲ្យតាំងបន្ទាយជាមាំមួនឲ្យបាន មុខជាចូចូនឹងថយកាលផង់យើង ។ ឡៅពីបានស្ដាប់ក៏ថា "ប្អូនឯងពីដើមមក បងយល់ថាមិនចេះគិតអ្វីសោះ មានតែថ្វីដៃច្បាំងខ្លាំងពូកែតែម្យ៉ាង បងទើបនឹងបានឃើញដម្រិះម្ដង

កាលប្អូនធ្វើកលឧបាយចាប់ខ្លួនទៀតាយបាន ឥឡូវប្អូនទឹងលើកពលទៅព័ទ្ធយកកងទ័ពប្អូនមិនឲ្យតាំងជាមាំមួននោះ បងត្រូវចិត្តណាស់" ហើយទៀតពីក៏បែងរំលែកពលយោធាត្រៀមទុកសម្រាប់ខ្លួនឯង ១ កង ចាត់ឲ្យតៀវហ៊ុយ ១ កង ។

ចំណែកប្អូនកាលលើកទ័ពមកជិតស្រុកសៀវផាយហើយ ទទួលកើតខ្យល់ព្យុះបក់បោកខ្លាំងណាស់ ដងទង់ជ័យប្អូនដែលដោតលើរទេះក៏បាក់ដាច់ចុះ ប្អូនឃើញវិបរិតប្លែកក៏បញ្ឈប់កងទ័ពតាំងបន្ទាយនៅទីនោះហើយសួរទីប្រឹក្សាថា "ដែលមានខ្យល់ព្យុះបក់មករំលំបាក់ដងទង់ជ័យយើងដូច្នេះជាអាគេទល្អឬអាក្រក់ប្រការម្តេច? ។ ស៊ុនហុកឆ្លើយថា ថ្ងៃនេះកាចណាស់ មុខជាទៀតពីទឹងលើកទ័ពមកប្លន់បន្ទាយយើងជាប្រាកដហើយ ។ ទទួលម៉ាកាយចូលមកជល់ទៀតជំរាបប្អូនថា ខ្យល់ពីទិសឯកើតបក់មកត្រូវដងទង់ជ័យបាក់នោះ ខ្ញុំបាទយល់ថា កណ្តាលយប់នេះទឹងមានគេមកលុកបន្ទាយហើយ ។ ប្អូនបានស្តាប់ស៊ុនហុកទឹងម៉ាកាយនិយាយដូច្នោះ ក៏យល់ថាសំដីអ្នកទាំង ២ ត្រូវពាក្យគ្នា ទើបឆ្លើយថាដែលបណ្តាលឲ្យកើតខ្យល់ព្យុះដូច្នេះ គឺទេពតាសំដែងហេតុឲ្យដឹង ព្រោះយើងមានបុណ្យរាសនា ។ ប្អូនក៏ចាត់បែងកងទ័ពជា ១១ កង កង ១ ឲ្យនៅរក្សាបន្ទាយ ៨ កងឲ្យនាយទាហានឯកលើកញែកចេញ ទៅពួនបង្កប់នៅក្រៅបន្ទាយទាំង ៨ ទិស បើឃើញកងទ័ពខ្មាំងលើកមកប្លន់បន្ទាយវេលាណា ក៏ឲ្យទាហានទាំង ៨ កងនោះវាយប្រសព្វព័ទ្ធចូលមក.

២ កងទៀត តែញកគ្នាលើកទៅស្ទាក់នៅមាត់ផ្លូវដែលទឹងទៅស្រុកឈើដើរ ១ កង ទៅស្រុកហៃហ្វី ១ កង ៗ

លុះពេលយាម ២ ឡេវពីទឹងតៀវហ៊ុយក៏លើកទាហានចេញទៅពីស្រុកសៀវផាយ ៗ តៀវហ៊ុយក៏ត្រេបចិត្តគិតថា គ្រាមុនអញបានធ្វើកលឧបាយចាប់ឡេវតាយបាន គ្រានេះឡេវពីក៏សរសើរតម្រេះប្រាជ្ញាទឹងគំនិតរបស់អញច្រើនណាស់ តៀវហ៊ុយក៏ជិះសេះលើកទាហានជាកងមុខចូលទៅវាយបន្ទាយចូចូ ៗ តៀវហ៊ុយឃើញមនុស្សក្នុងបន្ទាយនោះតិច ហើយបានឮសំឡេងទាហានខាងក្រោយបន្ទាយស្រែកហោអឺងកងភ្លើងក៏ឆេះឡើងភ្លឺពេញក្នុងបន្ទាយ ទើបគិតថា គ្រានេះប្រហែលចូចូគិតកលឧបាយទេដឹង ក៏នាំទាហានត្រឡប់ចេញមករកឡេវពី ទទួលជួបទឹងតៀវលៀវ, ទៅធូ, អ៊ុគិម, លីទៀន, ស៊ីឡង, ផាក់ជិន, ហៃហ៊ូទុន, ហៃហ៊ូអៀន, លើកទាហានវាយប្រសព្វខ្ទប់ទាំងសងខាងចូលមកគ្រប់ទាំង ៨ ទិស តាំងតែច្បាំងកាប់សម្លាប់គ្នាជាកោលាហល ឯទាហានដែលតៀវហ៊ុយលើកមកនោះសុទ្ធតែទាហានដើមចូចូ ក៏បែកចូលទៅរកនាយរបស់ខ្លួនទាំង ៨ កង សល់នៅតែទាហានស្និទ្ធខាងខ្លួនប្រហែល ៤០. នាក់ថ្វាយ តៀវហ៊ុយច្បាំងទំលាយពេញកម្លាំងទាំងសងខាង ហើយទាហានទាំង ៤០ ថ្វាយនោះដែកចេញទៅបាន ទើបគិតតែក្នុងចិត្តថា "ទឹងទៅរកឡេវពីប្តូរទៅស្រុកឈើដើរ ឯស្រុកហៃហ្វីវេលានេះក៏ទៅមិនបាន មុខជាទាហានចូចូទឹងនៅចាំស្ទាក់គ្រប់ផ្លូវ" ទើបនាំទាហានទាំងនោះឡើងទៅនៅលើកំពូលភ្នំបងអៀង ៗ

ឯឡេវពីនោះជិះសេះនាំទាហានលើកណូនតាមតៀវហ៊ុយទៅ លុះ

បានឮសំឡេងទាហានស្រែកហ៊ោអឺងកងទ័ពបន្ទាយច្របូកច្របល់មក ឡៅពី
ក៏ស្មានថា គៀវហ៊ុយចូលទៅប្លន់បន្ទាយនោះ តែនៅរិះគិតថាមុខជាច្រូច
នឹងធ្វើកលឲ្យអន្តរាយមិនខាន ទទួលក្រឡេកឃើញហែហួនបរពល
ចូលមក កាត់យកទាហានឡៅពីបានប្រហែលពាក់កណ្ដាល ឡៅពី
ឃើញដូច្នោះក៏ខឹងខ្លាំងណាស់ ញាក់សេះបរចូលទៅតយុទ្ធនឹងហែហួន
ទទួលហែហួនអៀនលើកទាហានវាយប្រសព្វចូលមកទៀត ឡៅពីក៏បរ
សេះចូលតតាំងច្បាំងដោះខ្លួន ទាហានឡៅពីក៏របួសស្លាប់ទៅខ្លះ វិល
ចូលទៅខាងកងទ័ពច្រូចខ្លះ សល់នៅទាហានដែលស្និទ្ធប្រហែល ៣០
ប្រាយ ឡៅពីក៏បរពលចូលតយុទ្ធវែកចេញទៅបាន គិតនឹងត្រឡប់ទៅ
ស្រុកសៀវផាយ ក៏ក្រឡេកទៅឃើញពន្លឺភ្លើងក្នុងស្រុកនោះឆេះសន្ធោ
ឡើង ឡៅពីក៏ដឹងថា កងទ័ពច្រូចចូលទៅវាយយកស្រុកនោះបាន ទើប
ត្រឡប់សេះនាំទាហានរត់ទៅផ្លូវស្រុកឈីជីវ ឃើញផ្លូវដែលបែកទៅខាង
ស្រុកហៃហ្វី មានទាហានច្រូចនៅស្កាត់ទទឹងផ្លូវជាច្រើន ឡៅពីគិតថាគ្រា
នេះច្រូចលើកទ័ពមកច្បាំងជាច្រើនណាស់ ខ្លួនអញនឹងគៀវហ៊ុយក៏បែក
ព្រាត់គ្នាទៅដោយខ្លួនហើយ នៅតែក្នុងអ៊ូដែលរក្សាគ្រប់គ្រងស្រុកហៃ
ហ្វីនោះ មិនដឹងជាបានសុខទុក្ខយ៉ាងណា ឡៅពីត្រិះរិះឃើញថាក្នួនសៀវ
បានផ្ដាំនឹងស៊ុនខៀនថា បើអាប់ចុនវេលាណាក៏ឲ្យចូលទៅចុះនឹងជួយទុក
ប្ដូរនោះ គ្រានេះខ្លួនអញថ្លោះការជាទម្ងន់ហើយ គួររត់ទៅអាស្រ័យ
នៅនឹងក្នួនសៀវសិនចុះ ដើម្បីនឹងបានសម្រាកខ្លួនគិតការតទៅទៀត
លុះត្រិះរិះហើយ ឡៅពីក៏នាំទាហានសេះទាំង ៣០ ប្រាយនោះ បរស្រុត

រួតតាមផ្លូវដ្រមង់ទៅស្រុកគីដីវ ទទួលប្រទះនឹងលើទៀនលើកទាហាន ស្កាត់ទទឹងពីមុខ ឡៅពីភ័យស្លុតមិនបានគិតប្រយុទ្ធនឹងតតាំងកំលះលាំង គេបោះដោះតែខ្លួន ១ រត់រួចទៅ ពោលទាហានទាំងអស់នៅក្នុងចំណោមទ័ព លើទៀនក៏ចូលទៅព័ទ្ធចាប់ទាហានឡៅពីទាំងអស់បាន ។

ខណៈកាលឡៅពីបំផាយសេះរត់ទៅនោះ បេះតែស្រុតទាំងយប់ទាំងថ្ងៃចម្ងាយផ្លូវប្រហែល ១ ពាន់សិន (៤០ គ.ម.) លុះទៅដល់ស្រុកធៀងដីវក៏ចូលទៅប្រាប់អ្នកចាំទ្វារថា យើងសុំចូលទៅជួបនឹងអ៊ូនថាំចៅ-ហ្វាយស្រុកដែលជាកូនអ៊ូនសៀវ ។ នាយទ្វារក៏នាំសេចក្ដីទៅជំរាបអ៊ូន-ថាំ ៗ មានសេចក្ដីត្រេកអរណាស់ក៏ចេញមកគំនាប់ហើយនាំខ្លួនឡៅពីចូលទៅ ។ ឡៅពីក៏នាំរឿងរ៉ាវអធិប្បាយឲ្យអ៊ូនថាំស្ដាប់គ្រប់ប្រការ ហើយថា យើងនឹងទៅអាស្រ័យនៅនឹងអ៊ូនសៀវជាបិតាអ្នក នឹងបានរិះគិតកំចាត់ចូចូជាពសត្រូវឲ្យបាន ។ អ៊ូនថាំបានស្ដាប់សព្វសេចក្ដីពីរឿងឡៅពីបែកទ័ពរត់មក ក៏ឲ្យមានចិត្តវិប្បយោគទុក្ខនឹកករុណាឡៅពីពន់ប្រមាណ ទើបឲ្យរៀបតុបាយទឹកជូនឡៅពីបរិភោគរួចក៏រៀបចំកន្លែងឲ្យឡៅពីនិទ្រា រួចអ៊ូនថាំតែងសំបុត្រទៅដល់បិតា តាមសំដីដែលឡៅពីនិយាយឲ្យបំរើនាំសំបុត្រនោះទៅមុន ហើយចាត់ទាហានជូនខ្លួនឡៅពីទៅជាក្រោយ ។ បំរើសេះក៏បានទៅដល់ស្រុកគីដីវយកសំបុត្រនោះចូលទៅឲ្យអ៊ូនសៀវៗមើលដឹងសេចក្ដីហើយក៏មានចិត្តសោមនស្សណាស់នាំពលយោធាចេញមកចាំទទួលឡៅពីក្រៅស្រុក លុះឃើញឡៅពីទៅដល់អ៊ូនសៀវចូលទៅដឹកដៃឡៅពីមក អ្នកទាំង ២ ក៏គំនាប់គ្នាតាមទំនៀម

ហើយនាំឡៅពីចូលទៅដល់ទីគេហដ្ឋាន អ៊ួនសៀវនិយាយនឹងឡៅពីថា អ្នកបានប្រើស៊ិនទៀនមកសុំកងទ័ពខ្ញុំ ទទួលបុត្ររបស់ខ្ញុំមានជម្ងឺបានជាខ្ញុំមិនបានលើកទ័ពទៅជួយអ្នកៗ កុំគប្បីតូចចិត្តនឹងខ្ញុំឡើយ ខ្ញុំមានសេចក្តីវិតក្កគិតដល់អ្នកជាដរាប ឥឡូវអ្នកខូចស្រុកនឹងប្ដូរទៅហើយក៏ជាការអភ័ព្វ ខ្លួនអ្នកមិនស្ទាប់បានមកឃើញមុខគ្នានឹងខ្ញុំ វេលានេះជាភ័ព្វអ្នកភ័ព្វខ្ញុំៗ មានសេចក្តីត្រេកអរពន់ប្រមាណណាស់ ៗ

ឡៅពីឆ្លើយថា គ្រានេះខ្លួនខ្ញុំក៏ព្រាអនាថា ដែលអ្នកមានមេត្តារាប់អានខ្លួនខ្ញុំៗក៏មានសេចក្តីត្រេកអរ សូមទទួលគុណអ្នកទុក តទៅមុខខ្ញុំនឹងបានតបស្នងសងគុណអ្នកវិញ កាលពីដើមខ្ញុំក៏បានដឹងច្បាស់ថា ចិត្តថ្លើមរបស់អ្នកមានធម៌សប្បុរសស្រួលយករាប់អាន តែងឧបត្ថម្ភសេនាទា-ហានមិនឲ្យអនាថខ្ញុំក៏គិតថា នឹងមកជ្រកកោនពឹងបុណ្យអ្នក ឲ្យអ្នកប្រើដើម្បីនឹងរិះគិតកំចាត់ប្ដូរចេញ ឥឡូវខ្ញុំបរាជ័យនឹងប្ដូររត់មកតែខ្លួន សូម្បីប្អូនរបស់ខ្ញុំទាំង២នាក់នឹងគ្រប់គ្រួ ក៏មិនបានដឹងជារស់ឬស្លាប់យ៉ាងណា ដែលខ្ញុំថ្ងោះការរត់មករកអ្នកតែម្នាក់ឯងដូច្នេះ មានសេចក្តីអាប់យសខ្មាសគេខ្លាំងណាស់ វេលានេះ ខ្ញុំក៏សុំផឹកទឹកពិកទ្ធសច្ចាសុំនៅធ្វើការនឹងអ្នកត្រាតែសំរេចកិច្ចការ ៗ អ៊ួនសៀវបានស្ដាប់ពាក្យឡៅពីក៏ឲ្យមានចិត្តអាណិតនឹងស្រឡាញ់ពន់ពេក ទើបចាត់ចែងគ្រឿងបរិភោគនឹងឧបភោគឲ្យជាច្រើន ហើយក៏តាំងតែឧបត្ថម្ភទំនុកបំរុងឡៅពីឲ្យនៅក្នុងស្រុកគីជីវ ៗ

(មានត)

ដំណើរតាមខ្យល់ក្នុងកន្ទារ:

# លោក ផេង-ជ្រីវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

ម្បក់ព្រៃគ្របដណ្ដប់ទីក្រុង តាំងពីប៉ុន្មានម៉ោងរួចមកហើយ មនុស្សក្នុងផ្ទះលោកអៃយ៉ាដ ហាក់ដូចដេកស្ងាត់ឈឹង ប៉ុន្តែដោយពន្លឺផ្កាយព្រាងៗ គេឃើញស្រមោលសស្នុង ៗ ដើរសន្សឹម ៗ ក្រោមដើមឈើក្នុងសួន ហើយលបចេញតាមទ្វារតូចមួយ ។ គឺប្រាកដជាមនុស្សក្នុងផ្ទះហ្នឹង បានជាពួកបក្សីដែលចិញ្ចឹមក្នុងទ្រុងគ្មានភ្ញាក់ផ្អើល ដោយដំណើរនៃជនទាំងពីរអ៊ឹបខ្ចិបសោះ ។

លុះចេញផុតដល់ក្រៅរបង អ្នកទាំងពីរខំដើរញាប់ជើង ៗ គេស្គាល់ច្បាស់ជានាងឡឺឡា ស្ដើងទ្រនាប់ ខទូរសំពត់ពណ៌ស នៅខាងមុខតាឡូប តាមរស្មីព្រះចន្ទចាំងមកពីចន្លោះពពក: នាងស្រីដើរមុន ៗ តាឡូប បណ្ដោយឲ្យឡឺឡាដើរទៅមុន ចម្ងាយប្រហែលពីរ-បីម៉ែត្រ គាត់ឈប់រួចផ្ទៀងស្ដាប់ដូចជាឮស្នូរជើងដើរពីក្រោយ ។

តាឡូបនឹកថា ប្រាកដជាមានមនុស្សឃើញ ! គេដើរតាមពីខាងក្រោយ ! លុះឈប់មួយសន្ទុះ ហើយដឹងថាឥតមានអ្នកណាតាមឡើយ ទើបគាត់ខំរូតដើរឲ្យទាន់នាងឡឺឡា ។

អ្នកទាំងពីរបានដល់កន្លែងមួយរំពេច ឃើញពាងអណ្ដូងស្អុំៗ រីកធំដោយយប់ងងឹត ។

ខណៈនោះ តាឡិបកាន់ដៃនាងឡីឡា នាំរហូតដល់គុម្ពស្ពុំទ្រមែន ដើមកូឡាបរួចឡើបដាក់ត្រចៀកថា

– នៅឲ្យស្ងៀម ចាំត្រង់កន្លែងហ្នឹងចុះ !

រួចសំឡឹងឆ្វេង សំឡឹងស្តាំក្នុងទីងងឹត ទើបគាត់លូពីរបីម៉ាត់ឆ្ពោះត្រាប់ ខ្លៅព្រៃឲ្យជាដំណឹង ៗ មានមនុស្សម្នាក់លេចឡើងឡើង ចម្ងាយបីបួន ម៉ែត្រ ចេញពីគុម្ពផ្កាមក យកសំពត់គ្របបិទមុខ ៗ តាឡិបដើរចូល ទៅជិត ៗ អ្នកនោះសួរថា:

អ្នកនៅឯណា ?

តាឡិបដំកបះដោយសំដីគួរសមថា:

– នុះ អ្នកឈរនៅ នុះ !

មនុស្សនោះសើចស្ងើញ ហើយនិយាយថា :

– អើ ប្រាកដមែន ! បើដូច្នេះ ហ៎ យករង្វាន់ឲ្យហើយទៅចុះ ! យើងស្រេចការហើយ !

គេដកហូតប្រាក់មួយស្បោងពីខោក្រវ៉ាត់ដែលមានកាំបិតស្នៀតមួយ សស្លាបទឹងកាំភ្លើងពីស្មាទ្បមួយព្យួរនៅនោះ ហើយហុចឲ្យទៅតាឡិប ៗ

តាឡិបទទួលយកប្រាក់ ប៉ុន្តែគាត់ដូចជានៅព្រមព្រួម ព្រោះ ដូចជាព្រួយខ្វល់អ្វីនៅនាគុម្ពឈើ ៗ ជាទីបំផុត គាត់ដាច់ចិត្តទៅនាំនាង ឡីឡាយកមកប្រគល់ឲ្យមនុស្សនោះ ៗ

ខណៈនោះ ភ្លើងកាមរាគឆេះឡើង អ្នកនេះក៏សង្រួបនាងនារីដូច

ជាសត្វស្រ្គុបអំពា ។ សាច់នាងក្រមុំក្តៅអ៊ុនៗ ផ្សាយក្លិនក្រអូប ជាហេតុឲ្យគេញ័រញាក់ដៃគេទាំងពីរ ។ គេទុនេកមុខនាងក្រមុំ, នាងស្រែកដោយសម្រែកគួរខ្លាចថា:

- ជួយផង តាឡិប !

នាងទើបនឹងដឹងច្បាស់ជារស្មី ។

- អាកំសាក !

- អាក្បត់ !

មុនដែលរស្មីកំរើកងើបខ្លួន មុក្តារនឹងអ៊ីស្មាអ៊ីលស្ទុះមកដល់នៅពុំមុខៗ នាងឡីឡាប្រឹង ហើយស្ទុះទៅឱបអ៊ីស្មាអ៊ីល ។ ទាំងយំហើយប្រាប់ថា:

ឱលោកនាយ! សូមកុំជឿ គេក្បត់ចិត្តខ្ញុំ?

អ៊ីស្មាអ៊ីលនាំនាងឡីឡាទៅប្រគល់ឲ្យតាឡិបឯអណ្តូង រួចត្រឡប់មករករស្មីវិញ ។

រស្មីដកកាំបិតស្នៀតចេញ ស្រែកទាំងកំហឹង ហើយលោតសំដៅគូសត្រូវ តែមុក្តារ រហ័សក្រែក ចាប់ដៃរស្មីជាប់ កាំបិតក៏ធ្លាក់ចុះទៅដី:

- អាឯងឃ្លាំចាំ !

អ៊ីស្មាអ៊ីលនិយាយដោយសំដីយ៉ាងម៉ឺងម៉ាត់ថា

- ទេ រស្មី មិនគឺជាការឃ្លាំចាំឡើយ ! អញគ្រាន់តែចង់ដឹងការកំសាកផងអាឯងទេតើ ៗ អញអាចសម្លាប់អាឯងឥឡូវដូចក្តែ ប៉ុន្តែណ្ហើយ អញបន្ទូរឲ្យអាឯងផ្សងក់សនាចុងក្រោយ ក្នុងការប្រយុទ្ធតាមច្បាប់ ។

អ៊ីស្មាអ៊ីលចាប់ពីស្ទូវឡើ រួចប្រាប់ទៀតថា:

— អាងនឹងឃើញឬទេ ដើមត្នោតដុះនៅក្បែរកំពែងនុះ កាលណាទៅដល់កន្ទែងនុះ យើងបាញ់គ្នា ចំប្រឹងប្រែងឲ្យមែនទែន ។

នាងឡូឡាស្រែកហៅដោយសំដីព្រួយខ្លាំងថា:

— អ៊ីស្មាអ៊ីល !

ប៉ុន្តែ ជនទាំងពីរបេះតែដើរជម្រើងកំពែងនោះ គឺនៅក្រោយកំពែងនោះហើយដែលនាងឡូឡាបានស្តាប់ទំនាយរបស់យាយមេអាប ។

ស្នូរបាញ់ពីរកាំភ្លើងទម្លុះរហស្សភាពនៃរាត្រី ។

មួយស្របក់ក្រោយមក គេឃើញអ៊ីស្មាអ៊ីលដើរត្រឡប់មកវិញ ។

ខណៈនោះ នាងឡូឡាដែលមិនអាចទឹងទប់នូវសេចក្ដីអរបាន ក៏ស្ទុះទៅឱបគូស្នេហ៍ហើយនិយាយថា:

— អ៊ីស្មាអ៊ីល ! អ៊ីស្មាអ៊ីល !

នាងយំផង សើចផង ប៉ុន្តែមានគំនិតព្រួយមួយកើតឡើងក្នុងចិត្ត ។

— សូមបងកុំជឿថាខ្ញុំស្រឡាញ់ក ខ្ញុំស្មានជាបងទេតើ ដែលឲ្យខ្ញុំមកចួបនៅទីនេះ !

អ៊ីស្មាអ៊ីលឥតមាននិយាយថាអ្វី ។ គេចាប់នារីអោបហើយផ្ទេក់មាត់នាង ។ គូស្នេហ៍ទាំងពីរផ្ទេក់គ្នាទៅវិញទៅមកមួយស្របក់ នៅក្រោមស្មើព្រៃះឫក្សេស ។

* * *

## វគ្គទី ៧

# ស្រមោលនៃសេចក្ដីទុក្ខ

ព្រឹកឡើងនៃយប់ដែលមានរឿងហេតុ លោកតាអៃយ៉ាដកំពុងតែត្រួតត្រាមើលតាឡិបដែលបំពេញកិច្ចការ គឺថែរក្សាកូនសេះទើបនឹងកើតនៅនាកណ្ដាលទីធ្លាផ្ទះក្រាលថ្មថ្ម លោកស្រាប់តែក្រោកឡើងនឹងសំឡេងបរិទេវស័ព្ទនឹងសូរមនុស្សដង្ហែសពតាមផ្លូវមុខផ្ទះ ។ លោកស្ទុះចេញទៅមើលបានឃើញមនុស្សប្រុសបួននាក់សែងក្ដារម្ឈូសគ្របសំពត់ស ។

មានមនុស្សជាច្រើនពាក់អាវស្លៀកខោខ្មៅដើរពីខាងមុខ ដែលលោកតាអៃយ៉ាដអាចសំគាល់បានថាជាពួកជនក្នុងផ្ទះ នៃអ្នកមានបណ្ដាស័ក្តិគួរសម ។

លោកសួរអ្នកដង្ហែថា:

— ឈឺអី បានជាស្លាប់ ?

គេឆ្លើយដំណបមកវិញថា:

— ទ្រព្រះគុណកាអ៊ីដ គឺម្ចាស់យើងខ្ញុំ មានអ្នកណាគេសម្លាប់នៅក្បែរអណ្ដូងទឹក ។

លោកតាអ៊ីដបង្គាប់ថា :

— ចូរបើកមុខឲ្យអញមើលបន្តិច !

អ្នកសែងបន្ទន់ដង្គន់ ល្មមឲ្យក្ដារម្ឈូសតាំងនៅតាមកំពស់ធម្មតា រួចទាសៈម្នាក់បើកសំពត់គំរបចេញ ។ មុខស្លេមលេចឡើងនៅកណ្ដាលថ្ងៃ ៈស្ងួកស្ងាំងដោយអានុភាពនៃសេចក្ដីស្លាប់ ។ មានរន្ធតូចមួយត្រង់

ថ្ងាស់ ជាចន្លោះភ្នែកទាំងពីរចង្អុលប្រាប់កន្លែងដែលគ្រាប់កាំភ្លើងចូលតាមនោះ ។ គ្រាប់ដែកនេះរត់តាមខួរ ហើយទំលាយធ្លាងក្បាល ដ្បិតគេឃើញមានឈាមកកនៅត្រង់កន្ទួតអួង ។

លោកតាអែយ៉ាដព្រឺព្រួចពេក តែអាការទឹកមុខមិនបានក្បត់គំនិតលោកខាងក្នុងឡើយ ។ លោកគំនាប់សព ហើយឲ្យពរថា :

— សូមឲ្យសន្តិសុខនៃព្រះអាឡស់ស្ថិតនៅនឹងអ្នកនេះ !

ក្បួនដង្ហែក៏ធ្វើដំណើរតទៅទៀត ។

ខណៈដែលលោកបែរខ្លួនដើម្បីចូលផ្ទះ លោកបានឃើញអ៊ីស្មាអ៊ីលឈរនៅពីមុខ ។ អ្នកកំឡោះមុខស្លេក មិនកំរើក ឈរសំឡឹងសព ។ លោកសំឡឹងមុខកូនប្រុសសព្វៗ មិនចេញស្តី ប៉ុន្តែភ្នែកលោកមើលធ្លុះដល់ពោះវៀន ។ អ៊ីស្មាអ៊ីលយល់ច្បាស់ថា ឪពុកខ្លួនដឹងនូវកលហកម្ម នឹងការសម្ងាត់ នៃមរណភាពរបស់ស្ត្រីម្នាក់ពេលនេះប្រាកដហើយ តែគ្រាន់តែមិនដឹងថា បណ្តាលមកពីហេតុអ្វី ។ ជាទីបំផុតលោកប្រាប់ថា:

— ត្រឡប់ចូលទៅវិញ កូន !

លោកអែយ៉ាដបិទទ្វារពីក្រោយគេ ។ ឮលោកថាតិច ៗ :

— ព្រះអាឡស់ធំណាស់ ព្រះអង្គដឹងទាំងអស់ នូវកិច្ចការដែលគេធ្វើ !

រួចធ្វើព្រងើយ ច្បូតពុកចង្កាទន់ល្មើយដែលលាងរាល់ព្រឹកក្នុងទឹកក្រអូប លោកគិតតែមើលតាឡបដែលកំពុងថែកូនសេះទើបនឹងកើត ។

* * *

ពេលនោះ កងទាហានត្រូវតែដែលគេប្ដឹងអំពីឃាតកម្មដែលរស្មីមេបនអាប់ដាឡះ បានទទួលរងបាបគ្រោះ ក៏នាំគ្នាធ្វើរឿងនោះឲ្យលេចច្បាស់ឡើង ។

មួហាម្មេដណាប៉ីប៊ី ជាមនុស្សប្រចណ្ឌអំណាចក្នុងការត្រួតត្រាករ័ទ័ព ក្ដៅក្រហាយចង់រកអ្នកដែលប្រព្រឹត្តបទល្មើសឲ្យឃើញ ព្រោះលោកចូលចិត្តថា ការណ៍នេះ គឺជាទោសផ្លូវនយោបាយ ។ ដ្បិតចរស្មីមេបនអាប់ដាឡះ ស្លាប់ក្នុងយប់ថ្ងៃដែលលោកបានប្រគល់ការជំនួបកិច្ចសម្រាមនៃរដ្ឋាភិបាលក្នុងស្ដង់ទីណុប គេទើបនឹងទទួលមុខងារខាងការពាក់កង់ទ័ពក្នុងក្រសួងការស់ ការពប៉ូលី ។

នាយទាហានត្រួតពី ហៅអនុសេនីយ៍ឯករបស់ខ្លួនមក គឺជានាយទាហានម្នាក់ដែលធ្លាប់ចាត់ចែងព្រឹត្តិការណ៍ខាងក្នុងក្រវែល ។ គឺជាមនុស្សចិត្តត្រជាក់គិតអ្វីហើយមិនរញ៉េរញ៉ៃ បេះទប់កំហឹងរបស់ខ្លួន ។ ក្នុងការកត់ហេតុរឿង លោកតែងមាននយោបាយបន្ធូរមានវិជ្ជាជម្មុំងមាត់ខាងពិនិត្យសំគាល់ មានសេចក្ដីក្លាហានយ៉ាងដាច់ខាត គិតធ្វើអ្វីតែងសម្រេច ទោះបីការណ៍នោះចង្អៀតដូចម្ដេចក៏ដោយ ។ លោកនេះស្គាល់យ៉ាងអស្ចារ្យនូវល្បិចក្រវេចក្រវៀន នូវកិច្ចពុតត្បុតនូវការលាក់កំនួច ហើយជាក់ច្បាស់ជាងគេ នូវរហស្សការញេីតញេីមនៃពួកអារ៉ាប់ ដ្បិតលោកធ្លាប់នៅក្នុងប្រទេសពជជាយូរអង្វែង ហើយបានឡើងឋានស័ក្តិក៏ដោយសារកិច្ចខាងលើនេះ ។

លោកអនុសេនីយ៍ចាប់ធ្វើការអង្កេតភ្លាម ។ លោកអញ្ជើញទៅ

កាន់ផ្ទះស្មៀមបេនអាប់ដាឡះតែម្នាក់ឯង លោកកាំភ្លើងក្នុងហោប៉ៅយ៉ាង ប្រយ័ត្នមិនឲ្យអ្នកណាឃើញ ។ លុះទៅដល់មុខផ្ទះ បរិទេវនសព្ទ សំឡេងសូត្រធម៌នៃពួកមាស: សំឡេងយំស្រែកនៃពួកស្រីៗ ធ្វើឲ្យលោក ចូលចិត្តថាសពមិនទាន់យកទៅកប់នៅឡើយ ។ លោកមិនទាន់បាន ធ្វើការអង្កេត ព្រោះតាមច្បាប់ធម៌ក្នុងវង់ គេហាមផ្ដាច់មិនឲ្យអ្នកណាពាល់ ក្រដាស ធ្វើកិច្ចការអ្វី ប៉ះសំលៀកបំពាក់ គឺថាវត្ថុផ្សេងៗសពទាំងអស់ ក្នុងវេលាដែលបុគ្គលមិនទាន់ចេញផុតពីផ្ទះ ទៅកាន់កន្លែងប៉ាឆា ។ ទោះបី ស្លាប់ហើយក៏ដោយ ពេលដែលសពនៅលើផ្ទះ គេទុកដូចជានាយ ចៅហ្វាយនៅរស់ ។

.លោកអនុសេនីយ៍ឯកគិតថា បើគ្មានសំបុត្រស្នាមអ្វីមួយរបស់ស្មៀម ដែលអាចនាំជួយបំភ្លឺផ្លូវនៃការអង្កេត ដោយហោចទៅ លោកអាចសួរ ពួកលាកុដិក (មនុស្សល្ងើល្ងើ) ក៏សឹងបាន ។ កាលដែលលោកទៅដល់ កន្លែងដែលពួកស្រីៗ កំពុងយំខ្សឹកខ្សួល លោកមិនមានរំភើបដោយការសោយ សោកនោះឡើយ ព្រោះលោកដឹងថាស្រីទាំងនោះយំដោយគេជួល ផ្សែត មុខងារគ្នាត្រូវតែយំដូច្នេះ ។ លោកចូលទៅគំនាប់សពស្មៀមដែលគេទើប តែបំពាក់ខោអាវថ្មី ខាងក្រោយដែលគេយករូបបុគ្គលទៅបំអាសទឹកអប់ៗ លុះធ្វើការកិច្ចហើយ លោកដើរហួសទៅផ្លាខាងក្នុង ដែលមានពួក លាកុដិកនៅនោះ ។ លោកប្រទះទាសីមួយក្លាមជាទីគាប់ចិត្ត ផ្សែត លោកនឹកថាការល្ងើល្ងើនឹងការមិនដឹងក្តីរបស់វា មុខតែនាំឲ្យវានិយាយ មិនបានកុហក លោកក៏សួរទាសីនោះថា:

– ថៃម្សិលមិញ ឯងមានឃើញមនុស្សប៉ៃឡែកឬទេ? តើមានអ្នកណាមកលេងនឹងចៅហ្វាយឯងឬទេ?

នាងតាសីភ័យដោយឃើញឯកសណ្ឋាននឹងគ្រឿងឥស្សរិយយសមាសរបស់លោកឧនុសេនីយ៍ឯក ហើយខ្លាចសាសន៍តួរតឹងដែលគេនាំគ្នាទុកដូចជាមហាចោរ ក៏មិនហានឆ្លើយ ។

លោកអនុសេនីយ៍ឯកនិយាយកំហែងថា:

– បើនាងឯងមិនឆ្លើយ អញឲ្យគេចាប់ដាក់គុកភ្លាម នាងឯងមុខជាត្រូវគេរ៉ាយកក់រហូតបែកឈាម ហើយគេហូតពោះវៀនចេញដូចទន្សាយ ។ បើនាងឯងនិយាយត្រង់ នាងឯងរួចខ្លួន ។

ការកំហែងនេះធ្វើឲ្យតាសីកំសត់ជាចប់ចិត្តព្រមឆ្លើយ ។ នាងប្រាប់ថា:

– ពីម្សិលមិញ ខ្ញុំឥតបានឃើញអ្នកណាមកទេ! ខ្ញុំឃើញតែតាឡុបជាតាសៈបំរើលោកតាអៃយ៉ាដម្នាក់ឯងមក ។

– អស់ហើយឬ?

– ចា៎! លោកម្ចាស់ អស់ហើយ!

– ល្អ!

លោកអនុសេនីយ៍ឯងអ្ងុកមិនថា ។ វេលានោះ លោកចោទសួរអ្នកបំរើឯទៀតជាច្រើន តែគ្រាន់យកតែនាម រួចលោកប្រញាប់ទៅឯផ្ទះលោកតាកាអ៊ុជ ។ ចម្លើយរបស់នាងតាសី ដូចជាបើកការកំបាំងជូនលោក ។

ឈ្មោះតាឡប ! មនុស្សអ្នកបំរើលោកតាអៃយ៉ាដ ! លោកនឹកដល់កាលដែលលោកទៅលេងឯផ្ទះលោកតាកាអ៊ីដជាមួយនឹងចៅហ្វាយនាយរូបលោកនឹកមួយរំពេចដល់អាការថ្លាំងថ្នាក់ចិត្ត នឹងជាសត្រូវរបស់អ៊ីស្មាអ៊ីល កាលគេប្រាប់ថាសៀរបេនអាប់ដាឡះ ចូលជាជំនួយដល់កងទ័ពតួរគីហើយ ។

លោកអនុសេនីយ៍នឹកទៀតថា:

— អើ ! មែនហើយ ! មែនហើយ ! អញប្រហែលឃើញផ្លូវហើយ?

* * *

ទ្វារផ្ទះលោកអៃយ៉ាដះបើកចំហ ។ លោកអនុសេនីយ៍ឯកចូលដល់ទីធ្លាក្រាលឥដ្ឋថ្មើមថ្មូ បានប្រទះទាសៈម្នាក់ លោកបង្គាប់ឲ្យគេនាំទៅរកម្ចាស់ផ្ទះ ។

លោកតាអៃយ៉ាដ មានកូនប្រុសទាំងពីរនៅសងខាង កំពុងមើលធម៌កូរ៉ង់ក្នុងបណ្ណាល័យ ពន្លឺរស្មីយ៉ាងត្រជាក់ចាំងចូលតាមបង្អួច ក្លិនខ្លឹមចន្ទន៍ក្រអូបពេញទាំងបន្ទប់ ។ គឺហាក់ដូចគេមានតែចិត្តបរិសុទ្ធ នឹងសុខភាពយ៉ាងបរិបូណ៌នៅក្នុងផ្ទះនោះ ។

លោកអនុសេនីយ៍ឯកនិយាយថា:

— កាអ៊ីដ ខ្ញុំមានការត្រូវធ្វើអង្កេតនៅផ្ទះលោកអំពីមរណភាពសៀរបេនអាប់ដាឡះ ។

លោកតាកាអ៊ីដឆ្លើយថា:

— ក្នុងផ្ទះយើង មានតែសេចក្តីបរិសុទ្ធ ។ (មានត)

## រឿងបល្ល័ង្កទិព្យ សាមសិបពីររឿង

រឿងព្រេងតំណាល

### លោកសមិន មូត្យនជិមៈ តែង

### លោករ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

## និទាននៃរូបទេពនិម្មិត ទីប្រាំពីរ

មានថ្ងៃមួយទៀត ព្រះមហាក្សត្រភោជៈ ទ្រង់យាងទៅជិតបល្ល័ង្កទិព្យនោះ ដើម្បីនឹងទទួលរាជាភិសេក ។ ស្រាប់តែរូបទេពនិម្មិតទីប្រាំពីរពោលថា "មហារាជភោជៈ, សូមទ្រង់ព្រះសណ្ដាប់, ស្ដេចអង្គណាដែលអាចគង់លើបល្ល័ង្កទិព្យនេះបាន លុះតែស្ដេចអង្គនោះបានឧបត្ថម្ភជីវសត្វទាំងអស់ ដូចជាព្រះមហាក្សត្រវិក្រមាទិត្យ" ។ មហារាជភោជៈ សណ្ដាប់នូវវាចានៃរូបទេពនិម្មិតទីប្រាំពីរហើយ ទ្រង់មានព្រះបន្ទូលសួរទ្រង់ព្រះទៅរូបទេពនិម្មិតនោះវិញថា "តើព្រះបាទវិក្រមាទិត្យទ្រង់បានជួយឧបត្ថម្ភជីវសត្វយ៉ាងណាខ្លះ?" ។

រូបទេពនិម្មិតនោះក្រាបបង្គំទូលមហារាជភោជៈថា: "សូមទ្រង់ព្រះសណ្ដាប់អំពីចរិយាជាវីរភាពនៃព្រះបាទវិក្រមាទិត្យ ដូចតទៅនេះ៖

ព្រះមហាក្សត្រវិក្រមាទិត្យ ទ្រង់បានសោយរាជសម្បត្តិនៅទីក្រុងអវន្តី ។ មានមួយថ្ងៃ ទ្រង់មានព្រះរាជបញ្ជាទៅកាន់អាមាត្យថា: "ចូរអ្នកត្រាច់ទៅកាន់ប្រទេសផ្សេងៗ ហើយដល់អ្នកវិលត្រឡប់មកវិញ ចូរអ្នកមកប្រាប់យើងអំពីស្ថានការណ៍ដែលអ្នកបានឃើញកុំខាន" ។

អាមាត្យបានទទួលព្រះរាជនុញ្ញាតហើយ ក៏ត្រាច់ទៅកាន់ប្រទេសផ្សេងៗ ទៅដល់ប្រទេសកស្មិរ ។ នៅទីនោះ មានសេដ្ឋីម្នាក់បានជីកស្រះមួយធំ តែគ្មានទឹក ។ តមក គេបានឮសំឡេងស្រែកកណ្តាលអាកាសថា "បើមានឧត្តមបុរសណាម្នាក់ បានបូជារូបកាយ ទើបស្រះនោះមានទឹក" ។ ដល់បានឮសំឡេងនោះ សេដ្ឋីក៏បានយកមាសទម្ងន់ ១០ នាឡិមកលញ់ធ្វើជាមនុស្ស ហើយព្យួរនៅមាត់ស្រះ រួចបានចាក់អក្សរលើសិលាចារិកថា "បើអ្នកណាមួយ អាចហ៊ានបូជារូបរបស់ខ្លួនទុំទឹងធ្វើអំណោយនូវមនុស្សមាសនោះ" ។ បណ្តាមនុស្សទាំងអស់ដែលទៅកាន់ទីនោះ, គ្មានអ្នកណាម្នាក់ព្រមសុខចិត្តធ្វើពលិកម្មរូបរបស់ខ្លួនសោះឡើយ, ដោយមិនមានកំឡាំងល្មមនឹងធ្វើបានមនុស្សទាំងអស់នោះក៏ថយវិលត្រឡប់ទៅកាន់ទីដទៃរៀងរាល់ខ្លួន ។

អាមាត្យរបស់ព្រះមហាក្សត្រវិក្រមាទិត្យ ដល់បានឃើញរឿងរ៉ាវទាំងនោះ ក៏វិលត្រឡប់ទៅកាន់ក្រុងអវន្តី ហើយយកសេចក្តីទៅក្រាបបង្គំទូលទ្រង់សព្វគ្រប់ប្រការ ។ ព្រះបាទវិក្រមាទិត្យទ្រង់ព្រះសណ្តាប់អាមាត្យពណ៌នាអំពីរឿងប្លែកអស្ចារ្យ ទ្រង់ក៏មានព្រះរាជបំណងទៅកាន់ទីនោះ ហើយទ្រង់ក៏បានយាងទៅកាន់ប្រទេសកស្មិរ ។ ដល់ពេលសាយណ្ហសម័យ, ទ្រង់ក៏យាងទៅកាន់ស្រះធំនោះ, ដោយក្លែងព្រះអង្គមិនឲ្យគេស្គាល់, រួចទ្រង់ថ្វាយបង្គំព្រះអាទិទេព ។ កន្លងពេលបទោសកាល (យប់) ទ្រង់បានធ្វើអញ្ជលីរួចមានព្រះបន្ទូលទៅកាន់ព្រះអាទិទេពថា "ឱព្រះអាទិទេព ម្តេចក៏ព្រះអង្គធ្វើឲ្យខ្ញុំខ្មាសគេ ហើយខ្ញុំប្រកាស

ថា "ព្រះអាទិទេពដែលសោយឆ្អែតស្កប់ស្កល់តែលោហិតរបស់មនុស្ស ដែលគេយកមកធ្វើពលិកម្ម, ត្រូវតែសោយលោហិតរបស់ខ្ញុំកុំខាន" ។ ក្នុងពេលនោះ ព្រះបាទវិក្រមាទិត្យទ្រង់ក៏ហូតព្រះខ័នថ្វាកាត់ព្រះសូរង មួយរំពេច, តែព្រះអាទិទេពបានយកព្រះសូរងនៃព្រះបាទវិក្រមាទិត្យ មកតភ្ជាប់នឹងព្រះកាយហើយ ក្រាបបង្គំទូលទ្រង់ថា 'សូមព្រះអង្គ ទ្រង់គង់ជាសុខចុះ, សូមទ្រង់មានព្រះរាជបំណងចង់បានអ្វី យើងខ្ញុំនឹង បំពេញតាមព្រះរាជហឫទ័យ" ។ ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលតប ទៅនឹងព្រះអាទិទេពថា "ឱ ព្រះអាទិទេព, បើព្រះអង្គទ្រង់សព្វព្រះរាជ-ហឫទ័យនឹងយើង, សូមព្រះអង្គទ្រង់យកទឹកមកបំពេញស្រះធំនេះ ដើម្បី ជាប្រយោជន៍ដល់សត្វលោកទាំងអស់" ។

ព្រះអាទិទេពពោលថា "ព្រះអង្គមានព្រះទ័យស្មោះស្ម័គ្រនឹងព្រះ រាជករណីយកិច្ចដ៏មាំមួន, យើងព្រមព្រៀងអនុគ្រោះទ្រង់តាមព្រះរាជ-បំណង ។

លុះដល់បច្ចូសសម័យព្រឹកឡើង, ពួកប្រជាជននៅនគរកស្មិរបាន ឃើញស្រះធំមានទឹកពេញ ។

រូបទេពនិម្មិតទីប្រាំពីរពោលបញ្ចប់ថា: "ឱ មហារាជភោជៈ នេះ ហើយ ដែលជាព្រះរាជចរិយាដ៏វិសេសនៃព្រះបាទវិក្រមាទិត្យ ក្នុងកិច្ច ស្រោចស្រង់ជីវិតសត្វទាំងអស់ ។ បើទ្រង់មានព្រះរាជចរិយាបែបនេះ ទើបទ្រង់អាចគង់លើបល្ល័ង្កទិព្វនេះបាន ។ មហារាជភោជៈ លុះទ្រង់ ព្រះសណ្ដាប់នូវវាចានៃរូបទេពនិម្មិតទីប្រាំពីរ ហើយទ្រង់ព្រះតម្រិះថា

ទ្រង់មិនដែលមានសកម្មភាពបែបនេះសោះឡើយ, ហើយទ្រង់ក៏ព្រួយព្រះរាជហឫទ័យពន់ពេកក្នុងថ្ងៃនោះ ។

*

*　*

## និទាននៃរូបទេពនិម្មិតទីប្រាំបី

ពេលក្រោយតមក, មហារាជភោជៈទ្រង់ព្រះពស្ត្រសម្រាប់រាជ្យ, រួចទ្រង់យាងចូលទៅជិតបល្ល័ង្កទិព្វ ។ ក្នុងពេលនោះរូបទេពនិម្មិតទីប្រាំបីពោលថា «បពិត្រព្រះមហារាជភោជៈ ស្តេចអង្គណាមួយបំពេញសេចក្ដីបំណងអ្នកដទៃ ដូចជាព្រះមហាក្សត្រវិក្រមាទិត្យ, ស្តេចអង្គនោះអាចគង់លើបល្ល័ង្កនេះបាន ។

មហារាជទ្រង់មានព្រះបន្ទូលសួរថា «តើមហារាជវិក្រមាទិត្យនេះទ្រង់បានបំពេញបំណងអ្នកដទៃយ៉ាងណាខ្លះ? រូបទេពនិម្មិតនោះក្រាបទូលថា «សូមព្រះមហារាជទ្រង់ព្រះសណ្ដាប់, ទូលបង្គំនឹងក្រាបទូលដូចតទៅនេះ ៖

ព្រះមហាក្សត្រវិក្រមាទិត្យ ទ្រង់សោយរាជសម្បត្តិនៅក្រុងអវន្តី ។ នៅក្រុងនោះមានបុរោហិតរបស់ទ្រង់ឈ្មោះ ត្រីបុរាការ (Tripurâkâr) មានបុត្រាម្នាក់ឈ្មោះ កមលាការ (Kamâlâkâr) បុត្រនេះល្ងង់ជាទីបំផុត ។ បុរោហិតនោះ ដោយយល់ថាបុត្រាខ្លួនល្ងង់ដូច្នោះ, ក៏ចេះតែគិតក្នុងចិត្តជានិរន្តរ៍ ។ មានសម័យថ្ងៃមួយ បុរោហិតនោះបានឲ្យបុត្រានោះអង្គុយជិតខ្លួន ហើយក៏ទូន្មានថា ៖

"ឱ កូនអើយ, ចូរកូនស្ដាប់ឪពុក, នៅក្នុងសង្សារវដ្ដ ជីវសត្វទាំង បានមកកើតជាមនុស្ស លុះត្រាតែជីវសត្វនោះមានគុណធម៌ក្នុងខ្លួន ។

" ជីវសត្វដែលនឹងបានរូបកាយជាមនុស្ស ឬ មកកើតជាជាតិមនុស្ស លុះត្រាតែសត្វនោះបានរៀននូវវិជ្ជាសាស្ត្រ ។ បើមិនដូចនោះទេ សត្វដែលមានទ្រង់ទ្រាយជាមនុស្សនោះ ដោយកិច្ចត្រឹមតែឥរិយាបថ គឺ ដេក, អង្គុយ, ឈរ, ដើរ, បរិភោគ ។ល។ ប៉ុណ្ណោះ គេមិនអាចយល់ច្បាស់ថា ជាមនុស្ស ឬក៏ជាសត្វតិរច្ឆានទេ ព្រោះសត្វតិរច្ឆានក៏មានការប្រព្រឹត្តិយ៉ាងនេះដែរ មនុស្សនោះគេទុកដូចជាសត្វតិរច្ឆាន ។ ចំណេះរបស់សត្វមិនមែនចំណេះរបស់មនុស្សទេ ។ ព្រោះហេតុដូចនេះ អ្នកណាដែលគ្មានចំណេះរបស់មនុស្ស, អ្នកនោះមិនមែនសត្វតិរច្ឆានឬ? ។ កូនឯងដឹងទេ ចំណេះ (វិជ្ជា) ប្រសើរជាងរាជសម្បត្តិនៃព្រះមហាក្សត្រិយ៍, ព្រះមហាក្សត្រគេគោរពចំពោះតែក្នុងប្រទេសដែលទ្រង់សោយរាជសម្បត្តិ, មនុស្សមានវិជ្ជាគេគោរពមិនមែនតែត្រឹមក្នុងប្រទេសរបស់ខ្លួនទេ ប្រទេសឯទៀតក៏គេគោរពដែរ ។ ចូរកូនដឹងថា វិជ្ជាសម្បត្តិវិសេសជាងសម្បត្តិដែលនៅក្នុងសង្សារ; ភោគសម្បទនេះគេខ្លាចចោរលួច, ភ្លើងឆេះ, អាជ្ញាស្ដេចរឹបអូស ។ វិជ្ជាសម្បត្តិគេមិនខ្លាចខូចខាតបែបនេះទេ ។ ហើយបើគេចាយសម្បត្តិដែលមានហើយ, សម្បត្តិនោះក៏អន្តរាយអស់ ។ ចំណែកខាងវិជ្ជាសម្បត្តិ បើទុកជាចាយយ៉ាងណាក៏ដោយ, ប្រាជ្ញាស្ថិតនៅជានិរន្តរ៍មិនចេះអស់ ។ គេមិនអាចយកសម្បត្តិថ្មីមកជំនួសសម្បត្តិចាស់, តែវិជ្ជាសម្បត្តិស្ថិតនៅឥតប្រែប្រួល ។

ត្រូវកូនគិតថា " វិជ្ជាជាគ្រឿងអលង្ការដ៏ឧត្តមជាងគ្រឿងអលង្ការទាំងអស់ក្នុងលោក ព្រោះថាគ្រឿងអលង្ការនេះ ក៏ចាំងថែងសមតែក្មេងនឹងពួកជំទង់, ត្រង់មនុស្សចាស់មិនសមទេ ។ វិជ្ជាមានរស្មីភ្លឺថែងចាំងគ្រប់វ័យទាំងអស់ ។ ឱ គួរឲ្យអនិច្ចា, កូនឯងគ្មានវិជ្ជានេះសោះឡើយ, ព្រោះហេតុដូចនេះ ជីវិតភាពរបស់កូនឯង ទុកដូចជាស្លាប់ ។ បើគេស្ទង់មើលនូវលទ្ធផល, ឪពុកពោលថា របស់ទាំងបីយ៉ាងគឺ ' គ្មានកូនប្រុស ១, មានកូនប្រុសតែស្លាប់ទៅវិញ ១, មានកូនប្រុសបានរួចពីសេចក្ដីស្លាប់ហើយតែរស់នៅក្នុងលោកប្រកបដោយសេចក្ដីល្ងង់ខ្លៅ ១ ។ បើកូនប្រុសមានលក្ខណៈបែបនេះ, ការដែលគ្មានកូនប្រសើរ, ថាបើមានគួរសម្លាប់ចោលល្អជាង ។ បើកូនប្រុសល្ងង់ខ្លៅរស់នៅក្នុងពិភព-លោកមិនជាការល្អសោះឡើយ ។ ព្រោះហេតុដូចនេះ បើកូនប្រុសមិនបានគិតនូវជោគវាសនារបស់ខ្លួនក្នុងអនាគតទេ ហើយទទួលមរណ-ភាពទៅ, ទុក្ខរបស់ឪពុកដែលកើតឡើងដោយសេចក្ដីស្លាប់កូនឯងនេះមាន តែរយៈវេលាមួយខែ ឬពីរខែប៉ុណ្ណោះ ។ ចំណែកកូនប្រុសដែលល្ងង់ខ្លៅអាចធ្វើឲ្យបិតាមាតាកើតទុក្ខជាអនេកប្បការ ។ ព្រោះហេតុនេះ បានជាអញថា " ការសម្លាប់កូនដែលល្ងង់ខ្លៅប្រសើរជាង " ។

កមលាការបានស្ដាប់ឱវាទនៃមាតា ក៏ធ្វើដំណើរទៅកាន់ប្រទេសដទៃ ដើម្បីនឹងសិក្សារៀនសូត្រនូវចំណេះវិជ្ជាទាំងឡាយ ។ បុរសនោះបានទៅដល់រដ្ឋកស្មិរៈ ។

នៅក្នុងនគរនោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះ ចន្ទ្រមូលី (Chandramauli) ជាអ្នកចេះសិល្បសាស្ត្រ ។ កមលាការបាននៅពឹងពាក់អាស្រ័យព្រាហ្មណ៍នោះដើម្បីនឹងយកលោកជាគ្រូបាអាចារ្យ ។

ចន្ទ្រមូលីព្រាហ្មណ៍ មានសេចក្ដីពេញចិត្តនឹងកមលាការ ក៏បានឲ្យទៅបុរសនេះនូវសិទ្ធិមន្ត្រ (Siddhimantra) នៃព្រះនាងទេវធីតា, សរស្វតី (Sarasvati) (នាងទេវធីតាខាងផ្នែកសិល្បៈ) ។

ដោយអានុភាពនៃសិទ្ធិមន្តនេះ កមលាការទៅជាពហុសូត្រ ចេះដឹងវិជ្ជាផប់ប្រាំបី (សូមអានត្រង់និទាននៃរូបទេពនិមិត្តទីបួន) ។

ក្រោយមក កមលាការ បានអញ្ជើញទៅកាន់ទីក្រុងកញ្ចិ (Raircî) ។ នៅទីនោះ, លោកបានជួបប្រទះនឹងនាងកញ្ញាម្នាក់នាមនាង នរមោហិណី (Naramohini) (ប្រែថានារីដែលធ្វើបុរសឲ្យវង្វេង) ។ នាងនេះស្ថិតនៅគេហដ្ឋានតែម្នាក់ឯង, គ្មានបុរសណានៅជាមួយនាងទេ ។ ទ្វារគេហដ្ឋានរបស់នាងបើកជានិរន្តរ៍, ជាងធ្វើគេហដ្ឋាននោះគឺ រាក្សសៈ (អារក្ស) ឈ្មោះ ទុរជ័យ (Durjaya) ។

រាក្សសៈនេះធ្លាប់មកកាន់ទីនេះរាល់ថ្ងៃក្នុងពេលព្រលប់ ។ បើជនណាចូលទៅក្នុងគេហដ្ឋាននោះ ហើយឈប់កាន់កាំងស្មារតី ដោយក្រឡេកទៅឃើញនាងកញ្ញានោះ, រាក្សសៈមកដល់ក្នុងពេលព្រលប់ ក៏បរិភោគបុរសនោះទៅ ។ មានបុរសជាច្រើននាក់បានទទួលមរណភាពបែបនេះ ។

កមលាការ បានដឹងច្បាស់នូវរឿងរ៉ាវទាំងនេះ ។ ក៏វិលត្រឡប់

ទៅកាន់ប្រទេសខ្លួនវិញ, ហើយយកសេចក្ដីនេះទៅក្រាបទូលព្រះមហាក្សត្រិយ៍វិក្រមាទិត្យសព្វគ្រប់ប្រការ, ហើយក៏ទូលបន្ថែមថា "សូមទ្រង់ព្រះមេត្តាប្រោស, សូមទ្រង់ព្រះរាជទានទូវនាងកញ្ញាដែលមានរូបឆោមលោមពណ៌ល្អប្រិមប្រិយនេះមកទូលព្រះបង្គំ" ។

ព្រះមហាក្សត្រិយ៍ទ្រង់តបទៅនឹងកមលាការថា "បំណងរបស់អ្នកនឹងសម្រេចដូចសេចក្ដីប្រាថ្នា" ។ ព្រះបាទវិក្រមាទិត្យ ទ្រង់ស្ដេចយាងទៅជាមួយនឹងកមលាការ ដល់កញ្ចិបុរី, ជិតនាងកញ្ញានរមោហិណី ។ លុះទ្រង់ទតទៅឃើញនាងកញ្ញា, ទ្រង់ឥតមានរំភើបព្រះទ័យឡើយ, ទ្រង់ស្ថិតនៅនឹង, មិនមានព្រះទ័យធ្លាក់ចុះទៅក្នុងកាមារម្មណ៍ទេ ។ ក្នុងពេលនោះ រាក្សសៈមានបំណងចង់បរិភោគព្រះមហាក្សត្រិយ៍, ក្នុងពេលរាក្សសៈនោះស្រែកសង្រ្កុកដំបូង, ព្រះអង្គបានយកព្រះហស្ដកាន់ដងព្រះខ័នថ្វា ហើយបម្រុងតយុទ្ធនឹងរាក្សសៈនោះវិញ ។ ទ្រង់បានតស៊ូនឹងរាក្សសៈរហូតដល់ពិឃាដរាក្សសៈនោះបានជាបរិយោសាន ។

នាងកញ្ញានរមោហិណី មានចិត្តសោមនស្សពន់ពេក ដោយឃើញព្រះអង្គទ្រង់ពិឃាដរាក្សសៈ (Râxasa) នោះបាន ។ នាងសរសើរព្រះអង្គជាអនេកប្បការ ហើយក្រាបបង្គំទូលថា "ឱ! ព្រះអង្គ, ទ្រង់បានជួយខ្ញុំម្ចាស់រួចពីកណ្ដាប់ដៃរាក្សសៈ ។ ទ្រង់បានប្រោសប្រាណទូវជីវិតខ្ញុំម្ចាស់, ព្រោះហេតុដូចនេះ ខ្ញុំម្ចាស់សូមជ្រកកោនក្រោមម្លប់របស់ព្រះអង្គ" ។ ព្រះមហាក្សត្រិយ៍ ទ្រង់ព្រះសណ្ដាប់ទូវពាក្យនាងកញ្ញា ហើយមានព្រះបន្ទូលតបថា "ឱ នាងកញ្ញា បើនាងចូលមកជ្រកកោន

នឹងយើង, ចូរនាងប្រែងចិត្តក៏ក្តីចំពោះបុរសដែលយើងនឹងប្រាប់គឺ "កម-លាការ" ជាសុមេធបុរស ហើយដែលយើងពេញចិត្តជាងគេ, ចូរនាងយកបុរសនេះធ្វើជាប្តីចុះ, ចូរនាងគោរពថា បុរសនេះជាស្វាមីនាងតាំងពីថ្ងៃនេះតទៅ" ។ នាងកញ្ញាព្រមតាមព្រះរាជឱង្ការព្រះមហាក្សត្រិយ៍ ។

លុះដល់ព្រះអង្គទ្រង់បានប្រគល់នាងកញ្ញាចំពោះកមលាការ ព្រះបាទវិក្រមាទិត្យទ្រង់ស្តេចយាងវិលត្រឡប់មកកាន់ព្រះរាជធានីវិញ ។

កមលាការ បាននាំយកនាងកញ្ញា ដែលមានរូបឆោមលោមពណ៌ស្រស់ប្រិមប្រិយ វិលត្រឡប់ទៅកាន់គេហដ្ឋានខ្លួនដែរ ។

រូបទេពនិម្មិតទីប្រាំបីទូលបន្ថែមថា "ឱ ព្រះមហាក្សត្រភោជៈ, តាមដែលទូលបង្គំក្រាបទូលមកនេះ ទ្រង់អាចជ្រាបហើយថា ព្រះបាទវិក្រមាទិត្យ ទ្រង់បានបំពេញបំណងអ្នកដទៃ ចំណែកព្រះអង្គវិញបានបំពេញបំណងអ្នកដទៃយ៉ាងនោះដែរឬទេ? បើទ្រង់មានទើបអាចគង់នៅលើបល្ល័ង្កទិព្វនេះបាន" ។ ព្រះបាទភោជៈ ទ្រង់ព្រះសណ្តាប់នូវវាចានៃរូបទេពនិម្មិតទី ៨, ទ្រង់ក៏បានស្តេចយាងចេញពីទីនេះ ដោយព្រះហឫទ័យអៀនខ្មាសពន់ពេក ។

* * *

(មានត)

# កំណត់និងប្រវត្តិការណ៍

## ប្រវត្តិនៃវត្តបទុមវតីរាជវរារាម
## ក្រុងភ្នំពេញ

### យុគបណ្ណានុរក្ស ប៊ូ-ប៉ូ រៀបរៀង

វត្តបទុមវតីរាជវរារាម ដែលតាំងនៅក្នុងសង្កាត់លេខ ៤ ក្រុងភ្នំពេញ សព្វថ្ងៃនេះ កាលដើមឡើយ ជាទីដំណែលវត្តចាស់បុរាណឈ្មោះថា "វត្តខ្ពបតាយ៉ង" កើតមានជាយូរអង្វែងជាង ៥០០ ឆ្នាំមកហើយដូចមានសេចក្តីកត់ត្រាក្នុងព្រះរាជពង្សាវតារក្រុងកម្ពុជាធិបតី បច្ចិមសម័យ ខ្សែទី ៣ តាំងពីទំព័រលេខ ៨៣ រៀងទៅថា៖

កាលព្រះបាទសម្តេចព្រះបរមរាជា (ពញាយ៉ាត) បានសោយរាជសម្បត្តិហើយទ្រង់គង់នៅក្រុងនគរធំបាន ១៦ ឆ្នាំ ស្តេចបោះបង់ចោលក្រុងនគរធំមកសាងក្រុងថ្មីនៅទួលបាសាន ក្នុងខែត្រស្រីសន្ធរ ទ្រង់គង់នៅក្រុងថ្មីនេះបានតែ ១ ឆ្នាំ ស្តេចចេញមកសាងក្រុងភ្នំពេញជាគ្រាដំបូង ក្នុងឆ្នាំថោះសប្តស័ក ព. ស. ១៩៧៨ គ. ស. ១៤៣៥ ។ គ្រាសាងក្រុងនោះ ព្រះអង្គត្រាស់បង្គាប់ឲ្យជីកព្រែក, ឲ្យធ្វើផ្លូវថ្នល់, ឲ្យកសាងវត្តជាច្រើននៅក្នុងក្រុង ដូចមានឈ្មោះព្រែកនិងឈ្មោះវត្តនៅជាប់រហូតមកដល់សព្វថ្ងៃនេះ ។ ទ្រង់ឲ្យកសាងវត្តមួយនៅទិសខាងជើងព្រះបរមរាជវាំង ហៅថា "វត្តឧណ្ណាលោម" ជាវត្តគណៈមហានិកាយ ។ ទ្រង់ឲ្យកសាងវត្តមួយទៀតនៅទិសខាងត្បូងព្រះបរមរាជវាំង

ហៅថា "វត្តខ្ទបតាយ៉ង" ជាវត្តគណៈមហានិកាយដែរ តែសម័យនោះព្រះសង្ឃនៅមិនទាន់មាននាមថាមហានិកាយទេ ព្រោះសម័យនោះប្រទេសកម្ពុជាពុំទាន់កើតមានព្រះសង្ឃគណៈធម្មយុត្តិនៅឡើយ ។ វត្តទាំង ២ នេះ ទ្រង់ឲ្យកសាងដំណាលគ្នាក្នុងឆ្នាំកុរបញ្ចស័ក ព.ស. ១៩៨៦ គ.ស. ១៤៤៣ ។

## វត្តខ្ទបតាយ៉ង

ដើមហេតុដែលឲ្យឈ្មោះថា "វត្តខ្ទបតាយ៉ង" ព្រោះទីវត្តនោះកាលដើមឡើយជាដីចំការរបស់តាយ៉ង ហើយគាត់បានដកខ្ទបមួយនៅពីខាងកើតចំការនោះផង ។ ឯទំហំទទឹងបណ្ដោយទីវត្តខ្ទបតាយ៉ង ក្នុងច្បាប់ព្រះរាជពង្សាវតារពុំបានប្រាប់ទេ ។

## វត្តបទុមវតីរាជវរារាម

ដើមហេតុដែលឲ្យឈ្មោះថា "វត្តបទុមវតីរាជវរារាម" នោះដូចមានសេចក្ដីអធិប្បាយតទៅនេះ៖

ចំណេរកាលពីព្រះបាទសម្ដេចព្រះបរមរាជា (ពញាយ៉ាត) មកមានព្រះមហាក្សត្រច្រើនព្រះអង្គគង់នៅក្រុងភ្នំពេញ ជាប់រៀងរហូតមកដល់ព្រះបាទសម្ដេចព្រះស្រីសុគន្ធបទ១ ស្ដេចបោះបង់ចោលក្រុងភ្នំពេញទៅសាងក្រុងថ្មីនៅទួលបាសាន ខែត្រស្រីសន្ធរ ក្នុងឆ្នាំជូតសប្តស័ក ព.ស. ២៤០៨ គ.ស. ១៨៦៥ ។ ព្រះមហាក្សត្រអង្គក្រោយៗ មកបានផ្លាស់ទៅសាងទីក្រុងនៅក្នុងខែត្រផ្សេងទៀតៗ ជាច្រើន រហូតដល់សាងក្រុងឧត្តុង្គមានជ័យ ។

បំណោរកាលពីនោះមកទៀត ព្រះបាទសម្ដេចព្រះនរោត្តមទ្រង់គង់នៅក្រុងឧត្តុង្គមានជ័យ, ទាន់ក្រោយព្រះអង្គបោះបង់ចោលក្រុងឧត្តុង្គស្ដេចមក សាងក្រុងភ្នំពេញ ជាគ្រាទីពីរ នៅឆ្នាំឆ្លូវសប្ដស័ក ព.ស. ២៤០៨ គ.ស. ១៨៦៥ ។ គ្រានោះ ទ្រង់បាននិមន្តសម្ដេច ព្រះសុគន្ធាធិបតី ប៉ាន គណៈធម្មយុត្តិពីវត្តសាលាគួរ[១] (វត្តអំពិលប៊ី) ក្រុងឧត្តុង្គ ឲ្យមកគង់នៅវត្តខ្ពបតាយ៉ង ដែលជាវត្តបទុមវតីសព្វថ្ងៃនេះ ហើយទ្រង់និមន្តសម្ដេចព្រះសង្ឃរាជ ទៀង គណៈមហានិកាយ ពីវត្តពុទ្ធប្រាង្គណ៍ ក្រុងឧត្តុង្គ ឲ្យមកគង់នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។

រឿងប្រែឈ្មោះវត្តខ្ពបតាយ៉ង ឲ្យហៅថាវត្តបទុមវតីរាជវរារាមវិញ អ្នកឧកញ៉ាមហាវិនិច្ឆ័យ សៅ វ៉ែត អាយុ ៩០ ឆ្នាំ និងព្រះពុទ្ធាចារ្យ ភុល-ទេស ព្រះជន្ម ៦៤ ឆ្នាំ គង់នៅវត្តបទុមវតី បានជំណាលថា «កាលសម្ដេចព្រះសុគន្ធាធិបតី ប៉ាន និមន្តចេញពីវត្តសាលាគួរ ក្រុងឧត្តុង្គ មកគង់នៅវត្តខ្ពបតាយ៉ង ក្រុងភ្នំពេញជាដំបូង គ្រានោះ វត្តខ្ពបតាយ៉ងជាទីវត្តចាស់បុរាណ គ្មានវិហារកុដិសាលាជាគ្រឿងដំណែលចាស់នៅសេសសល់ទេ សូម្បីតែភិក្ខុសាមណេរ ១ អង្គក៏គ្មានដែរ ។ វត្តចាស់នោះក្លាយទៅជាទីព្រៃស្ងាត់ ព្រោះអ្នកស្រុកបោះបង់ចោលជាច្រើនឆ្នាំមកហើយ ប៉ុន្តែ បានជាគេដឹងថាកន្លែងនោះជាទីវត្តចាស់បុរាណ ដោយសារគេមើលច្បាប់ព្រះរាជពង្សាវតារផង គេសង្កេតមើលឃើញទីទួលព្រៃមួយខ្ពស់ជាងគេផង ហើយនៅលើទួលនោះមានពោធិ

---

១ ហៅតាមត្រឹមត្រូវថា វត្តសាលាគំនូរ ។ ឬហៅ សាលាគួ ព្រោះមានសាលាពីរ ក៏បាន ។

ព្រែកស្ទឹងមួយតូច បែបជាកេងឆ្មោសថ កន្លែងកេងនោះមានព្រះដី ១ អន្ត តូច នៅក្បែរព្រះដីនោះមានផែនថ្មសទ្ទឹកសីមា ១ ផ្ទាំង, នៅទិសខាងកើតមុខទួលនោះមានខ្ពបមួយតូចវែង ដែលខ្មោចតាយ៉ង់គាត់ដកយកទឹកស្រោចដំណាំគាត់, ឯទឹកក្នុងខ្ពបនេះមិនរីងស្ងួតទេ តែងដក់នៅយូរប៉ុន្មានវស្សាហើយថ្លាស្អាតផង អ្នកស្រុកដងយកទឹកក្នុងខ្ពបនេះប្រើប្រាស់បាន ។

គ្រានោះ ព្រះបាទសម្ដេចព្រះនរោត្តម ទ្រង់ត្រាស់បង្គាប់មេការ ឲ្យដឹកនាំយកឈើព្រះរាជទ្រព្យពីក្រុងឧត្តុង្គមកកសាង ព្រះវិហារ, កុដិ, សាលា នៅលើទួលនោះ ទ្រង់ឲ្យដីកគូស្នាមភ្លោះខាងជើង ខាងត្បូង និងខាងលិចវត្ត ដើម្បីយកអាចម៍ដីចាក់បំពេញពង្រីកទួលនោះឲ្យបានខ្ពស់ធំទូលាយជាងមុន និងទ្រង់ឲ្យដីកខ្ពបចាស់នោះឲ្យជ្រៅជាងមុនទៅទៀត រួចឲ្យដាំដើមឈូកក្នុងគូស្នាមភ្លោះទាំង ៣ ជ្រុងវត្ត ។ លុះរៀបចំវត្តល្មមសមគួរហើយ ក៏ធ្វើបុណ្យបញ្ចុះសីមាឆ្លងវិហារកុដិសាលា, វេលានោះ បានប្រែឈ្មោះ "វត្តខ្ពបតាយ៉ង់" ជា "វត្តបទុមវតីរាជវរារាម" វិញ ប្រែថា "វត្តមានឈូកជារបង ជាអារាមដ៏ប្រសើររបស់ព្រះរាជា" ជាប់រហូតមកដល់សព្វថ្ងៃនេះ ។

បានរកឃើញកស្តុតាងមួយទៀត: មានផែនថ្ម ១ ផ្ទាំងជាសទ្ទឹកសីមាទិសបូព៌ ដែលគេដាក់ទុកនៅមុខព្រះវិហារវត្តបទុមវតីសព្វថ្ងៃនេះ មានអក្សរចារឹកនៅថ្មសទ្ទឹកសីមានោះថា "ព. ២៤១៨ មមែ នក្ខត្តស័ក ហេមន្តវតុ បុស្សមាស សុក្កបក្ស ចតុទ្ទសី តិថីកុម្ភារ ជាបរិច្ឆេទកាល

កំណត់ទីត្រង់ណោះ បានបន្ទុះជាមហាសីមារួចហើយ ឯមហាសីមានេះ បន្ទោយ ៥ សិន ទទឹង ៤ សិន ។

## « ប្រែ » (១)

បញ្ជាក់សេចក្តីក្នុងអក្សរចារឹកខាងលើនេះ ឲ្យងាយស្តាប់ថា ថ្ងៃ ៣ ១៤ ៗ ២ ឆ្នាំមមែ នក្សត្រត្រីស័ក ហោមន្តរជ្ជ ព.ស. ២៤១៤ ជាបរិច្ឆេទកាល កំណត់ទីត្រង់នេះបានបញ្ចុះជាមហាសីមារួចហើយ ឯមហាសីមានេះ បណ្តោយ ៥ សិន ទទឹង ៤ សិន[២] ។

គិតតាំងពី ព.ស. ២៤០៨ គ.ស. ១៨៦៥ ជាឆ្នាំដែលសម្តេចព្រះសុគន្ធាធិបតី ប៉ាន ចាប់ផ្តើមកសាងវត្តបទុមវតីជាដំបូងបំផុតមក ការរៀបចំតាក់តែងវត្តនេះចេះតែបានចំរើនកើនឡើងរៀងរាល់ឆ្នាំ ដូចមានកុដិ, សាលាទីងបូជនីយដ្ឋានជាច្រើន គឺ

## ព្រះពោធិព្រឹក្ស[៣]

ព្រះបាទ សម្តេច ព្រះនរោត្តម ទ្រង់ត្រាស់បង្គាប់មុខមន្ត្រីឲ្យធ្វើបុណ្យសម្ពោធ ៣ ថ្ងៃដាំកូនព្រះពោធិព្រឹក្ស ដែលព្រះគេខសារគ្រៀងនៅលង្កាទ្វីបនាំមកថ្វាយព្រះអង្គ នៅទីមុខវត្តបទុមវតី នៅថ្ងៃ ៣ ៗ ៣ ១០ ឆ្នាំកុរនព្វស័ក ព.ស. ២៤៣០ ច.ស. ១២៤៩ គ.ស. ១៨៨៧ ក្នុងសម័យនៃសម្តេចព្រះសុគន្ធាធិបតី ប៉ាន ។

---

១ បំឡែងតាមបែបអក្សរដែលគេចារឹកនៅថ្មសន្ទឹកសីមានោះ ។ ២ ពីរហត្ថត្រូវជា ១ ម៉ែត្រ, ២ ម៉ែត្រត្រូវជា ១ ព្យាម, ២០ ព្យាមត្រូវជា ១ សិន ។ ឯមហាសីមាវត្តបទុមវតីនេះ បណ្តោយ ៥ សិន ត្រូវជា ២០០ ម៉ែត្រ, ទទឹង ៤ សិន ត្រូវជា ១៦០ម៉ែត្រ ។ (វចនានុក្រមខ្មែរ) ។ ៣ ស្រង់ពីច្បាប់ព្រះរាជពង្សាវតារក្រុងកម្ពុជា ។

## ព្រះចេតិយអង្គធំ (១)

សម្តេចព្រះមង្គលទេពាចារ្យ អៀម បានឃោសនាពុកពុទ្ធបរិស័ទកសាងព្រះចេតិយធំមួយអង្គក្នុងវត្តបទុមវតី ។ លុះកសាងរួចស្រេចហើយបានធ្វើបុណ្យបញ្ចុះព្រះបរមសារីរិកធាតុ ១ អង្គ និងព្រះអរហន្តធាតុ ១ អង្គ ដែលព្រះរតនសារគ្រូនៅលង្កាទ្វីបនាំយកមកថ្វាយព្រះបាទសម្តេចព្រះនរោត្តមក្នុងពេលជាមួយកូនព្រះពោធិព្រឹក្សនោះ ព្រមទាំងបញ្ចុះព្រះអដ្ឋិធាតុនៃសម្តេចព្រះសុគន្ធាធិបតី ប៉ាន ផង នៅថ្ងៃ ៤ ᧱ ៦ ឆ្នាំរកាឯកស័ក ព.ស. ២៤៥២ ច.ស. ១២៧១ ត្រូវនឹងថ្ងៃទី ៨ ខែម៉េ គ.ស. ១៩០៩ ក្នុងរជ្ជកាលនៃព្រះបាទសម្តេចព្រះស៊ីសុវត្ថិ (ព្រះបរមកដានុកោដ្ឋ) ។

## ព្រះវិហារថ្មី

សម្តេចព្រះមង្គលទេពាចារ្យ ស៊ុក ជាមេគំនិតបានចាប់ផ្តើមរុះរើព្រះវិហារចាស់ក្នុងវត្តបទុមវតីចេញ ហើយកសាងព្រះវិហារថ្មីតាំងពីក្នុងឆ្នាំឆ្លូវនព្វស័ក ព.ស. ២៤៨០ គ.ស. ១៩៣៧ ក្នុងរជ្ជកាលនៃព្រះបាទសម្តេចព្រះស៊ីសុវត្ថិ-មុនីវង្ស ។ លុះកសាងព្រះវិហារថ្មីនោះរួចស្រេចហើយ បានធ្វើបុណ្យសម្ពោធឆ្លងនៅថ្ងៃ ៧ ᧯ ៤ ឆ្នាំមមីចត្វាស័ក ព.ស. ២៤៨៥ ច.ស. ១៣០៤ ត្រូវនឹងថ្ងៃទី ២០ ខែម៉ារ្ស គ.ស. ១៩៤២ ក្នុងរជ្ជកាលនៃព្រះបាទសម្តេចព្រះនរោត្តម សីហនុ-វរ្ម័ន និងក្នុងសម័យនៃសម្តេចព្រះសុធម្មាធិបតី អ៊ុង-ស្រី ។

---

១ ស្រង់ពីច្បាប់ព្រះរាជពង្សាវតារក្រុងកម្ពុជា ។

ក្រៅអំពីថាវរត្ត ៣ យ៉ាងខាងដើមនេះ នៅមានកិច្ចការជាសំខាន់ច្រើនទៀត(១) គឺបានរៀបចំតាក់តែងទីខាងមុខវត្តបទុមវតីឲ្យស្អាតបាតសមរម្យ, បានធ្វើកុដិធំ ៗ ជាច្រើនខ្នង, បានធ្វើទីប៉ាធា ៣ ខ្នង, បានធ្វើសាលាសំណាក់ ២ ខ្នងនឹងសាលាភេសជ្ជៈ ១ ខ្នង, បានធ្វើស្រះឈូក ១ គូ, បានធ្វើសាលាបិណ្ឌ ១ ខ្នងនឹងសាលាបរិយត្តិធម្មវិន័យ ១ ខ្នង, បានរុះរើកេងជួងចាស់ធ្វើជាថ្មីឡើងវិញនៅកន្លែងចាស់ដដែល, បានចាក់ដីបំពេញទីវត្តឲ្យរាបស្មើ ព្រមទាំងបានធ្វើកំពែងវត្តផង ៗល ៗ ការរៀបចំទីវត្តបានចំរើនឡើងរៀងរាល់ឆ្នាំ ដោយសារកម្លាំងសទ្ធាជ្រះថ្លានៃពួកពុទ្ធបរិស័ទទាំងឡាយ មានអ្នកឧកញ៉ាមហាមន្ត្រី ញឹក-នូវ ជាអ្នកទទួលភារៈចាត់ការ បានចាប់ផ្តើមរៀបចំទីមុខវត្តនឹងក្នុងវត្តតាំងពី ព.ស. ២៤៨៥ គ.ស. ១៩៤២ ជាដើមរៀងមក ក្នុងសម័យនៃសម្តេចព្រះសុធម្មាធិបតី អ៊ុង-ស្រី ។

## សេចក្តីបញ្ចប់

អាយុវត្តឧបតាយ៉ង, ចាប់ពីត្រឹម ព.ស. ១៩៧៨ គ.ស. ១៤៣៥ ដែលចាប់ផ្តើមកសាងវត្តឧបតាយ៉ងនៅសម័យសាងក្រុងភ្នំពេញគ្រាដំបូង រហូតមកដល់ ព.ស. ២៤០៨ គ.ស. ១៨៦៥ ដែលប្រែឈ្មោះវត្តឧបតាយ៉ង ជាវត្តបទុមវតីវិញ នៅវេលាសាងក្រុងភ្នំពេញគ្រាទី ២ ឃើញបានចំនួន ៤៣១ ឆ្នាំ នេះជាអាយុនៃវត្តឧបតាយ៉ង ៗ

---

១ ស្រង់ពីសេចក្តីរាយការរបស់អ្នកឧកញ៉ាមហាមន្ត្រី ញឹក-នូវ ។

អាយុវត្តបទុមវតី, ចាប់ពីត្រឹមឆ្នាំដែលតាំងឈ្មោះវត្តបទុមវតី រហូតមកដល់ ព.ស. ២៤៩៨ គ.ស. ១៩៥៥ បានចំនួន៩០ឆ្នាំ នេះជាអាយុនៃវត្តបទុមវតី ។ យក ៤៣១ ឆ្នាំបូករួមនឹង ៩០ ឆ្នាំ ត្រូវជា ៥២១ ឆ្នាំ នេះទុកជារយៈកាលនៃវត្តនេះ ដែលបានប្រតិស្ឋានមក ។

## ភាពទាក់ទងនឹងពុទ្ធសាសនា ដែលគួរស្ដាប់ៈ

សម្រាប់អ្នកស្រុកជប៉ុន គេកាន់ថា "ព្រះពុទ្ធសាសនា ជាសំពៅមាសរបស់វឌ្ឍនធម៌នៃជាតិ" ព្រោះអក្សរសាស្ត្រ ការស្ថាបត្យ ជាងតន្ត្រី ជាងកំបោរ ជាងគំនូរ និងអ្នកតែងសៀវភៅ រហូតដល់ការតាំងផ្កាឈើ ឬល្ខោន ក៏កើតមកពីសាសនាទាំងអស់, ហេតុនេះ ទើបទុកជាការត្រឹមត្រូវហើយ ដែលឲ្យកិត្តិយសចំពោះព្រះពុទ្ធសាសនាថា "ជាសំពៅមាសរបស់វឌ្ឍនធម៌នៃជាតិ" ព្រោះបានផ្ទុកយកសិល្បៈវិទ្យាការផ្សេង ៗ មកកាន់ប្រទេសជប៉ុនជាច្រើនយ៉ាង ។

ចាកសៀវភៅ «ដោយមុខមែនពិតរបស់ជប៉ុន»

ប្រែចាកទស្សនាវដ្ដីសាសនាភាសាថៃ

អ្នកប្រែ៖ ចាប - ពិន

យោបល់អ្នកប្រែៈ

ខ្មែរយើងក៏ទុកព្រះពុទ្ធសាសនា ជាសំពៅមាសរបស់វឌ្ឍនធម៌នៃជាតិដូចជប៉ុនដែរ ព្រោះខ្មែរទាំងប្រទេសយល់ថា ព្រះពុទ្ធសាសនាមានវត្តអារាមជាមូលដ្ឋាន ជនណាបានចូលបួសជាបព្វជិត ឬជាគ្រហស្ថអាស្រ័យនៅក្នុងវត្ត តែងតែចេះអក្សរ ចេះស្ថាបត្យ ចេះគ្រឿងតន្ត្រី កំបោរ ចេះគំនូរ ចេះតែងសៀវភៅ រហូតដល់ចេះភ្លេង ឬចេះល្ខោន, មកពីវត្តជាទីផ្ទុកនូវសិល្បៈវិទ្យាទាំងនេះតាំងពីបុរាណកាលមក ។

ប.- ព.

# ពិធីបុណ្យវិសាខបូជានៅក្រុងវ៉ាស៊ីនតោន

## លោកលេខាធិការ ញ៉ែម-ខឹម

ប្រែអំពីសារពត៌មាន « កាំបូជ » លេខ ២៨៩២ ឆ្នាំទី ១២

ចេញថ្ងៃ ៣០ ឧសភា ឆ្នាំ ១៩៥៥

---

កាលពីល្ងាចថ្ងៃសុក្រមុននេះ នៅមហាវិទ្យាល័យហាវ៉ាដ៍ ពួកបព្វជិតនិងពួកពុទ្ធបរិស័ទនៅក្រុងវ៉ាស៊ីនតោន បានរួមគ្នាធ្វើបុណ្យប្រចាំឆ្នាំមួយ គឺបុណ្យវិសាខបូជា ។

បុណ្យនេះជាបុណ្យលើកទី ៣ ដែលគេធ្វើនៅក្រុងវ៉ាស៊ីនតោន ដោយសារពួកសមាគមមិត្តនៃពុទ្ធសាសនា ដែលមានចំនួនមួយភាគ ៤ នៃប្រជាជននៅក្រុងនោះជាអ្នកផ្តើម ។ បុណ្យនេះធ្វើឡើងដើម្បីគោរពចំពោះថ្ងៃដែលព្រះអង្គទ្រង់ប្រសូតទ្រង់បានសំរេចពោធិញាណ និងទ្រង់ចូលព្រះនិព្វាន ។

មានអគ្គទូតជាច្រើនសាសន៍ ដែលតាំងនៅក្រុងវ៉ាស៊ីនតោន បានអញ្ជើញទៅរួមធ្វើពិធីនេះដែរ ។ ពិធីបុណ្យនេះបានធ្វើឡើងក្រោមអធិបតីភាពនៃសមាគមអប់រំខាងព្រះពុទ្ធសាសនានៃមហាវិទ្យាល័យ ។

សមាគមនេះ បានចាប់កំណើតឡើងបីឆ្នាំមកហើយ ដោយមានសមាជិកសុទ្ធតែជាអ្នកខ្នះខ្នែងជួយឧបត្ថម្ភហើយជាអ្នកចេះដឹងជ្រៅជ្រះខាងពុទ្ធសាសនាផង ។

មានជនម្នាក់តំណាងក្រុមនោះបាននិយាយថា "ឆ្នាំក្រោយសមាគមនេះនឹងបង្កើតឲ្យមានកម្មវិធីបង្រៀនខាងអក្សរសាស្ត្រ និងច្បាប់វិន័យ

ខាងព្រះពុទ្ធសាសនា ។ កាលពីមុនមានសាស្ត្រាចារ្យម្នាក់ដែលគេជ្រើសរើសនៅនាក្រុងនោះ បានមកបង្រៀនភាសាបាលីប្រចាំថ្នាក់មួយបែបដែលគេនិយមប្រើក្នុងសម័យព្រះពុទ្ធគង់នៅឡើយ ដល់ពួកសមាជិកនៃសមាគមនោះ ។ ក៏ប៉ុន្តែការបង្រៀននោះអាក់ខានទៅវិញ ដោយសាស្ត្រាចារ្យនេះត្រូវផ្លាស់ទៅកាន់កន្លែងថ្មីទៀត ។

អ្នកតំណាងក្រុមនេះបានពោលបន្ថែមទៀតថា ''រដ្ឋាភិបាលនៃប្រទេសលង្កាបានផ្ញើអំណោយជាសៀវភៅ មានអត្ថបទជាភាសាបាលីជាច្រើនដល់សមាគមនេះ ដូច្នេះការបង្រៀននឹងចាប់ផ្ដើមឡើងវិញនៅពេលឆាប់ៗខាងមុខនេះ ។

ការសន្និបាតក្នុងឆ្នាំនេះ ធ្វើនៅស្ថានឯកអគ្គរាជទូតថៃនិងនៅស្ថានឯកអគ្គរាជទូតកោះលង្កា ។

សព្វថ្ងៃនេះ សមាគមកំពុងខំខ្នះខ្នែងរៀបចំឲ្យមានការទស្សនានៅកន្លែងឯទៀតឲ្យបានកាន់តែច្រើនក្នុងតំបន់នោះ ដើម្បីឲ្យសមាជិកមានឱកាសនឹងផ្សាយពន្យល់លទ្ធិព្រះពុទ្ធសាសនា ដល់ប្រជាជនឯទៀតៗផង ។

លោកប្រធានាធិបតី អីសិនហូវ័រ បានទទួលឲ្យគេបញ្ជាក់អំពីសេរីភាពនៃពុទ្ធសាសនាជូនលោកម្ដងទៀត ។ មិនតែប៉ុណ្ណោះ លោកសុំឲ្យពួកពលរដ្ឋអាមេរិកាំង '' បញ្ជាក់អំពីច្បាប់ដែលជនម្នាក់ៗត្រូវមានសិទ្ធិនឹងជឿចំពោះសាសនាណាក៏ដោយ តាមសម្បជញ្ញៈរបស់ខ្លួន'' ជូន

លោកម្តងទៀតដែរ ។ លោកប្រធានាធិបតីបានពោលបំភ្លឺថា "សេចក្តីបញ្ជាក់បន្ថែមនេះជាការមួយសំខាន់ណាស់ក្នុងសារតារ នៅពេលដែលប្រជាជនសកលលោកមិនព្រមទទួលស្គាល់សេរីភាពជនដទៃ" ។

សេចក្តីថ្លែងការណ៍របស់លោកប្រធានាធិបតី ដែលនៅក្នុងសារលិខិតមួយ គេបានយកទៅសូត្រនៅវិល្លីយ៉ាំស្បូរ នៅពេលដែលគេធ្វើពិធីបញ្ជាក់អំពី "ជំនឿរបស់ជនជាតិអាមេរិកាំងចំពោះសេរីភាពនៃលទ្ធិព្រះពុទ្ធសាសនា" ។ នៅពេលធ្វើនោះ គឺកាលពីថ្ងៃអាទិត្យមុននេះ លោកវេជ្ជបណ្ឌិតក្រាយសុន-ពរ-គីរ៉ក ប្រធាននៃមហាវិទ្យាល័យកូឡុំប៊ីយ៉ាបានពោលចំពោះមុខប្រជាជនចំនួន ៣.៥០០ នាក់ថា សេរីភាពខាងសាសនាមិនអាចនឹងឃ្លាតចេញពីសេរីភាពឯកជនបានឡើយ" ។ លោកបានពោលអាងថា ដោយហេតុតែមានការចំរើនខាងផ្លូវដឹកនាំនឹងក្នុងការទាក់ទងគ្នាទៅវិញទៅមកប្រជាជនគ្រប់នគរ ក្នុងសម័យឥឡូវនេះត្រូវតែបានទទួលព្រឹត្តិសនាឬអនាគតដូចៗគ្នា" ។ លោកបានអំពាវនាវ ឲ្យជនដែលមានធន្ទៈល្អ ស៊ូបន្តនឹងច្បាប់ខាងផ្លូវចិត្ត រួមតែមួយជាមួយគ្នានេះ" ។

លោកវេជ្ជបណ្ឌិត គីរ៉ក បានពោលរំឭកអំពីច្បាប់បុរាណដែលស្តីអំពីសេរីភាពស្ថិតនៅឯក្រុងវិល្លីយ៉ាំស្បូរ ហើយនឹងអនុស្សាវរីយ៍នៃវីរបុរសដែលបានផ្តើមបង្កើតសេរីភាព ហើយថែមទាំងបានតស៊ូដើម្បីការពារសេរីភាពនេះផង កាលក្នុងសតវត្សទី ១៨ ។

លោកបានពោលបន្ថែមទៀតថា "យើងត្រូវដោះស្រាយបញ្ហាសម័យនេះ ឲ្យដូចជារបៀបដែលវីរបុរសយើងមុនៗ លោកបានដោះស្រាយបញ្ហារបស់លោកកាលជំនាន់នោះដែរ" ។ សហប្រជាជាតិបានធ្វើគុណបំណាច់ជាច្រើនអនេកដល់ប្រជាជនគ្រប់ប្រទេស ហើយមានពោលថា ច្បាប់ធម្មនុញ្ញសហប្រជាជាតិសព្វថ្ងៃនេះ បានធ្វើឲ្យមានការព្រមព្រៀងមួយយ៉ាងធំទូលាយណាស់ ។ ដូច្នេះយើងមិនត្រូវយល់ថា ធម្ម-នុញ្ញសហប្រជាជាតិជាថ្នាំសម្រាប់ដោះស្រាយបញ្ហាយើងសព្វថ្ងៃនេះ" ។

"យើងមានចិត្តប្រាថ្នានឹងបង្កើត (វែរក្យា) ច្បាប់នេះមិនមែនមានចិត្តបង់រំលាយទេ ហើយបើយើងគ្រាន់តែខំព្យាយាមពង្រីកសាលាបង្រៀនរាំងប្រជាជាតិឲ្យកាន់តែមានចំនួនច្រើនឡើងប៉ុណ្ណោះ នោះយើងមិនអាចនឹងរកឃើញនូវផែនការសន្តិភាព និង សុខភាពសកលលោកបានឡើយ ដោយប្រាសចាកច្បាប់ខាងលើនេះ ។

នៅទីបញ្ចប់ លោកវេជ្ជបណ្ឌិតមានប្រសាសន៍ថា ការដោះស្រាយនៃបញ្ហាក្នុងថ្ងៃនេះ អាចទុកពិភាក្សាទៅពេលក្រោយទៀតបានយ៉ាងហ្មត់ចត់ ជាមួយនឹងបញ្ហាដែលជាប់ទាក់ទងក្នុងប្រទេស តែដែលសំខាន់ជាងគេ គឺបញ្ហាស្តីអំពីច្បាប់ខាងផ្លូវចិត្ត ។ គឺថាបើមានសតិសម្បជញ្ញៈខាងធ្វើចិត្តឲ្យនឹងក្នុងជំនឿហើយ នោះយើងអាចរួមបញ្ហាទាំងពីរខាងលើនេះបាន ។